**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# វិធានការស្រាវជ្រាវបទល្មើសរបស់ ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **អាំង ខួចឡាង**

**យ៉េង សេរីរ័ត្ន**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អាំង ឡួចឡាង** និង **យ៉េង សេរីរ័ត្ន** ជានិស្សិត **ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ** ឆ្នាំទី៤ ជំនាន់ទី២០ ក្នុងឆ្នាំសិក្សា២០១៦-២០២០ សូមថ្លែងនូវកតញ្ញូនិងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើត លះបង់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ ដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្គត់ផ្គង់ចំពោះការស្នាក់នៅ ការរៀនសូត្រតាំងពីថ្នាក់មតេយ្យសិក្សារហូតដល់កម្រិតបរិញ្ញាបត្រ និងបានរួមចំណែកនូវការផ្តល់កម្លាំងកាយចិត្ត ការអប់រំ ប្រៀនប្រដៅ ព្រមទាំងផ្តល់នូវព្រហ្មវិហារធម៌ ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់ពុំអាចកាត់ថ្លៃបាន មិនអាចរៀបរាប់អស់ នៅក្នុងសេចក្តីថ្លែងអំណរគុណនេះអស់បានឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នៅកន្លែងបណ្តុះបណ្តាលចំណេះដឹង និងបណ្តុះនូវស្មារតីការស្រាវជ្រាវ និងការបង្កើនចំណេះវិជ្ជាផ្នែកនីតិសាស្ត្រ(ច្បាប់)រហូតដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ និងចំណេះដឹងពិតប្រាកដ។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លុយ ចណ្ណា សាកលវិទ្យាធិការ និង លោក-លោកស្រី សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** ព្រមទាំងលោក-លោកស្រី សាស្ត្រាចារ្យ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវការអប់រំ ព្រមទាំងចំណេះដឹង និងក្រមសីលធម៌ដល់យើងខ្ញុំក្នុងអំឡុងពេល០៤ឆ្នាំនេះ។

ជាងនេះទៅទៀតក៏សូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងនៃ **បណ្ណាល័យនីតិសាស្ត្រ** បានរៀបចំនិងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅដែលបង្កជាលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងចូលរួមចំណែកក្នុងការរៀបចំ តាក់តែងជាសារណានេះឡើង។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌា** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិតយោបល់ក្នុងការកែសម្រួល និងតម្រង់ផ្លូវដល់យើងខ្ញុំកន្លងមករហូតបានសម្រេចនូវស្នាដៃមួយនេះ។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរគុណដល់ បងប្អូនមិត្តៗនិស្សិតដែលបានស្គាល់ និងបានផ្តល់កម្លាំងចិត្តជំរុញការសរសេរ និងតាក់តែងសារណានេះឡើង ដោយផ្តល់នូវគុណតម្លៃទទួលទុកជាឯកសារស្រាវជ្រាវ ជាបណ្តោះអាសន្ននិងរួមចំណែកជាការផ្តល់នូវគំនិតបន្តិចបន្តួចគ្រាន់ជាការស្រាវជ្រាវបន្ថែមក្នុងថ្នាក់នីតិសាស្ត្រ និងបង្ហាញបទពិសោធន៍ ចំពោះការអនុវត្តជាក់ស្តែងនៅសាលាដំបូង ដើម្បីយកមកប្រៀបធៀបនិងទ្រឹស្តីដែលបានផ្តល់ដោយសាស្ត្រាចារ្យ។

# អារម្ភកថា

ក្នុងរយៈពេលដែលបានឆ្លងកាត់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកនីតិសាស្រ្ត និងចូលមកដល់ឆ្នាំទី៣ យើងបានផ្ដោតទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងការខិតខំប្រឹងប្រែងស្រាវជ្រាវ រួមទាំងបានរួមចំណែកអនុវត្តជាក់ស្ដែងនៅសាលាដំបូងខេត្តកណ្ដាលក្នុងនាមជាជំនួយការចៅក្រម អស់រយៈពេលជិត០១ ឆ្នាំ ដែលពាក់ព័ន្ធនឹងចៅក្រមស៊ើបសួរ ក៏បានចាប់អារម្មណ៍នឹងមានគោលបំណងចងក្រងចេញជាឯកសារបង្ហាញនូវពិសោធន៍ជាក់ស្ដែងសម្រាប់ការស្រាវជ្រាវទើបស្រលាញ់នឹងជ្រើសយកប្រធានបទ **»វិធានការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ»** ដែលជាវិធានការសំខាន់ក្នុងដំណើរការរឿងក្ដីសម្រាប់បទល្មើសព្រហ្មទណ្ឌដែលតំណាងអយ្យការបានសម្រេចប្ដឹងមកចៅក្រមដែលទទួលបន្ទុកកិច្ចស៊ើបសួរ នៅលើរឿងក្ដីព្រហ្មទណ្ឌនីមួយៗ។

កន្លងមកប្រធានបទមួយនេះទោះបីមានការស្រាវជ្រាវជាបន្តបន្ទាប់ និងមានការតាក់តែងជាសារណាច្រើនក៏ពិតមែន ក៏ប៉ុន្តែបែបផែនស្រាវជ្រាវនិងការផ្ដល់ជាគំនិតមិនដូចគ្នាទាំងស្រុងឡើយ ជាពិសេសគឺការពន្យល់ ជាមួយនិងការអនុវត្តជាក់ស្ដែង។ ដោយឃើញថាមានការខ្វះខាត ខ្វះចន្លោះលើចំណុចមួយចំនួនទើបសម្រេចចិត្តចងក្រងនូវខ្លឹមសារនៃសារណានេះឲ្យមានលក្ខណៈល្អប្រសើរ ច្បាស់លាស់ ស៊ីជម្រៅទៅលើប្រធានបទនេះឱ្យងាយស្រួលយល់ថែមទាំងទំនើបជាងមុនផងដែរ។ ក្រោយពេលដែលយើងខ្ញុំបានចូលរួមអនុវត្តជាក់ស្ដែងបានបង្ហាញឱ្យឃើញថា មានការលំបាកក្នុងការយកទ្រឹស្ដីទៅអនុវត្តទាំងស្រុងជាមួយនឹងបទល្មើសព្រហ្មទណ្ឌ ដែលតែងតែកើតឡើងក្នុងសង្គមខ្មែរ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គ្រប់ការអនុវត្តដំណោះស្រាយលើដំណើររឿងក្ដីទាំងអស់ សុទ្ធតែមានគោលបំណងការពារយុត្តិធម៌ក្នុងសង្គមនិងបង្ការឲ្យបាននូវការប្រព្រឹត្តបទល្មើសជាថ្មីរបស់ជនត្រូវចោទ ឬដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ ការពារផលប្រយោជន៍របស់ជនរងគ្រោះឬដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរងគ្រោះពីអំពើរបស់អ្នកផ្ដើមគំនិតចារី សហចារី ឬអ្នកសមគំនិត។

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានភាពស្មុគស្មាញបន្តិចដោយសារតែវាជាវិធានចាប់បង្ខំឲ្យបុគ្គលដែលបានទទួលនូវសិទ្ធិអំណាច ត្រូវតែអនុលោមតាមគ្រប់កាលៈទេសៈ លើកលែងតែបញ្ញត្តិជាឆន្ទានុសិទ្ធិរបស់អាជ្ញាធរតុលាការ ក្រៅពីនេះមិនអាចធ្វើបានតាមតែអំពើចិត្តរបស់ខ្លួនបានឡើយ។ កាលណាមានអំពើណាមួយដែលធ្វើឡើងដោយផ្ទុយពីអ្វីដែល ក្រមនីតិវិធីបានចាប់បង្ខំកិច្ចទាំងនោះ នឹងត្រូវបានបុគ្គលមានផលប្រយោជន៍ជាភាគីព្រហ្មទណ្ឌអាចប្ដឹងសុំមោឃៈភាពកិច្ចទាំងនោះ ទៅស្ថាប័នមានសមត្ថកិច្ច។

ជាចុងក្រោយយើងខ្ញុំ សង្ឃឹមថាកិច្ចការស្រាវជ្រាវរួមទាំងឯកសារយោងដែលមកតាំងបង្ហាញក្នុងស្នាដៃនេះ គ្រាន់តែមានគោលបំណងសិក្សាតែប៉ុណ្ណោះ ដូច្នេះជៀសមិនផុតពីការធ្វេសប្រហែសបង្កើតឲ្យមាន

នូវកំហុសដោយប្រការណាមួយឡើយ ហេតុដូចនេះសូមខន្តីអភ័យទោសជាមុន និងជួយកែលម្អនូវកំហុសទាំងឡាយដែលកើតមាននៅក្នុងស្នាដៃមួយនេះ។

យើងខ្ញុំសូមទទួលការរិះគន់ពីសំណាក់ លោក លោកស្រីសាស្រ្តាចារ្យ បងប្អូនមិត្តៗនិស្សិតទាំងអស់ដែលបានអានស្នាដៃមួយ និងរីករាយទទួលយកនូវកំហុសដែលកើតមានដោយអចេតនា។

## មាតិកា


**សេចក្តីផ្តើម**.......................................................................................................................១

## ជំពូកទី១
## មូលដ្ឋានគ្រឹះនៃការស៊ើបសួរ

**ផ្នែកទី១៖ទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរ**.........................................៣

**កថាខណ្ឌទី១៖ សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ**........................................................៤

១.១.១ តើចៅក្រមស៊ើបសួរជាអ្នកណា?...........................................................................................៥

១.១.២ គោលបំណងនៃការបង្កើតចៅក្រមស៊ើបសួរ...........................................................................៥

**កថាខណ្ឌទី២៖ ភាពដែលអាចបំពេញមុខការបាន** ..............................................................៦

១.២.១ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ..........................................................................................៦

១.២.២ វិសមិតភាពមុខងារ..............................................................................................................៨

**កថាខណ្ឌទី៣៖ ឧទ្រម្ម់ការដាច់ខាតដែលត្រូវគោរព**.............................................................៨

១.៣.១ ការសម្ងាត់នៃការស៊ើបសួរ .....................................................................................................៩

១.៣.២ការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខណ៍អក្សរ...................................................................១០

**ផ្នែកទី២៖ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**...............១០

**កថាខណ្ឌទី១៖ ការដាក់ពាក្យប្តឹង**.........................................................................................១១

២.១.១ បណ្តឹងបរិហារ......................................................................................................................១១

២.១.២ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី........................................................១៥

**កថាខណ្ឌទី២៖ អធិបញ្ជារបស់នាយឋានានុក្រម** .....................................................................២០

២.២.១ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.........................................................................................២០

២.២.២ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ .........................................................................................................២០

**ផ្នែកទី៣៖ សិទ្ធិអំណាចនៃការប្រើប្រាស់វិធាននិរន្តរាយ** ..........................................................២១

**កថាខណ្ឌទី១៖ វិធានការបង្ខំរបស់ចៅក្រមស៊ើបសួរ**..................................................................២១

៣.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន ..............................................................................................................២២

៣.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន...............................................................................................................២២

៣.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន.............................................................................................................២៣

**កថាខណ្ឌទី២៖ វិធានការត្រួតពិនិត្យរបស់តុលាការ**......................................... ២៤
៣.២.១ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ......................................... ២៤
៣.២.២ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន......................................... ២៥
៣.២.៣ ដីកាបង្គាប់ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ......................................... ២៥
**កថាខណ្ឌទី៣៖ លក្ខខណ្ឌ និងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន**......................................... ២៦
៣.៣.១ លក្ខខណ្ឌនៃបុគ្គលដែលត្រូវបានចោទប្រកាន់......................................... ២៦
៣.៣.២ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន......................................... ២៧
៣.៣.៣ រយៈពេល និងការពន្យាពេលឃុំខ្លួនបណ្ដោះអាសន្ន......................................... ២៧
**ជំពូកទី២**
**អំណាចសំខាន់ៗលើការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ**
**ផ្នែកទី១៖ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់**......................................... ២៩
**កថាខណ្ឌទី១៖ អង្គហេតុដែលមានសញ្ញាណធាតុផ្សំបទល្មើស**......................................... ២៩
១.១.១ អង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ......................................... ៣០
១.១.២ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ......................................... ៣១
១.១.៣ ការសួរចម្លើយ និងស្ដាប់ចម្លើយរបស់ភាគីពាក់ព័ន្ធ......................................... ៣២
**កថាខណ្ឌទី២៖ ការឆែកឆេរ និងចាប់យកវត្ថុតាង**......................................... ៣៣
១.២.១ ការធ្វើកោសលវិច័យ......................................... ៣៤
១.២.២ ដីកាសម្រេចចាត់តាំងអ្នកជំនាញ......................................... ៣៥
១.២.៣ លទ្ធផលនៃការធ្វើកោសលវិច័យ......................................... ៣៥
**ផ្នែកទី២៖ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស**......................................... ៣៦
**កថាខណ្ឌទី១៖ ការចាត់តាំងចៅក្រមផ្សេងឱ្យស៊ើបសួរជំនួស**......................................... ៣៦
២.១.១ ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច......................................... ៣៧
២.១.២ ការចាត់តាំងចៅក្រមសាលាដំបូងផ្សេងទៀត......................................... ៣៨
**កថាខណ្ឌទី២៖ ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យស៊ើបសួរជំនួស**......................................... ៣៨
២.២.១ ការចាត់តាំងមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌......................................... ៣៩
២.២.២ ប្រតិបត្តិការតាមការចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ......................................... ៣៩

## ជំពូកទី៣
## ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស**........ ៤១
**កថាខណ្ឌទី១៖ ដីកាបញ្ជូនពត៌មាន និងលិខិតជូនដំណឹងបញ្ចប់កិច្ចស្រាវជ្រាវ**........ ៤២
១.១.១ ដីកាបញ្ជូនពត៌មានទៅអយ្យការ........ ៤២
១.១.២.លិខិតជូនដំណឹងដល់ភាគីក្នុងរឿងក្ដី........ ៤២
១.១.៣ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ........ ៤៣
១.១.៤ ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ........ ៤៣
**កថាខណ្ឌទី២៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ**........ ៤៤
១.២.១ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ........ ៤៥
១.២.២ ការសម្រេចលើកលែងការចោទប្រកាន់........ ៤៥
១.២.៣ ការសម្រេចអំពីសិទ្ធិជនត្រូវចោទក្នុងឃុំ និងវត្ថុតាង........ ៤៦
**សេចក្ដីសន្និដ្ឋាន**........ ៤៧
**អនុសាសន៍**........ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង បច្ចុប្បន្នកំពុងប្រើប្រាស់នូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានប្រកាសដាក់ឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។ ដែលក្រមនីតិវិធីនេះបានកំណត់អំពីបែបបទ និងរបៀបរបប ដើម្បីធ្វើចំណាត់ការលើបណ្តឹងជាបទល្មើសព្រហ្មទណ្ឌណាមួយ។ នៅដែលពេលមានបណ្តឹងដាក់មកកាន់ស្ថាប័នតុលាការនៅសាលាជម្រះក្តីជាន់ទាប ដែលមានសាលាដំបូងរាជធានីខេត្ត ជាស្ថាប័នដំបូងដែលទទួលគ្រប់ពាក្យបណ្តឹងទាំងឡាយ ដែលជាជំហានក្នុងការដំណើរការបណ្តឹង និងទាមទារតុលាការឲ្យចេញសាលក្រម ទោះបីជាបណ្តឹងនោះត្រូវបានធ្វើឡើងដោយបុគ្គលដែលជាជនរងគ្រោះក្តីដោយតតិយជនក្តី ឬដោយមន្ត្រីនគរបាលយុត្តិធម៌ក្តី។ ដោយក្នុងនោះគេឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌនេះ បានបង្ហាញឲ្យយើងឃើញនូវដំណាក់កាលដាច់ដោយឡែកពីគ្នា គឺដំណាក់កាលស៊ើបអង្កេត ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលនៃការចោទប្រកាន់ធ្វើឡើងដោយព្រះរាជអាជ្ញា ដំណាក់កាលស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលចុងក្រោយ គឺដំណាក់កាលជំនុំជម្រះរហូតដល់ប្រកាសសាលក្រម។

ក្រោយពីបានពិនិត្យទៅលើដំណាក់ទាំងអស់នេះ បានបង្ហាញឲ្យយើងឃើញថា ដំណាក់កាលចៅក្រមស៊ើបសួរនេះជាដំណាក់កាលមួយដែលស្ថិតនៅចន្លោះនៃកិច្ចនីតិវិធីរវាងអយ្យការ និងដំណាក់កាលចៅក្រមជម្រះផងដែរ។ មុននឹងឈានដល់ការស៊ើបសួរនេះ លុះត្រាតែព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ឲ្យបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាកិច្ចនីតិវិធីសំខាន់ណាស់ដែលទាក់ទងទៅនឹងការស្វែងរកនូវភាពពិត នៃអង្គហេតុជារឿងព្រហ្មទណ្ឌ ដែលបង្ហាញអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសទៅលើបុគ្គល ដែលបានចោទប្រកាន់ដោយព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយក្នុងនោះផងដែរចៅក្រមស៊ើបសួរ មានកាតព្វកិច្ចស្វែងរកភស្តុតាងទាំងដោះបន្ទុកនិងដាក់បន្ទុក។ អំណាចរបស់ចៅក្រមស៊ើបសួរដែលបានផ្តល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ មានអំណាចក្នុងការស្រាវជ្រាវបទល្មើស និងបង្ហាញនូវការពិតនៃរឿងហេតុដែលទាក់ទិននឹងបទល្មើស ដែលតំណាងអយ្យការបានប្តឹងមកខ្លួន រួមទាំងវិធានមួយចំនួន ដែលផ្តល់ឲ្យចៅក្រមដោយភ្ជាប់ជាមួយនឹងមុខងាររបស់ចៅក្រមស៊ើបសួរផងដែរម្យ៉ាងទៀតក៏ផ្តល់សិទ្ធិអំណាចទៅចៅក្រមស៊ើបសួរ ក្នុងការឃុំខ្លួន ក្នុងករណីមានការសង្ស័យទៅលើជនត្រូវចោទផងដែរ ដោយអំណាចនេះផ្តល់ដោយវិធានការនិរន្តរាយ ក្នុងនោះរួមមាន ដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ។ ដោយសារយើងមិនអាចធ្វើការបកស្រាយទៅលើ ដំណាក់កាលទាំងអស់ ដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានទេដូច្នេះយើងសូមធ្វើការពន្យល់ និងបកស្រាយត្រឹមដំណាក់កាល នៃកិច្ចបើកការស៊ើបសួររបស់ចៅក្រមស៊ើប

សួរក្នុងទំហំនៃប្រធានបទខាងលើគឺ ៖ **វិធានការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ** យកមកធ្វើការបកស្រាយតែប៉ុណ្ណោះ។

ការស្រាវជ្រាវនេះ គឺមានគោលបំណងបង្ហាញឲ្យឃើញកាន់តែច្បាស់ និងកាន់តែស៊ីជម្រៅលើតួនាទី និងភារកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការប្រើប្រាស់វិធានការស្រាវជ្រាវបទល្មើសនេះ ដើម្បីស្វែងរកការពិតនៅក្នុងអង្គហេតុ។ ទាំងអស់នេះយើងនឹងធ្វើការបកស្រាយថា ចៅក្រមស៊ើបសួរមានវិធានការអ្វីខ្លះទៅលើការស្វែងរកនូវការពិតនោះ ដែលរួមមានការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ការឆែកឆេរ ការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ និងការស្ដាប់ទូរស័ព្ទជាអាទិ៍ ដែលសុទ្ធសឹងតែជាវិធានដែលបានកំណត់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងតឹងរឹងក្នុងការប្រើប្រាស់វិធានការនីមួយៗនេះផងដែរ។

ចំពោះសម្មទ្ធិផលនៃការស្រាវជ្រាវមួយនេះ នឹងរំពឹងថាអាចចងក្រងជាសៀវភៅ ក៏ដូចជាឯកសារទុកក្នុងបណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដើម្បីរក្សាទុកជាទស្សនៈទាន ជាគំនិតជូនដល់ប្អូនៗជំនាន់ក្រោយក្នុងការបំពេញនូវចំណេះដឹង ក្នុងនាមជាអ្នកកំពុងសិក្សាអនុវត្តទ្រឹស្តី ដែលអាចឲ្យយើងផ្សារភ្ជាប់គ្នា ទៅនឹងការអនុវត្តជាក់ស្តែងលើក្រមនីតិវិធីព្រហ្មទណ្ឌចំពោះផ្នែកចៅក្រមស៊ើបសួរ ទៅលើដំណាក់កាលនៃការដំណើរការរឿងក្តីនៅក្នុងសាលាដំបូងនីមួយៗ ជាជំនួយដល់ការស្វែងរកនូវការពិត ដែលនឹងមានរៀបរាប់នៅក្នុងសារណានេះ ចាប់តាំងពីកិច្ចដំបូងនៃការប្រើវិធានការស្រាវជ្រាវបទល្មើស រហូតដល់កិច្ចបញ្ចប់ការស្រាវជ្រាវ។ តើមុននឹងចាប់ផ្តើមចៅក្រមស៊ើបសួរត្រូវធ្វើកិច្ចណាខ្លះ? ហើយក្នុងអំឡុងពេលស្រាវជ្រាវបទល្មើសត្រូវធ្វើដូចម្តេចខ្លះ? បន្ទាប់មកត្រូវមានឯកសារណាខ្លះ? ហើយនីតិវិធីបន្តទៅណាទៀតរហូតដល់ពេលបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ។ ដើម្បីធ្វើការបកស្រាយទៅលើប្រធានបទ **"វិធានការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ"** នេះឲ្យកាន់តែស៊ីជម្រៅ និងការបន្ថែមឲ្យយល់កាន់តែទៀតនោះយើងបានធ្វើការបែងចែកជាបីជំពូករួមមាន៖

**ជំពូកទី១៖ មូលដ្ឋានគ្រឹះនៃការស៊ើបសួរ។**

**ជំពូកទី២៖ អំណាចសំខាន់ៗលើការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ។**

**ជំពូកទី៣៖ ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ។**

# ជំពូកទី១
# មូលដ្ឋានគ្រឹះនៃការស៊ើបសួរ

# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃការស៊ើបសួរ

ដើម្បីជាភាពងាយស្រួលដល់អ្នកសិក្សា ក៏ដូចជាធ្វើការស្វែងយល់ពីអំណាចរបស់ចៅក្រមដែលមានក្នុងកិច្ចនីតិវិធីស្រាវជ្រាវរកបទល្មើសនេះឱ្យកាន់តែច្បាស់ គឺគប្បីយល់ដឹងផងដែលថា ចៅក្រមដែលអាចបើកការស៊ើបសួរនេះបាន គាត់ជាចៅក្រមអសនៈដែលស្ថិតនៅក្នុងយុត្តាធិការស៊ើបសួរ។ បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានរំលេចយ៉ាងលម្អិតអំពីមូលដ្ឋានគ្រឹះរបស់ចៅក្រមស៊ើបសួរក្នុងកិច្ចស៊ើបសួរនេះផងដែរ។ ដោយសារតែក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាបទប្បញ្ញត្តិដែលចែងពីកិច្ចនីតិវិធី ដើម្បីធ្វើយ៉ាងណាឱ្យមានប្រសិទ្ធិភាពក្នុងការស្វែងរកបទល្មើស ឬភាពពិតក្នុងអង្គហេតុជារឿងព្រហ្មទណ្ឌ។ នៅពេលដែលមានអង្គហេតុមានសញ្ញាណបទល្មើសមួយត្រូវបានលេចឡើងនោះ ប្រាកដណាស់ គេសង្កេតឃើញតែងមានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ ការធ្វើការចោទប្រកាន់របស់អយ្យការ ក៏ដូចជាការស៊ើបសួរដែលច្បាប់តម្រូវដែលមានចៅក្រមស៊ើបសួរ ដើម្បីធ្វើកិច្ចស៊ើបសួរនេះដែលអមដោយមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ជាសេនាធិការ។ បើពិនិត្យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ បានឱ្យដឹងថាការស៊ើបសួរនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ គឺជាដំណាក់កាលមួយដែលស្ថិតនៅចន្លោះកណ្ដាលនៃដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ ហើយដំណាក់កាលស៊ើបសួរនេះ គឺបានផ្ដល់នូវសិទ្ធិដល់ចៅក្រមស៊ើបសួរយ៉ាងធំធេង និងឯករាជ្យចំពោះការស្វែងរកការពិតនៃអង្គហេតុនិងរកភស្តុតាង ទៅលើភាពសមហេតុផលទាំងដាក់បន្ទុក និងដោះបន្ទុកផងដែរ ។[1]

ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយ ដោយអាចធ្វើការចោទជាសំណួរបានថា៉តើទំនាក់ទំនងអ្វីខ្លះដែលធ្វើឱ្យចៅក្រមស៊ើបសួរ ត្រូវមានអំណាចក្នុងការបើកការស៊ើបសួរ? តាមរយៈការចោទសួរនេះ នឹងធ្វើការបកស្រាយក៏ដូចជាបង្ហាញជូននៅក្នុងផ្នែកខាងក្រោមនេះ។

## ផ្នែកទី១៖ ទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរ

ចំពោះទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរនេះដែរ នឹងបង្ហាញឱ្យកាន់តែច្បាស់ថា ចៅក្រមស៊ើបសួរជាតួអង្គសំខាន់ដែលមានភារៈកិច្ច ក៏ដូចជាសិទ្ធិអំណាចក្នុងកិច្ចដំណើរការបើកការស៊ើបសួរនេះ។ ត្រង់ចំណុចនេះមានន័យថា មានតែចៅក្រមដែលស្ថិតនៅក្នុងយុត្តាធិការស៊ើបសួរប៉ុណ្ណោះ ទើបមានសមត្ថកិច្ចក្នុងការដំណើរការ ក៏ដូចជាប្រតិបត្តិនូវនីតិវិធីស៊ើបសួរនេះបានដោយ អំណាចនេះត្រូវផ្ដល់ឱ្យចៅក្រមស៊ើបសួរដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ជារួមមកវិញអាចនិយាយបានថា ចៅក្រមស៊ើបសួរ និងការស៊ើបសួរនេះ គឺជាទំនាក់ទំនងមួយដែលមិនអាចកាត់ផ្ដាច់បាន។ ជាមូលដ្ឋានចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរតាមរយៈពីរ

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៧ ។

របៀប៖ គឺតាមការប្ដឹងសុំឱ្យបើកការស៊ើបសួរពីព្រះរាជអាជ្ញា **(ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)**[2] ប្រសិនបើបទល្មើសជាបទល្មើសឧក្រិដ្ឋ បទមជ្ឈឹម[3] និងម្យ៉ាងទៀត ចៅក្រមស៊ើបសួរក៏អាចបើកការស៊ើបសួរបានដែរ ក្រោយពីព្រះរាជអាជ្ញាដែលធានាផលប្រយោជន៍សង្គមធ្វើការតំកល់រឿងទុកឥតចាត់ការ[4] ក៏អាចធ្វើឱ្យភាគីខ្លួនឯងផ្ទាល់ ធ្វើការប្ដឹងសុំឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរបានផងដែរតាមរយៈការប្ដឹងសុំពីដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះបាន **(ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍នៅមុខចៅក្រមស៊ើបសួរ)**[5] គឺមានន័យថាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺអាចធ្វើបាននៅពេលដែលមានការបើកការស៊ើបសួរ ហើយម្យ៉ាងទៀតក៏អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានផងដែរនៅពេលដែលពុំទាន់មានចំណាត់ការបើកការស៊ើបសួរ ។

ចំពោះការបើកការស៊ើបសួរ គឺជាសមត្ថភាពផ្ដាច់មុខរបស់ចៅក្រមស៊ើបសួរ ហើយនៅក្នុងវិធានការនៃកិច្ចបើកការស៊ើបសួរនេះគឺជាអំណាចរបស់ចៅក្រមស៊ើបសួរ ដែលតែងតែមានការប៉ះពាល់ដល់ប្រយោជន៍មួយចំនួនទៅលើជនជាប់ចោទ ដែលជាការបំពានទៅលើសិទ្ធិបុគ្គលផងដែរ។ ការប៉ះពាល់ទាំងនេះ ដែលចេញមកពីវិធានការស៊ើបសួរដោយទាមទារចាំបាច់ឱ្យចៅក្រមស៊ើបសួរត្រូវប្រើប្រាស់នូវវិធានការនិរន្តរាយ(ជាអំណាចបង្ខំ) ឬការប្រើប្រាស់នូវវិធានការស្រាវជ្រាវបទល្មើស (ដែលប៉ះពាល់ទៅលើសិទ្ធិឯកជន)។ យ៉ាងណាមិញបើយើងក្រឡេកពិចារណាឡើងវិញយើងអាចចោទជាសំណួរបានថា តើចៅក្រមស៊ើបសួរជាអ្នកណា? ហើយបែបបទនៃការចាត់តាំងនៃការស៊ើបសួរមានដំណើរការយ៉ាងដូចម្ដេច? តើការបង្កើតឱ្យមានចៅក្រមស៊ើបសួរក្នុងគោលបំណងអ្វី?

### កថាខណ្ឌទី១៖ សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានស្ថាប័នតុលាការដែលបម្រើឱ្យពលរដ្ឋក្នុងការស្វែងរកយុត្តិធម៌ដែលមាននៅតាមមូលដ្ឋាន ដោយនៅគ្រប់រាជធានី-ខេត្ត ត្រូវបែងចែកជាសាលាដំបូងរាជធានី-ខេត្ត។ ចំពោះអ្នកដែលមានអំណាចក្នុងការសម្រេចសេចក្ដី ឬហៅថាជាចៅក្រមនោះ គឺត្រូវបានបែងចែកជាពីរដាច់ដោយឡែករួមមានចៅក្រមអសនៈ និងចៅក្រមអយ្យការ។ ក្នុងនោះផងដែរ ចំពោះចៅក្រមអសនៈក៏ត្រូវបានចែកមុខងារជាពីរ គឺតួអង្គដែលមានទាំងចៅក្រមជំនុំជម្រះ និងចៅក្រមស៊ើបសួរ។ ដោយតួអង្គទាំងពីរនេះស្ថិតនៅក្នុងស្ថាប័នយុត្តាធិការជំនុំជម្រះ និងយុត្តាធិការស៊ើបសួរ។ ដោយឡែកចៅក្រមអយ្យការវិញ គឺស្ថិតនៅក្នុងស្ថាប័នអយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត ដែលមានតួអង្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងជាអ្នកទាមទារឱ្យតុលាការអនុវត្តច្បាប់ និងតំណាងអយ្យការឱ្យផលប្រយោជន៍សាធារណៈក្នុងសង្គម ។

---

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៤ កថាខណ្ឌទី២។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២២។

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៤១។

[5]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៥ កថាខណ្ឌ១។

### ១.១.១ តើចៅក្រមស៊ើបសួរជាអ្នកណា?

ចៅក្រមស៊ើបសួរមានអត្ថន័យថា សំដៅលើចៅក្រមដែលមានតួនាទីស្វែងរកនូវភស្តុតាងដើម្បីសម្តែងឱ្យឃើញនូវភាពពិតនិងផ្តល់យុត្តិធម៌ទៅឱ្យគូភាគីដែលគាត់មានអំណាចបើកស៊ើបសួរ បានតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាឬតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ គឺជាចៅក្រមអសនៈដែលបំពេញមុខងារស៊ើបសួរនៅតាមបណ្តាលសាលាដំបូងដែលហៅថាមន្ទីរស៊ើបសួរ ឬនៅសាលាឧទ្ធរណ៍ជាតុលាការជាន់ខ្ពស់ ហៅថា សភាស៊ើបសួរ។[6]

នៅក្នុងសាលាដំបូងរាជធានី-ខេត្ត ចៅក្រមស៊ើបសួរ គឺចាំបាច់ត្រូវបានចាត់តាំងដោយប្រធានតុលាការ។ នៅក្នុងនោះការបំពេញភារកិច្ចក៏ដូចជាតួនាទីនៃការស៊ើបសួរគឺចៅក្រមស៊ើបសួរ អាចបំពេញមុខងារជំនួសគ្នាបាន ប្រសិនបើមានចៅក្រមណាម្នាក់មិនអាចបំពេញមុខងាររបស់ខ្លួនបានដោយសារមូលហេតុនៃជំងឺ ឬបញ្ហាផ្សេងៗទៀត ក្នុងនោះដែលការចាត់តាំងចៅក្រមជំនួសនេះមិនមែនមានតែចៅក្រមស៊ើបសួរទេ ដែលអាចបំពេញមុខងារជំនួសនេះគឺអាចចាត់តាំងចៅក្រមផ្សេងទៀតនោះតុលាការដដែលត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ ។[7]

### ១.១.២ គោលបំណងនៃការបង្កើតចៅក្រមស៊ើបសួរ

កាលយល់ដឹងពីគោលការណ៍ក្នុងការបង្កើតនេះជារឿងសំខាន់ ព្រោះប្រវត្តិសាស្ត្រ ធ្វើឱ្យយើងស្គាល់ខ្លួនឯងស្គាល់ពីព្រឹត្តិការណ៍ពីអតីតកាលក៏ដូចជាបុព្វបទសង្គមពីអតីតកាលទុកដល់បច្ចុប្បន្ន។ ចំពោះការបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះ ក៏មិនខុសគ្នាទៅនឹងការសិក្សាប្រវត្តិសាស្ត្រដែរចំពោះកម្ពុជាចាប់តាំងពីសម័យមុនរហូតដល់ពេលបច្ចុប្បន្ននេះតើប្រព័ន្ធស៊ើបសួរកើតឡើងដោយសារអ្វី? ជាចម្លើយ ប្រព័ន្ធចៅក្រមស៊ើបសួរកម្ពុជា គឺបង្កើតដោយសារតែកម្ពុជា ពីអតីតកាលស្ថិតក្រោមរបបអាណានិគមនិយមបារាំងដោយពេលនោះកម្ពុជាក៏បានទទួលឥទ្ធិពលទាំងស្រុង ពីក្រមពិភាក្សាព្រហ្មទណ្ឌបារាំងឆ្នាំ១៨០៨ និងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងក្រោយៗមកទៀត។ ហេតុនេះការឈ្វេងយល់ពីគោលគំនិតដើមនៃប្រព័ន្ធចៅក្រមកម្ពុជា គឺត្រូវពឹងពាក់អាស្រ័យជាសំខាន់ទៅលើវិធានគតិយុត្តរបស់បារាំង។ ក្រៅពីច្បាប់បារាំង នៅមានសេចក្តីសម្រេចរបស់សាលាក្តីខ្មែរក្រហមក៏ជាវិភាគទានមួយធំធេង ក្នុងការសិក្សាឈ្វេងយល់អំពីប្រព័ន្ធស៊ើបសួរ បើទោះបីសាលាក្តីកូនកាត់មួយនេះបាន

[6] ឯកសារជំនួយស្មារតីផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ កើត រិទ្ធ ។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៥១ ។

ធ្វើឱ្យប្រព័ន្ធចៅក្រមស៊ើបសួរមានដំណើរការក៏ដោយ ក៏នៅមាននីតិវិធីមួយចំនួនមិនត្រូវគន្លងខ្លះក៏ដោយសារវត្តមានច្បាប់អន្តរជាតិ និងអ្នកច្បាប់មកពីបណ្តាប្រទេសដែលមិនប្រើប្រាស់ប្រព័ន្ធចៅក្រមស៊ើបសួរ ។[8]

ដើម្បីជាគោលបំណងក្នុងការបង្កើតឱ្យមានចៅក្រមស៊ើបសួរនេះ គឺដើម្បីជួយសម្រួលទៅលើវិស័យយុត្តិធម៌ ក្នុងការស្វែងរកនូវភស្តុតាងទៅលើអង្គហេតុមួយដើម្បីបញ្ជាក់ពីភាពពិតឬជាការស្វែងរកពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសទៅលើបុគ្គលដែលបានប្រព្រឹត្តពិតប្រាកដ ដើម្បីជៀសវាងការមានការសង្ស័យការខ្វះខាតទៅលើបន្ទុកនៃភស្តុតាងដែលបានបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌មក មុននឹងបញ្ជូនទៅយុត្តាធិការជំនុំជម្រះ។ ម្យ៉ាងវិញទៀតក្នុងការស្វែងរកការពិតនេះចៅក្រមស៊ើបសួរត្រូវមានករណីកិច្ចស៊ើបសួរ ទាំងភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុក។ វត្តមានរបស់ចៅក្រមស៊ើបសួរពិតជាមានសារៈសំខាន់ណាស់ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដែលច្បាប់បានកំណត់ត្រូវបានធ្វើការបើកការស៊ើបសួរ[9] គឺចៅក្រមស៊ើបសួរបំពេញកិច្ចនៃការបើកការស៊ើបសួរ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ចៅក្រមស៊ើបសួរក្នុងពេលដំណើរការរឿងក្តីរបស់ខ្លួនគឺត្រូវតែមានភាពយុត្តិធម៌ និងឈរនៅ កណ្តាលគ្រប់ភាគីដែលពាក់ព័ន្ធនៃរឿងក្តីព្រហ្មទណ្ឌ។ ម្យ៉ាងទៀតស្របនឹងគោលបំណងដែលបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះដែរ គឺសម្រាប់ស្វែងរកភស្តុតាងមកបញ្ជាក់ថាការប្តឹងសុំបើកការស៊ើបសួរដែលតំណាងអយ្យការបានចោទប្រកាន់នោះ វាគឺជាបទល្មើសព្រហ្មទណ្ឌ ឬមិនមែនជាបទល្មើសព្រហ្មទណ្ឌ។

**កថាខណ្ឌទី២៖ ភាពដែលអាចបំពេញមុខការបាន**

បន្ទាប់ពីបានដឹងពីសញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួររួចមក គឺគប្បីដឹងផងដែរពីមុខការរបស់គាត់វិញម្តង។ នៅក្នុងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានកំណត់អំពីមុខការរបស់ចៅក្រមស៊ើបសួរ ក្នុងការបំពេញភារកិច្ចស៊ើបសួរនេះដែរ គឺចៅក្រមស៊ើបសួរអាចបំពេញមុខការរបស់ខ្លួនដោយសន្ទត់ទៅលើសមត្ថកិច្ចដែលខ្លួនមាន (សមត្ថកិច្ចដែនដី និងសមត្ថកិច្ចសម្ភារៈ)។ មួយវិញទៀតចៅក្រមដែលមានតួនាទីក្នុងការស៊ើបសួរហើយនោះ គឺមិនអាចចាត់តាំងជាចៅក្រមជំនុំជម្រះទៀតឡើយ (វិសមិតភាពមុខងារ) ។

**១.២.១ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនេះ ត្រូវបានបែងចែកជាពីរគឺ៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមដែនដី និងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមសម្ភារៈ ។

---

[8] ចក សម្បត្តិ "ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ៖ ខ្លឹមសារនៃប្រព័ន្ធចៅក្រមស៊ើបសួរ", ការផ្សព្វផ្សាយរបស់សមាគមន៍សាលាត្រាជូ ខែវិច្ឆិកា ឆ្នាំ២០១៧,<http://salatraju.com/post/332>, ២ ខែមិថុនា ឆ្នាំ២០១៩។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២២។

**ក. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមដែនដីមាន៖**

ចៅក្រមដែលមានសមត្ថកិច្ចគឺ[10]៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។

វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ការសម្រេចនេះបិទផ្លូវតវ៉ា។ បទប្បញ្ញត្តិនេះចែងអំពីសមត្ថកិច្ចដែលចៅក្រមស៊ើបសួរមានសមត្ថកិច្ចហើយនឹងកំណត់អំពីបញ្ហាក្នុងការដោះស្រាយ នៅពេលដែលទំនាស់រវាងចៅក្រមស៊ើបសួរច្រើនទៅលើបណ្តឹងតែមួយក៏ដូចជាវិវាទចំពោះសមត្ថកិច្ចសាលាដំបូងជាន់គ្នាផងដែរ។ បញ្ហាត្រង់ថា **"តើចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចស្រាវជ្រាវបទល្មើសបានទេ ប្រសិនបើជនត្រូវចោទមិនមានវត្តមានក្នុងដែនដីរបស់ខ្លួន?**

មិនតែប៉ុណ្ណោះក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់នូវសិទ្ធិពន្លាតសមត្ថកិច្ចជូនទៅចៅក្រមស៊ើបសួរបន្ថែមទៀត។ ចំពោះសមត្ថកិច្ចនេះដែលចៅក្រមស៊ើបសួរ ក៏អាចប្រើប្រាស់អំណាចទៅលើសមត្ថកិច្ចដែនដីដទៃទៀតបានដែរប្រសិនបើជនត្រូវចោទមិនមានវត្តមាននៅលើដែនដីរបស់ខ្លួន ចៅក្រមស៊ើបសួរក៏អាចត្រូវបានប្រើប្រាស់អំណាចនេះ ដោយចេញដីកាចាត់ឱ្យស៊ើបសួរជំនួសចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺត្រូវបានបែងចែកជាពីរ គឺដីកាចាត់ឱ្យស៊ើបសួរជំនួសចាត់ឱ្យចៅក្រមស៊ើបសួរផ្សេង និងដីកាចាត់ឱ្យស៊ើបសួរដែលចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។

**ខ. សមត្ថកិច្ចតាមសាច់រឿងរបស់ចៅក្រមស៊ើបសួរ**

ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំទទួលស្គាល់ថា តុលាការទាំងឡាយអាចប្តឹងមកខ្លួន ដោយខ្លួនឯងផ្ទាល់ដើម្បីស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយ បើទោះជាតុលាការទាំងនោះបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសក៏ដោយ។ ដូច្នេះចៅក្រមស៊ើបសួរអាចស៊ើបសួរបាន លុះត្រាតែត្រូវបានប្តឹងពីរឿងមួយដោយព្រះរាជអាជ្ញា ឬដោយជនរងគ្រោះ ដែលអាចបើកការស៊ើបសួរ ដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ។

ចំពោះសមត្ថកិច្ចនេះដែល គឺសំដៅទៅលើការទទួលបាននូវភារៈកិច្ចក៏ដូចជាមុខការដែលទទួលបានដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលប្តឹងសុំដោយព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរអាចទទួលបណ្តឹង

---

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៣ ។

អំពីអង្គហេតុដែលបញ្ជូនមក ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងរបស់ព្រះរាជអាជ្ញា។[11] ចៅក្រមស៊ើបសួរត្រូវស៊ើបសួរអំពីអង្គហេតុនោះប៉ុណ្ណោះ។ បើពិនិត្យទៅលើមាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺបង្ហាញឱ្យឃើញកាន់តែច្បាស់ថាចៅ ក្រមស៊ើបសួរដោយផ្អែកទៅតាមអង្គហេតុជាសម្ភារៈពិតៗ ដែលបានប្តឹងសុំពីព្រះរាជអាជ្ញាចង្អុលនូវឈ្មោះបទល្មើសនិងអំពីឈ្មោះបុគ្គលដែលតម្រូវឱ្យស៊ើបសួរ។ ក្នុងន័យនេះក៏ចង់បញ្ជាក់ថាចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរតាមអ្វីដែលកំណត់ក្នុងដីកានេះតែប៉ុណ្ណោះ ។

### ១.២.២ វិសមិតភាពមុខងារ

ដោយស្ថិតក្រោមឈ្មោះរួមជាចៅក្រម គឺគេប្រមូលផ្តុំជនទាំងអស់ ដែលមានលក្ខន្តិកៈជាចៅក្រមដែលបំពេញមុខងារផ្សេងៗគ្នាក្នុងប្រព័ន្ធយុត្តាធិការ។ ភាពខុសគ្នានូវតួនាទីទាំងនេះនាំឱ្យមានបុព្វសិទ្ធិ និងកាតព្វកិច្ចនៅពេលបំពេញមុខងាររបស់ខ្លួន។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬចៅក្រមស៊ើបសួរលើរឿងណាមួយមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើមិនដូច្នេះទេសាលក្រមនឹងត្រូវចាត់ទុកជាមោឃៈ។[12] ក្នុងន័យនេះដែរ ព្រះរាជអាជ្ញា ជាមជ្ឈដ្ឋានកណ្តាលក្នុងការទទួលនៅរាល់គ្រប់ព័ត៌មានទាំងអស់ តាមគ្រប់មធ្យោបាយដែលបង្កើតបានជាបទល្មើសព្រហ្មទណ្ឌទោះបីជាព្រះរាជអាជ្ញាពុំមានសិទ្ធអំណាចក្នុងការស៊ើបសួរក៏ដោយ ប៉ុន្តែក្នុងនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ព្រះរាជអាជ្ញានូវសិទ្ធិក្នុងការស៊ើបអង្កេត ដោយមានជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ក្នុងស្មារតីនៃមាត្រានេះដែរ គឺចង់បង្ហាញថាប្រសិនបើ ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿង ឬចាត់ការលើសំណុំរឿងហើយជាការស្វែងរកនូវភស្តុតាងចំពោះព្រះរាជអាជ្ញា គឺស្វែងរកតែភស្តុតាងដាក់បន្ទុក ខុសពីចៅក្រមស៊ើបសួរ គឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដូចនេះហើយប្រសិនជាព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទៅធ្វើជាចៅក្រមជំនុំជម្រះទៀតនោះច្បាស់ណាស់ប្រាកដជាមានបុរេនិច្ឆ័យ ដែលធ្វើឱ្យមានភាពអយុត្តិធម៌ទៅលើជនល្មើស ហើយសាលក្រមនោះ គឺចាត់ទុកជាគ្មានបានការគឺគ្មានអានុភាពទៅតាមផ្លូវច្បាប់ឡើយ។ ដូច្នេះដើម្បីជាការធានានូវសេចក្តីសម្រេចប្រកបដោយភាពយុត្តិធម៌ និងការស្វែងរកការពិត កាន់តែមានភាពសុក្រឹត្យភាព។

## កថាខណ្ឌទី៣៖ ទម្រង់ការដាច់ខាតដែលត្រូវគោរព

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលចេញដោយព្រះរាជអាជ្ញាទៅឱ្យចៅក្រមស៊ើបសួរ មិនចងកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរទេ។ ទោះបីជាចៅក្រមស៊ើបសួរទទួលបានមុខការដាច់ខាតនៅពេលដែលមានដីកា

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៥ ។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៨ ។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែបំពេញ និងគោរពនូវទម្រង់ការមួយចំនួនដែលមានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាគោលការណ៍មួយសម្រាប់ដំណើរការស៊ើបសួរឱ្យមានភាពយុត្តិធម៌ និងជៀសវាងនូវការបំពេញនូវកាតព្វកិច្ចតាមចិត្តរបស់ខ្លួន។ ក្នុងនោះដែលយើងឃើញថាចៅក្រមស៊ើបសួរត្រូវគោរពនូវ ការសម្ងាត់នៃការស៊ើបសួរ និងការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខណ៍អក្សរផងដែរ។

### ១.៣.១ ការសម្ងាត់នៃការស៊ើបសួរ

ដូចដែលបានរៀបរាប់នូវមុននេះហើយថា ការត្រូវតែគោរពនូវគោលការណ៍មួយចំនួនផងដែរ ក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងអំពីគោលការណ៍សម្ងាត់នៃការស៊ើបសួរ។ បុគ្គលដែលចូលរួមក្នុងការស៊ើបសួរជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។[13] ប៉ុន្តែការគោរពនូវការសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើប្រាស់សិទ្ធិនៃការការពារខ្លួនឡើយ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈកាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ការបំពាននៃការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[14] បើពិនិត្យទៅលើមាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺបង្ហាញឱ្យឃើញនូវស្មារតីនៃមាត្រានេះថា ការបើកការស៊ើបសួរជាសម្ងាត់ គឺវាអាចផ្តល់នូវភាពងាយស្រួលក្នុងការស្វែងរកតម្រុយនៃភស្តុតាង ក៏ដូចជាអ្នកដែលបានចូលរួមប្រព្រឹត្តបទល្មើសផ្សេងទៀតផង។ ក្នុងបញ្ញត្តិនៃមាត្រានេះទៀតសោតក៏បានដាក់កាតព្វកិច្ចដែលមានសិទ្ធិក្នុងការចូលរួមការស៊ើបសួរ ដោយតម្រូវឱ្យបុគ្គលទាំងនោះរក្សានូវការសម្ងាត់នៅពេលកំពុងស៊ើបសួរ គឺក្នុងគោលបំណងដើម្បីដំណើរការប្រព្រឹត្តទៅជៀសវាងការលេចលឺទៅខាងក្រៅ ដែលអាចបណ្តាលឱ្យជនល្មើសដឹងខ្លួនជាមុន ឬញុះញង់ឱ្យជនល្មើសនោះលុបបំបាត់នូវភស្តុតាងដែលពាក់ព័ន្ធ ឬក៏អាចឱ្យជនល្មើសដឹងអំពីសាក្សីហើយអាចទៅសម្លុតគម្រាមសាក្សីដើម្បីកុំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនដែលអាចធ្វើឱ្យការស៊ើបសួរពិបាកក្នុងការស្វែងរកការពិត។ ប៉ុន្តែការរក្សានូវការសម្ងាត់នេះ ក៏បង្កើតឱ្យមានអញ្ញត្រកម្មដែរ គឺថាប្រសិនជាមានឧបសគ្គដល់ការប្រើប្រាស់សិទ្ធិរបស់ខ្លួន គឺបុគ្គលដែរមានសិទ្ធិចូលរួមក្នុងការស៊ើបសួរទាំងនេះអាចមិនរក្សាការសម្ងាត់នេះបានហើយក៏មិនអាចបង្ខំឱ្យទទួលនូវទណ្ឌកម្ម ឬបទល្មើសដែលអាចនឹងផ្តន្ទាទោសផងដែរ ប្រសិនជាការរក្សាការសម្ងាត់នេះអាចនឹងប៉ះពាល់ ឬអាចមានគ្រោះថ្នាក់ដល់ខ្លួន។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៨៣។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២១។

### ១.៣.២ ការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខណ៍អក្សរ

ជាគោលការណ៍រាល់កិច្ចនីតិវិធីស៊ើបសួរ ត្រូវធ្វើជាលាយលក្ខណ៍អក្សរហេតុដូចនេះហើយចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីអមជានិច្ច។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជី មិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរទេ។[15] វត្តមានរបស់ក្រឡាបញ្ជីគឺ ខានមិនបានចំពោះគ្រប់កិច្ចស៊ើបសួរទាំងអស់។ វត្តមាននេះត្រូវចុះក្នុងលិខិតដែលត្រូវមានចុះហត្ថលេខារបស់ក្រឡាបញ្ជី។ សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីត្រូវចម្លងលិខិតនីមួយៗនៃសំណុំរឿង តាមលទ្ធភាពដែលអាចធ្វើទៅបាន។ លិខិតចម្លងនេះត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។[16] ដូចនេះមានន័យថាទាក់ទងនឹងការធ្វើកំណត់ហេតុនេះ គឺគេផ្តោតសំខាន់ទៅលើក្រឡាបញ្ជី ដែលអាចនិយាយបានថាជាកិច្ចការក្រឡាបញ្ជីត្រូវតែធ្វើដោយខានពុំបាន។

## ផ្នែកទី២៖ ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើងដឹងហើយថា នៅពេលដែលមានអង្គហេតុជាបទល្មើសណាមួយ យើងសង្កេតឃើញថាគឺមែងមានភាគីពីរ ដោយភាគីម្ខាងជាជនរងគ្រោះ និងភាគីម្ខាងទៀតជាជនបង្ក ឬជនល្មើសជាដើម។ ចំពោះអំពើដែលមានការបំពារបំពាន ឬបង្កឱ្យកើតឡើងនូវព្យសនកម្ម និងផលវិបាកដែលបង្កឡើងដោយបទល្មើសព្រហ្មទណ្ឌ។ ដូចនេះសិទ្ធិរបស់ជនរងគ្រោះត្រូវបានធានាដោយច្បាប់។ នៅក្នុងន័យនេះក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ បានផ្តល់នូវសិទ្ធិឱ្យជនរងគ្រោះក្នុងការធ្វើបណ្តឹងទាំងឡាយដែលចាំបាច់ដើម្បីការពារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ក្នុងនោះដែររួមមានបណ្តឹងទាមទារសំណងនិងបណ្តឹងបរិហារចំពោះបទល្មើស។ ដោយតាមរយៈការទាមទារនេះ ចាំបាច់ត្រូវធ្វើឡើងតាមរយៈនីតិវិធីមួយដែលភាគីនៃបណ្តឹងដែលត្រូវគោរពតាមគឺនីតិវិធីនៃការដាក់ពាក្យបណ្តឹង ដើម្បីអាចដាក់ពាក្យប្តឹងនេះបាន ភាគីនៃបណ្តឹងត្រូវធ្វើឡើងជាទម្រង់ដែលច្បាប់កំណត់ក៏ដូចជាបែបបទនៃលិខិតជាពាក្យប្តឹងនោះ។ មួយវិញដើម្បីអាចឱ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរបាននោះ ក៏មានចំណែកកើតចេញពីនាយហានានុក្រម ដែលមានអំណាចក្នុងការធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បាន ហើយក្នុងករណីនេះក៏អាចឱ្យ ព្រះរាជអាជ្ញាបើកការស៊ើបសួរផងដែរ គឺតាមរយៈការស្នើសុំឱ្យស៊ើបសួរដោយយុត្តាធិការព្រហ្មទណ្ឌបានផងដែរ។ មួយវិញទៀតព្រះរាជអាជ្ញាជាអ្នកតំណាងឱ្យផលប្រយោជន៍ សាធារណៈ និងជាអ្នកទាមទារឱ្យតុលាការអនុវត្តតាមច្បាប់ចំពោះអង្គហេតុជាបទល្មើសព្រហ្មទណ្ឌ ក្នុងករណីនេះ មិនចាំបាច់ទាល់តែមានការដាក់ពាក្យសុំដោយភាគី ដែលជាជនរងគ្រោះប្តឹងមក ឬក៏អ្នកដែលយល់ថាខ្លួនបាត់បង់នូវប្រយោជន៍ដែលកើតចេញពីអំពីនោះទេ គឺព្រះរាជអាជ្ញាមានកាតព្វកិច្ចចម្បងក្នុងរឿងនេះ ក្នុងការផ្តើមធ្វើការចោទ

---

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៨។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៩,កថាខណ្ឌទី១ និងទី២ ។

ប្រកាន់។ យ៉ាងណាមិញសំណុំរឿងនីតិវិធី គឺត្រូវទាមទារដោយការស៊ើបអង្កេតដែលមានភាពឆាប់រហ័សនិងមានប្រសិទ្ធិភាព។ ភាគីនៃនីតិវិធីនេះរួមមានដូចជាព្រះរាជអាជ្ញា ដែលមានតួនាទីចម្បង និងជនរងគ្រោះដែលមានតួនាទីបន្ទាប់បន្សំត្រូវសម្រេចថា និងធ្វើដូចម្តេចបន្តទៅមុខទៀតដោយយោងទៅលើភាពជាក់លាក់ និងស្ថានភាពភស្តុតាងដែលប្រមូលបាន។ ត្រង់ចំណុចនេះហើយជាភាពចាំបាច់ដែលភាគីរងគ្រោះ ឬភាគីបណ្តឹងត្រូវធ្វើពាក្យបណ្តឹងរបស់ខ្លួនឱ្យមានភាពត្រឹមត្រូវជៀសវាងការលើកចោលនូវពាក្យបណ្តឹងរបស់តុលាការនេះ ។

**កថាខណ្ឌទី១៖ ការដាក់ពាក្យប្តឹង**

ចំពោះការដាក់ពាក្យប្តឹងនេះ គឺត្រូវធ្វើតាមទម្រង់ជាបណ្តឹងបរិហារ និងទម្រង់ជាពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យ៉ាងណាមិញ បណ្តឹងទាំងពីរនេះ ជាប្រភេទបណ្តឹងដែលអាចធ្វើឱ្យបណ្តឹងអាជ្ញាមានចលនា។ នៅក្នុងករណីមានការតំកល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា ភ្លាមនោះគេអាចផ្តល់ជម្រើសដល់ជនរងគ្រោះក្នុងការដាក់ពាក្យប្តឹងដូចបានជំរាបជូនខាងលើថា នៅពេលមានការមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញានោះ ជនរងគ្រោះខ្លួនឯងអាចធ្វើបណ្តឹងតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរដែលច្បាប់បានតម្រូវ ហើយក៏មានការធ្វើការបកស្រាយជូនដូចខាងក្រោម ។

**២.១.១ បណ្តឹងបរិហារ**

បើមើលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលទាក់ទងទៅនឹងបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏មានចែងដែលថាមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកទទួលពាក្យបណ្តឹងទាមទារ និងបណ្តឹងបរិហារ។[17] ដោយបណ្តឹងទាមទារនេះជនរងគ្រោះអាចដាក់ពាក្យបណ្តឹង ដោយមានការទាមទារសំណងរដ្ឋប្បវេណីបានដោយផ្អែកលើព្យសនកម្មដែលខ្លួនទទួលរង។ ចំណែកឯបណ្តឹងបរិហារ គឺសំដៅទៅលើបណ្តឹងវែកមុខបទល្មើសដែលមានបំណងបង្ហាញ ឬបកអាក្រាតនូវបទល្មើស ដើម្បីឱ្យសមត្ថកិច្ចធ្វើការត្រួតពិនិត្យ និងស្វែងរកភស្តុតាងនៅក្នុងបទល្មើស ដោយចាប់ជនល្មើសបានប្រព្រឹត្តយកមកផ្តន្ទាទោសតាមច្បាប់។ **ឧទាហរណ៍៖** ក្នុងករណីមានចោរឆក់ ឬលួចទ្រព្យសម្បត្តិជាដើម។ បណ្តឹងបរិហារនេះអាចធ្វើឡើងតាមរយៈភាគីរងគ្រោះផ្ទាល់ និងតតិយជន ឬដោយមន្ត្រីសាធារណៈដែលគាត់បានឃើញ ឬបានដឹងពីបទល្មើសនោះ។ **ឧទាហរណ៍៖** យើងដើរទៅកន្លែងមួយស្រាប់តែឃើញមនុស្សស្លាប់ហើយក៏មិនដឹងថានរណាជាអ្នកសម្លាប់ជនរងគ្រោះនោះដែរ ប៉ុន្តែជាគោលការណ៍យើងដែលជាអ្នកឃើញមនុស្សស្លាប់នោះ ក៏មានសិទ្ធិប្តឹងទៅកាន់នគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាបានដូចគ្នាដែរ ដើម្បីឱ្យមានការចុះស៊ើបអង្កេត។ បណ្តឹងនេះគ្រាន់ជាសេចក្តីរាយការណ៍អំពីបទល្មើសតែប៉ុណ្ណោះ ពីព្រោះអ្នកប្តឹងនោះមិនមែនជាម្ចាស់បណ្តឹងទេ រីឯម្ចាស់បណ្តឹង គឺព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា៧១។

ចំពោះបណ្តឹងបរិហារនេះផងដែរ នៅពេលដែលដាក់ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌រួចមក មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតដើម្បីប្រមូលភស្តុតាងបញ្ជូនទៅកាន់អយ្យការ ឬតាមរយៈពាក្យប្តឹងបរិហារផ្ទាល់មកកាន់អយ្យការ ដោយមានគោលបំណងដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការសម្រេច ថាតើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់ទុកតាមរយៈការថ្លឹងថ្លែងរបស់ខ្លួន។[18] ត្រង់ចំណុចនេះ មិនមែនសុទ្ធតែបណ្តឹងមកកាន់ព្រះរាជអាជ្ញាសុទ្ធតែព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬបណ្តឹងអាជ្ញាមានចេតនានោះទេ។ ពាក្យថាបណ្តឹងអាជ្ញា គឺជាបណ្តឹងពិនិត្យអំពីបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះដោយដាក់ពន្ធនាគារមានកាលកំណត់ ឬដាក់ពន្ធនាគារអស់មួយជីវិត ចំពោះជនដែលប្រព្រឹត្តអំពើដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងវិធានច្បាប់ព្រហ្មទណ្ឌជាដើម។ បច្ចុប្បន្នគេឃើញថា ព្រះរាជអាជ្ញា ជាបណ្តឹងប្រឆាំងនឹងជនល្មើសដែលប្រព្រឹត្តបទល្មើសណាមួយ ដោយទាមទារឱ្យតុលាការធ្វើការផ្តន្ទាទោសជននោះ។ បណ្តឹងអាជ្ញានេះដែរ ត្រូវបានអនុវត្តដោយអយ្យការក្នុងនាមជាអ្នកការពារផលប្រយោជន៍ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញាមានន័យថា ព្រះរាជអាជ្ញា ផ្តើមធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ (អាចជាបទឧក្រិដ្ឋ មជ្ឈិម ឬលហុ) និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

បណ្តឹងអាជ្ញា មានអានុភាពលើគ្រប់បុគ្គលទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពទៀតឡើយ។[19] ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌអាចជានីតិបុគ្គល ថ្វីត្បិតតែជាបុគ្គលសិប្បនិម្មិត ដែលបង្កើតឡើងដោយច្បាប់ក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដែរ នីតិបុគ្គលនោះអាចទទួលរងនូវការផាកពិន័យជាប្រាក់ ឬទទួលរងនូវទោសបន្ថែមណាមួយដូចជាការរំលាយនីតិបុគ្គលជាដើម។ នៅក្នុងការចោទប្រកាន់នេះ ជាតួនាទីរបស់អយ្យការតាមរយៈបណ្តឹងអាជ្ញា។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[20] ករណីនេះព្រះរាជអាជ្ញាមានភារកិច្ចដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[21] ក្រៅពីអំណាចដឹកនាំសម្របសម្រួលសកម្មភាពនគរបាលយុត្តិធម៌អំណាចបើកការស៊ើបអង្កេតព្រះរាជអាជ្ញាផងដែល មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យបណ្តឹងអាជ្ញាមានចលនា មានន័យថាតាមរយៈការចោទប្រកាន់អំពីបទល្មើសណាមួយ។ ទាក់ទងនឹងការចោទប្រកាន់នេះដែរ គឺក្រៅពីទទួលបានបណ្តឹងទាមទារឬបណ្តឹង

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤០។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣។

[20] មាត្រា១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៧,កថាខណ្ឌទី១។

បរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ប្រសិនបើយល់ថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់នៅឡើយ។ អយ្យការអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្វែងរកភស្តុតាងបន្ថែម ឬបើកការស៊ើបអង្កេតបឋមបាន។[22] ចំពោះពាក្យប្តឹងនេះដែរ អាចធ្វើឡើងតាមរយៈជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌដូចជា មន្ត្រីគយជាដើម ឬតតិយជនដែលដឹងពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។ មុននឹងធ្វើសេចក្តីសម្រេច ព្រះរាជអាជ្ញាក៏ត្រូវធ្វើការ ពិនិត្យទៅលើកត្តាជាច្រើនដូចជា៖[23]

- តើអំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ហើយឬនៅ? ហើយត្រូវវាយតម្លៃកំណត់បទល្មើសឱ្យសមស្របទៅនិងអំពើដែលបានប្រព្រឹត្ត ។ **ឧទាហរណ៍៖** ជនម្នាក់បានឆក់យកទូរស័ព្ទអ្នកដទៃ ត្រង់ចំណុចនេះនឹងត្រូវវាយតម្លៃអំពើប្រព្រឹត្តនោះថាជាបទលួច ។
- ពិនិត្យថាតើជនសង្ស័យមានអភ័យឯកសិទ្ធិឬទេ? **ឧទាហរណ៍៖** អភ័យឯកសិទ្ធិគ្រួសារ[24] ឬអភ័យឯកសិទ្ធិការទូត ។
- តើជនសសង្ស័យត្រូវចោទប្រកាន់ក្នុងនាមជាអ្វីឱ្យសមស្របទៅនឹងអំពើដែលបានប្រព្រឹត្តរបស់ជននោះ? **ឧទាហរណ៍៖** ចោទប្រកាន់ក្នុងនាមជាចារី សហចារី ឬអ្នកសមគំនិត ឬអ្នកផ្តើមគំនិតជាដើម ។
- ត្រូវពិនិត្យថាស្ថិតក្នុងដែនសមត្ថកិច្ចដែរឬទេ? ព្រះរាជអាជ្ញានៃទីកន្លែងប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** បទល្មើសកើតឡើងនៅខេត្តសៀមរាប នោះសមត្ថកិច្ចរបស់អយ្យការសាលាដំបូងខេត្តសៀមរាប ។
- ព្រះរាជអាជ្ញានៃទីលំនៅជនសង្ស័យបានប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទល្មើសនៅរាជធានីភ្នំពេញ ហើយត្រូវបានគេដឹងថាជននោះមានទីលំនៅស្ថិតក្នុងខេត្តស្វាយរៀង ហើយជនរងគ្រោះអាចដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្វាយរៀង ។
- ព្រះរាជអាជ្ញានៅទីកន្លែងចាប់ខ្លួនដែលត្រូវបានសង្ស័យបានប្រព្រឹត្តបទល្មើស ។ **ឧទាហរណ៍៖** ជនល្មើសបានបាញ់ជនរងគ្រោះនៅខេត្តកំពង់ស្ពឺ ហើយបានរត់មកលាក់ខ្លួននៅភ្នំពេញ បន្ទាប់មកក៏ត្រូវចាប់ខ្លួន។ ក្នុងករណីនេះ អយ្យការអមសាលាដំបូងភ្នំពេញមានសមត្ថកិច្ច ។
- ត្រូវពិនិត្យថាតើក្នុងករណីនេះ ត្រូវមានបណ្តឹងរបស់ជនរងគ្រោះដែរឬទេ? **ឧទាហរណ៍៖** ដើម្បីអាចចោទប្រកាន់ពីបទបរិហារកេរ្តិ៍ជាសាធារណៈបាន ចាំបាច់ត្រូវមានបណ្តឹងពីជនរងគ្រោះ ។[25]

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤០,កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[23] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត,*មេរៀននីតិវិធីព្រហ្មទណ្ឌ*,២០១៧,២៧។

[24] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១២០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣៥៥។

[25] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១២០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣០៩។

- ត្រូវពិនិត្យថាតើបណ្ដឹងអាជ្ញាត្រូវរលត់ហើយឬនៅ? ក្រោយពីពិនិត្យមូលហេតុទាំងអស់នេះហើយ ទើបព្រះរាជអាជ្ញាមានមូលដ្ឋានក្នុងការធ្វើបណ្ដឹងអាជ្ញានេះ ។

ដោយបានដឹងហើយថា ការដែលអាចបើកការស៊ើបសួរបាន គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញាមានមធ្យោបាយច្រើនដើម្បីដាក់បណ្ដឹងអាជ្ញា។ ការជ្រើសរើសមធ្យោបាយទាំងនេះអាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងនីតិវិធី ដែលរួចរាល់អាចបញ្ជូនទៅតុលាការជំនុំជម្រះឬក៏តម្រូវឱ្យមានការបើកការស៊ើបសួរជាទូលំទូលាយផងដែរ។ ភាពចាំបាច់នេះ ជាកាតព្វកិច្ចដោយអាស្រ័យទៅលើប្រភេទបទល្មើសដែលពាក់ព័ន្ធ។ ទោះជាបណ្ដឹងអាជ្ញានេះ អាចប្ដឹងទៅយុត្តាធិការជំនុំជម្រះក៏ដោយការចោទប្រកាន់អាចធ្វើទៅបានតាមរយៈជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ក្នុងនោះរួមមាន៖

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម ។[26]

ជាជម្រើសនៃការចោទប្រកាន់នេះ តាមរយៈការបើកការស៊ើបសួរដែលកំណត់ប្រភេទបទល្មើស រួមមានបទឧក្រិដ្ឋ បទមជ្ឈិមដែលច្បាប់តម្រូវ។ ការបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវប្ដឹងទៅចៅក្រមស៊ើបសួរដែលមានអំណាចក្នុងការបើកការស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។ ដោយនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះរួមមាន៖

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកានេះត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។ ទម្រង់នេះមានលក្ខណៈសំខាន់ដែលត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវចាត់ទុកជាមោឃៈ ។[27]

ចំពោះភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដែលត្រូវប្ដឹងទៅយុត្តាធិការស៊ើបសួរនោះ គឺស្ថិតក្នុងការវាយតម្លៃពីស្ថានភាពសំណុំរឿងនៃនីតិវិធីផងដែរ ថាអាចឱ្យព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ក្នុងការបើកការស្រាវជ្រាវ

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៣។
[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៤។

បទល្មើសដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឱ្យអនុវត្តបណ្តឹងអាជ្ញាដោយសមហេតុផល។ ក្នុងទស្សនៈវិស័យនេះព្រះរាជអាជ្ញា មានផ្លូវពីរ៖ ទី១ បន្តការស៊ើបអង្កេត និងទី២ តាមរយៈការធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ។ ក្នុងករណីដែលការស៊ើបសួរ ក៏មានលក្ខណៈមិនដាច់ខាត ដូចក្នុងករណីបទមជ្ឈឹម ឬបទលហុ ដោយព្រះរាជអាជ្ញាចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរអាស្រ័យទៅលើការចម្រើនទៅមុខនៃសំណុំរឿងនីតិវិធី។ ជាទូទៅ ព្រះរាជអាជ្ញាអាចចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ នៅពេលណាដែលបុគ្គលពាក់ព័ន្ធមិនបានកំណត់អំពីអត្តសញ្ញាណនិងមិនអាចកំណត់អំពីអត្តសញ្ញាណបានក្នុងពេលបច្ចុប្បន្ន ដូច្នេះការប្តឹងទៅយុត្តាធិការជំនុំជម្រះមិនអាចធ្វើឡើងបានឡើយ។ ព្រះរាជអាជ្ញា ក៏នឹងអាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផងដែរ ប្រសិនបើក្រោយពីពិនិត្យសំណុំរឿងនីតិវិធីខ្លួនយល់ឃើញថា ភស្តុតាងដែលខ្លួនប្រមូលបាននៅពុំទាន់មានភាពគ្រប់គ្រាន់ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបានហើយភស្តុតាងដែលខ្វះនោះ អាចប្រមូលបានទាល់តែប្រើអំណាចបង្ខំ ហើយអ្នកមានអំណាចនោះ គឺចៅក្រមស៊ើបសួរដោយមានមន្ត្រីនគរបាលយុត្តិធម៌ជាសេនាធិការជំនួយដល់ក្នុងការស្វែងរកភស្តុតាងដើម្បីបង្ហាញនូវភាពពិតក្នុងអង្គហេតុ។

## ២.១.២ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

យើងបានដឹងដូចការរៀបរាប់ខាងលើរួចមកហើយ អំពីបណ្តឹងបរិហារដែលប្តឹងក្នុងគោលបំណងទាមទារឱ្យផ្តន្ទាទោសទៅលើអំពើជាបទល្មើសណាមួយនោះ។ យ៉ាងណាមិញទន្ទឹមគ្នានេះ ក៏មិនភ្លេចបន្ទាប់ពីមានពាក្យបណ្តឹងបរិហារ មានពាក្យបណ្តឹងមួយទៀត គឺដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺធ្វើឡើងតាមរយៈជនរងគ្រោះនៃបទល្មើស អាចដាក់ពាក្យបណ្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា[28] ហើយមួយវិញទៀតការដាក់ពាក្យបណ្តឹងនេះផងដែរ គឺអាចធ្វើឡើងដោយបុគ្គលគ្រប់រូបដែលប្រកាសថាខ្លួន បាត់បង់ផលប្រយោជន៍ដោយអំពើជាបទល្មើស អាចដាក់ពាក្យប្តឹងបាន។ ចំពោះពាក្យប្តឹងសាមញ្ញនេះ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ។ នៅក្នុងបញ្ញត្តិដំបូងនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានយកចិត្តទុកដាក់ក្នុងការធានារ៉ាប់រងនូវជោគវាសនារបស់ជនរងគ្រោះ។ ក្នុងករណីនេះយើងមិនអាចបដិសេធក្នុងការរៀបចំបណ្តឹងតវ៉ាបានទេបើសិនជនរងគ្រោះបានបង្ហាញខ្លួន។ ហើយមានតែបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរប៉ុណ្ណោះ ទើបអាចដាក់ឱ្យបណ្តឹងអាជ្ញាមានចលនាឬដំណើរការបាន។ មួយវិញទៀតដើម្បីផ្តល់សិទ្ធិដល់ជនដែលរងគ្រោះដោយសារតែអំពើនោះ តាមរយៈបណ្តឹងរដ្ឋប្បវេណីដើម្បីជួសជុលនូវព្យសនកម្មមួយចំនួនដែលត្រូវតែ៖

- ជាផលវិបាកផ្ទាល់នៃបទល្មើស

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ.លេខនស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៥។

- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតនិងមាននៅក្នុងពេលបច្ចុប្បន្ន ។

ចំពោះព្យសនកម្មនេះរួមមានព្យសនកម្មផ្នែកសម្ភារៈ ផ្លូវចិត្តនិងរូបកាយ។[29] ទាំងនេះហើយជាហេតុនាំឱ្យមានការប្តឹងដើម្បីទាមទារសំណងនូវរាល់ព្យសនកម្ម ដែលកើតឡើងនិងទាមទារឱ្យតុលាការអនុវត្តតាមច្បាប់ឬផ្តន្ទាទោសលើជនល្មើស។ ដូច្នេះព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ត្រូវធ្វើការសម្រេចថ្លឹងថ្លែងអំពីចំណាត់ការក្នុងពាក្យបណ្តឹងនិងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌ បញ្ជូនមកថា[30] ត្រូវធ្វើបណ្តឹងអាជ្ញា ចំពោះបទល្មើសដែលនីតិវិធីបានកសាង ឬទេ? ទោះជាជនរងគ្រោះមានត្រឹមតែតួនាទីបន្ទាប់បន្សំក៏ដោយ ក៏ជននេះមានសិទ្ធិស្វ័យសម្រេច លើការអនុវត្តជាយថាហេតុនូវសិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការរដ្ឋប្បវេណី ដែលជាញឹកញយអាស្រ័យទៅលើសេចក្តីសម្រេចរបស់តុលាការ មានន័យថាបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងក្នុងពេលតែមួយនឹងបណ្តឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌហើយបណ្តឹងអាជ្ញាក៏អាចធ្វើនៅមុខសាលាជម្រះក្តីរដ្ឋប្បវេណីក្នុងករណីនេះបណ្តឹងរដ្ឋប្បវេណីត្រូវព្យួរសិន ដរាបណាមានសេចក្តីសម្រេចជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[31] ហេតុដូច្នេះ ដំណាក់កាលនៃចំណាត់ការសំណុំរឿងត្រូវបានស្ថិតក្នុងការសម្រេចថា តើព្រះរាជអាជ្ញាត្រូវយកផ្លូវណាមួយសម្រាប់ដើរ ដោយអាចតាមរយៈការបញ្ជូនសំណុំរឿងទៅអោយយុត្តាធិការស៊ើបសួរ ដើម្បីរៀបរៀងសំណុំរឿងនេះ ឬបញ្ជូនផ្ទាល់ទៅយុត្តាធិការជំនុំជម្រះ ឬការតម្កល់ទុកឥតបានការ។

ចំពោះសេចក្តីសម្រេចនៃចំណាត់ការសំណុំរឿង ត្រូវគោរពនូវលក្ខខណ្ឌនៃការពិនិត្យទៅលើភាពអាចទទួលយកបាន(ផ្ទៀងផ្ទាត់ថាតើបទល្មើសផុតអាជ្ញាយុកាលហើយឬនៅ) បន្ទាប់មកត្រូវពិនិត្យទៅលើវិធានសមត្ថកិច្ចរបស់យុត្តាធិការដែលសំណុំរឿងនេះនឹងត្រូវបញ្ជូនទៅ។ ត្រង់ចំណុចនេះដែលប្រសិនបើសំណុំរឿងដែលទទួលបានមានភាពខ្វះខាតគឺ ព្រះរាជអាជ្ញាអាចធ្វើការអនុវត្តវិធានការមួយដោយចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាការស៊ើបសួរអាចប្រព្រឹត្តទៅបានដោយមូលហេតុពីរយ៉ាងគឺ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" និង "ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ឬអាចនិយាយម៉្យាងទៀតថា ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ"។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០,សីហា ២០០៧,មាត្រា១៣។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ.លេខនស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤០ កថាខណ្ឌទី១ ។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ.លេខនស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២២។

ដើម្បីអាចដំណើរការនៃកិច្ចនីតិវិធីបើកការស៊ើបសួរនេះបាន គឺក្រោយពីទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មកកាន់អយ្យការ ឬបណ្តឹងពីជនរងគ្រោះផ្ទាល់ ដែលទាំងអស់នេះជាមូលដ្ឋានដើម្បីអាចឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ចំពោះបទល្មើសណាមួយបាន។ ក្នុងករណីនេះផងដែល បើទោះជាមានសំណុំរឿងដែលបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌ ឬដាក់ដោយជនរងគ្រោះផ្ទាល់មកកាន់ព្រះរាជអាជ្ញាក៏ដោយ តែបើព្រះរាជអាជ្ញាយល់ថា សំណុំរឿងដែលបញ្ជូនមកមិនមែនជាបទល្មើស ឬពិតជាបទល្មើសព្រហ្មទណ្ឌមែន តែមានព្យសនកម្មតិចតួច ដែលព្រះរាជអាជ្ញាគាត់អាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។ ក្នុងករណីនេះកាលណាបណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវតែឱ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល០២ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹង។ កាលតម្កល់រឿងទុកឥតចាត់ការនេះត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ ការតម្កល់ទុកឥតចាត់ការនេះដែរគ្មានអាជ្ញាអស់ជំនុំទេ។ **ឧទាហរណ៍៖** បុគ្គល ក បានដាក់ពាក្យប្តឹងមកកាន់អយ្យការលើបុគ្គល ខ ដោយប្តឹងពីបទ "ហិង្សាដោយចេតនា" ក្នុងករណីនេះ ព្រះរាជអាជ្ញាយល់ឃើញថាព្យសនកម្មតិចតួចពេកដោយពិនិត្យជាក់ស្តែងគ្រាន់តែបុគ្គល ខ រអិលជើងធាក់ចំ ក តែប៉ុណ្ណោះ។ ករណីមួយទៀត ប្រសិនបើបទល្មើសនោះជាបទឧក្រិដ្ឋវិញ នោះជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញាក្នុងការចេញដីកាសន្និដ្ឋានឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរភ្លាម តែបើជាបទមជ្ឈិមក្នុងច្បាប់ក៏បានកំណត់ថាអាចធ្វើការបើកការស៊ើបសួរក៏បាន និងមិនបាច់ក៏បាន[32] មានន័យថា អាស្រ័យលើភាពស្មុកស្មាញនៃរឿងក្តី។ ករណីនេះចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរបានទេ បើសិនគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា។[33]

តាមរយៈការបើកការស៊ើបសួរនេះ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរ ក្នុងគោលបំណងដើម្បីស្វែងរកការពិត និងករណីយកិច្ចស៊ើបសួររកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។[34] ម៉្យាងវិញទៀត ចំពោះការបើកការស៊ើបសួរផងដែរ នៅក្នុងករណីមានការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញានោះមិនមែនជាផ្លូវចុងក្រោយនោះទេ មានន័យថាច្បាប់បានទុកផ្លូវមួយទៀតដល់ជនទាំងឡាយដែលយល់ថាខ្លួនរងគ្រោះ ឬប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួននោះអាចធ្វើការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបាន ដោយជនរងគ្រោះអាចធ្វើឡើងតាមរយៈពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[35]

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២២។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៤ កថាខណ្ឌទី៣។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៧ កថាខណ្ឌទី២។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៥។

ដូចគ្នាដែលបើសិនជនរងគ្រោះពុំបានទទួលដំណឹងពីការវិវត្តរបស់បណ្តឹងអាជ្ញានោះទេ ខ្លួនមានជម្រើសក្នុងការប្តឹងទៅអគ្គព្រះរាជអាជ្ញា។ បន្ទាប់ពីបានដឹងហើយថា ការតម្កល់ទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា មិនមានអានុភាពអាជ្ញាអស់ជំនុំទេ កាលណាជនរងគ្រោះនៃរឿងក្តីយល់ថារឿងគាត់គឺជារឿងព្រហ្មទណ្ឌ ហើយនៅតែចង់បន្តធ្វើការផ្តន្ទាទោសលើជននោះ គាត់អាចដាក់ពាក្យប្តឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល០២ខែ ក្រោយពេលទទួលដំណឹងពីការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញាក្នុងករណីបណ្តឹងអាជ្ញាមិនទាន់ផុតរលត់។ បណ្តឹងអាជ្ញានេះ អាចធ្វើទៅបានក្នុងករណីដែលមានពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះទៅចៅក្រមស៊ើបសួរ។

មួយវិញទៀត នៅក្នុងករណីដែលពាក្យប្តឹងរបស់ជនរងគ្រោះស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការពីសំណាក់ព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[36] ចំពោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈដីកា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្តឹងនេះទៅកាន់ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកានេះអាច ធ្វើឡើងប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទលើឈ្មោះបុគ្គលម្នាក់ឬច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរដោយចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ម៉្យាងវិញទៀតក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាសម្រេចមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។[37] ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹម(ចំពោះបទលហុ មិនអាចធ្វើតាមវិធីនេះបានទេ) អាចដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ នៅក្នុងករណីបែបនេះលំហូរនៃនីតិវិធីព្រហ្មទណ្ឌមានដូចតទៅ៖[38]

ទោះបីជាចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវទទួលបាននូវដីកាបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាជាមុនសិន ទើបអាចធ្វើការស៊ើបសួរបាន។ ក្នុងន័យនេះ ក្រោយពីបានទទួលបានពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចៅក្រម

---

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា៦។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៣៩។

[38] លោក រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *មេរៀននីតិវិធីព្រហ្មទណ្ឌ,២០១៧,៣៨*។

ស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្តឹងតាមដីកាហើយបញ្ជូនបណ្តឹងនេះទៅកាន់ព្រះរាជអាជ្ញា។[39] ពេលដែលទទួលបានការបញ្ជូនបណ្តឹងនេះព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ(បើការស៊ើបសួរប្រឆាំងអញ្ញាតជន ឬចោទប្រកាន់លើបុគ្គលចំពោះម្នាក់ ឬច្រើន) ប៉ុន្តែព្រះរាជអាជ្ញាក៏អាចប្តឹងទៅចៅក្រមស៊ើបសួរ ប្រសិនបើអាជ្ញាយុកាលផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចស៊ើបសួរ ឬដីកាម្រេចមិនស៊ើបសួរដោយមានសំអាងហេតុ។ គួរកត់សម្គាល់ដែរថា បណ្តឹងដោយមានការតាំងខ្លួនឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងមួយថ្មីដែលទើបតែបញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ប្រាក់តម្កល់ទុកតាមការកំណត់របស់ចៅក្រមស៊ើបសួរតាមដីកាសម្រេចដោយផ្អែកលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងក្តីដែលអាចឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឱ្យបង់ប្រាក់នេះដែរ។ ប្រសិនបើចៅក្រមស៊ើបសួរ តម្រូវឱ្យបង់ប្រាក់តំកល់ទុក តែដើមបណ្តឹងរដ្ឋប្បវេណីពុំបង់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ ចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនេះបាន។ ការតម្រូវឱ្យមានបង់ប្រាក់តម្កល់នេះដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនជាចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភឬដោយអូសបន្លោយពេលវេលា ដោយចៅក្រមស៊ើបសួរចេញដីកាសម្រេចឱ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី។[40] តែប្រាក់ពិន័យនេះមិនអាចលើពីប្រាក់តម្កល់បានទេ។ ផ្ទុយទៅវិញប្រសិនបើមិនបង់ប្រាក់ពិន័យរដ្ឋប្បវេណីទេ ប្រាក់តម្កល់នេះត្រូវបង្វិលឱ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។[41] ក្នុងករណីនេះដែរ ព្រះរាជអាជ្ញាសុំកុំឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរ ចៅក្រមមានជម្រើសពីរយ៉ាង៖

- មិនធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចមានសំអាងហេតុ ហើយធ្វើការជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណី ។
- ធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចមានសំអាងហេតុ ហើយធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញា ។

បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង អាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងពីខ្លួនបាន ប្រសិនបើមានការបើកការស៊ើបសួរ បន្ទាប់ពីមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយក្រោយមកចៅក្រមស៊ើបសួរបានលើកលែងចោទប្រកាន់កាលបើនីតិវិធីបានធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា។[42]

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៣៩។

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៤១។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៤០។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៤២។

## កថាខណ្ឌទី២៖ អធិបញ្ញារបស់នាយឋានានុក្រម

ក្រៅតែពីព្រះរាជអាជ្ញាជាតួអង្គធ្វើការចោទប្រកាន់នេះ នៅពេលមានករណីដែលមានអង្គហេតុ ជាបទល្មើសព្រហ្មទណ្ឌមានភាពមិនប្រក្រតីដែលសង្គមយល់ឃើញថាប៉ះពាល់ដល់ប្រយោជន៍សង្គម ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈជាដើម។ ក្នុងករណីទាំងនេះ នៅពេលដែលអយ្យការអមសាលាដំបូងសម្រេចធ្វើការមិនចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ឬក្នុងករណីដែលមានអង្គហេតុជារឿងព្រហ្មទណ្ឌដែលអ្នកមាននាយឋានានុក្រម យល់ឃើញថាចាំបាច់ក្នុងករណីធ្វើអធិបញ្ញាទៅកាន់អយ្យការ ដើម្បីធ្វើការចោទប្រកាន់ភ្លាមៗនោះ គឺព្រះរាជអាជ្ញាដែលស្ថិតនៅក្រោមអំណាច ក៏ដូចជាការបង្គាប់បញ្ជានោះ គឺជាចាំបាច់ត្រូវតែគោរពតាម។ ចំពោះតួអង្គដែលជានាយឋានានុក្រម មានសិទ្ធិអំណាចក្នុងការធ្វើអធិបញ្ញានេះរួមមាន៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ តួអង្គទាំងពីរនេះ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មាននាយឋានានុក្រមលើគេ។

### ២.២.១ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

នៅក្នុងចំណុចនេះ តួនាទីរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញាទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានន័យថាព្រះរាជអាជ្ញានៅសាលាដំបូងតាមបណ្តាលរាជធានី-ខេត្ត ត្រូវស្ថិតនៅក្រោមការបង្គាប់បញ្ជា និងការពិន័យលើព្រះរាជអាជ្ញា ព្រះរាជអាជ្ញាវង្សណាដែលធ្វើខុសទៅនឹងច្បាប់ ឬក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗ។ ចំពោះដំណាក់កាលនៃការបើកការស៊ើបសួរនេះដែរ យើងដឹងរួចមកហើយថា គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទើបចៅក្រមស៊ើបសួរមានអំណាចក៏ដូចជាមានសមត្ថកិច្ចក្នុងការបើកនីតិវិធីស៊ើបសួរនេះបាន តែក្នុងករណីមួយថា ក្នុងរឿងក្តីណាមួយដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមតែព្រះរាជអាជ្ញាមិនចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដោយមានការជូនដំណឹងពីចៅក្រមស៊ើបសួរត្រង់ចំណុចនេះ ចៅក្រមស៊ើបសួរអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រម ក្នុងករណីនេះអគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ថាជាការគួរ។ ក្នុងករណីនេះ ថ្វីត្បិតតែអគ្គព្រះរាជអាជ្ញា មានអំណាចចាត់ឱ្យព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនធ្វើការចោទប្រកាន់ ឬចេញដីកាសន្និដ្ឋានពិតមែន អគ្គព្រះរាជអាជ្ញាគ្មានសិទ្ធិឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកមិនចាត់ការបានទេ។[43]

### ២.២.២ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បន្ទាប់ពីបានដឹងថា អគ្គព្រះរាជអាជ្ញាជានាយឋានានុក្រមមានអំណាចលើចៅក្រម អយ្យការទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ក្នុងនោះដែលគួរគប្បីដឹងដែរថា បន្ទាប់ពីអគ្គព្រះរាជអាជ្ញា គឺនៅមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជានាយឋានានុក្រមលើគេ ដោយគាត់អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាសាលា

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩។

ឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ ហើយចៅក្រម អយ្យការគ្រប់រូបត្រូវតែគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម។ ប៉ុន្តែនៅក្នុងសវនាការ ចៅក្រម អយ្យការធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ណាមួយដែលអាចធ្វើចំពោះមុខចៅក្រមអយ្យការ ដោយសារតែវាចាររបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[44]

## ផ្នែកទី៣៖ សិទ្ធិអំណាចនៃការប្រើប្រាស់វិធាននិរន្តរាយ

ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកិច្ចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរនិងតម្រូវឱ្យជនជាប់ចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធចូលមកបង្ហាញខ្លួនដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ ដោយប្រើប្រាស់នូវវិធានបង្ខំណាមួយទើបអាចឱ្យជនត្រូវចោទចូលមកបានតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន។[45] ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួនជាវិធានការមានវិសាលភាពអាចចេញទៅលើជនជាប់ចោទ ឬជនជាប់ពាក់ព័ន្ធនឹងអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ។ ជាគោលការណ៍វិធានការនិរន្តរាយអនុវត្តក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា តែដីកាបង្គាប់ឱ្យចាប់ខ្លួនក្នុង ករណីមានភាពចាំបាច់អាចធ្វើការផ្សព្វផ្សាយជាអន្តរជាតិដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គ្រប់មធ្យោបាយឱ្យមានប្រសិទ្ធិភាព។ វិធានការនិរន្តរាយ គឺជាបណ្តុំបទដ្ឋានគតិយុត្តដែលបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា១៨៥ រហូតដល់មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សម្រាប់ផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការប្រើប្រាស់ក្នុងគោលបំណងផលប្រយោជន៍ស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ និងគោលដៅបង្គាប់ឱ្យជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរឬអ្នកជំនួស និងអាចបង្គាប់ឱ្យជនត្រូវចោទទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនជាបណ្តោះអាសន្ន។

### កថាខណ្ឌទី១៖ វិធានការបង្ខំរបស់ចៅក្រមស៊ើបសួរ

វិធានការបង្ខំ(អន្តរាយ) គឺការរំលោភសិទ្ធិសេរីភាពបុគ្គលដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញក្នុងគោលបំណងដំណើរការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌនិងផលប្រយោជន៍សង្គមជាតិ ឬបង្ការនូវការកើតឡើងបទល្មើសជាថ្មី។ ជាគោលការណ៍សិទ្ធិសេរីភាពបុគ្គល ត្រូវបានការពារដោយច្បាប់ធានារ៉ាប់រងមិនឱ្យមានការរំលោភលើរូប

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៨៥។

កាយបុគ្គលណាមួយឡើយ។ មួយវិញទៀតការពារជីវិតកិត្តិយសសេចក្ដីថ្លៃថ្នូរប្រជាពលរដ្ឋ ការចាប់ខ្លួនរបស់បុគ្គល និងឃុំខ្លួនទៅលើជនអាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។[46]

### ៣.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន

ជាបញ្ជាដល់បុគ្គលដែលជាជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពឱ្យចូលមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងដីកា។ សាមីខ្លួនដែលទទួលបានដីកានេះ អាចមកដោយសេរីនៅចំពោះមុខចៅក្រមស៊ើបសួរតាមកាលកំណត់ ដើម្បីមកធ្វើការឆ្លើយបំភ្លឺនូវអ្វីៗដែលចៅក្រមស៊ើបសួរធ្វើការសាកសួរក្នុងឋានៈជាជនត្រូវចោទ ដែលត្រូវបានតំណាងអយ្យការធ្វើការប្ដឹងចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[47] ជាទូទៅដីកានេះប្រើប្រាស់នៅពេលដែលជនត្រូវចោទឬបុគ្គលមានតម្រុយពិរុទ្ធភាពមិនបានរត់គេចពីការទទួលខុសត្រូវអំពីអំពើបទល្មើសក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថមិនបានឆ្លើយតបនឹងការកោះហៅ ឬនៅដំណាក់កាលអយ្យការ។ ក្រោយពេលដែលជនត្រូវចោទ បានចូលខ្លួនមកចំពោះមុខចៅក្រមស៊ើបសួរតាមការបង្គាប់ឱ្យចូលខ្លួន ចៅក្រមស៊ើបសួរត្រូវសួរចម្លើយភ្លាមៗ។ អ្នកដែលទទួលបន្ទុកក្នុងការអនុវត្តដីកានេះគឺមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ច នាទីលំនៅរបស់ជនត្រូវចោទបានស្ថិតនៅដោយបញ្ជូនដីកានេះទៅតាមនីតិវិធី និងព្រមបង្វិលចុងដីកាដើមដោយមានចុះហត្ថលេខារបស់អ្នកទទួល ឬអ្នកប្រគល់ ឬរបាយការណ៍ស្ដីពីការបញ្ជូនទៅជនត្រូវចោទកំពុងស្ថិតនៅក្រៅ របស់តុលាការមានសមត្ថកិច្ចតាមនីតិវិធីច្បាប់ដែលបានចែងអំពីរបៀបស្ដីពីការបញ្ជូន។[48]

### ៣.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន

ជាបញ្ជាកងកម្លាំងសាធារណៈដើម្បីឱ្យចាប់និងនាំខ្លួនជនត្រូវចោទ ឬបុគ្គលមានពិរុទ្ធភាព ដែលបានគេចវេសមិនព្រមចូលមកបង្ហាញខ្លួនមកចំពោះមុខចៅក្រមស៊ើបសួរ ឬរឹងទទឹងមិនព្រមមកតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួនដែលចៅក្រមស៊ើបសួរបានចេញម្ដងឬជាពីរដងរួចមក តែនៅតែមិនព្រមមកចូលខ្លួនដដែលឬបានរត់គេចចេញពីមូលដ្ឋាន។ ដីកាបង្គាប់ឱ្យនាំខ្លួនអនុញ្ញាតឱ្យកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទមកបង្ហាញចំពោះមុខចៅក្រមស៊ើបសួរទេត្រូវយកទៅអង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួនឬពន្ធនាគារមិនឱ្យលើសពី២៤ម៉ោងយ៉ាង

---

[46] មាត្រា៣៨ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចុះថ្ងៃទី២១ កញ្ញា ១៩៩៣។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៣២។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៣២។

យូរក្រោយពីការឃុំខ្លួន។[49] នៅថ្ងៃបន្ទាប់បើសិនមិនបានមកបង្ហាញខ្លួនទេត្រូវដោះលែងឱ្យមានសេរីភាពវិញ។[50] អ្នកដែលទទួលបន្ទុកអនុវត្តដីកានេះ គឺជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបន្ទាន់នោះដីកានេះត្រូវផ្សព្វផ្សាយគ្រប់មធ្យោបាយទាំងអស់ដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះការចាប់ខ្លួន និងនាំខ្លួនមិនអាចចូលទៅលំនៅឋានរបស់ជនត្រូវចោទមុនម៉ោង០៦ព្រឹក និងក្រោយម៉ោង១៦ ល្ងាចបានឡើយ។ នៅពេលដែលមានឧបសគ្គក្នុងការអនុវត្តដីកានេះ ត្រូវតែជូនដំណឹងទៅដល់ចៅក្រមស៊ើបសួរដែលបានចេញដីកាបង្គាប់ឱ្យនាំខ្លួននេះជាបន្ទាន់ដើម្បីសុំគោលការណ៍បន្ថែម។

### ៣.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន

ជាបញ្ជាទៅដល់មន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស្រាវជ្រាវ និងស្វែងរកចាប់ខ្លួនជនត្រូវចោទដែលកំពុងតែរត់គេចខ្លួនមិនដឹងស្ថិតនៅទីណាមួយពិតប្រាកដ។

បញ្ជាឱ្យចាប់ខ្លួនគឺជាលក្ខខណ្ឌដែរតឹងរឹងបំផុត ដោយសារតែវាប៉ះពាល់នូវសិទ្ធិសេរីភាពយ៉ាងខ្លាំងដែលច្បាប់តម្រូវឱ្យចៅក្រមស៊ើបសួរ គោរពនូវលក្ខខណ្ឌទាំងនោះ ទើបអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបាន។ ជាគោលការណ៍មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទៅលើជនត្រូវចោទ ត្រូវតែជូនដំណឹងទៅតំណាងអយ្យការ ដែលបានធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[51]

*លក្ខខណ្ឌ* អាចចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលមានពិរុទ្ធភាពដូចជា៖ ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋឬមជ្ឈឹមដែលដាក់ទោសពន្ធនាគារ និងជនត្រូវចោទត្រូវបាននគរបាលមានសមត្ថកិច្ចបានបញ្ជាក់អំពីការរត់គេចខ្លួន ឬចាកចេញពីមូលដ្ឋានមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដីកាបង្គាប់ឱ្យចាប់ខ្លួននេះគឺជាវិធានការស្រាវជ្រាវតាមចាប់ខ្លួន និងនាំខ្លួនជនត្រូវចោទទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលមានបញ្ជាក់បង្គាប់ឱ្យទទួល និងឃុំខ្លួនជនត្រូវចោទក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួនដល់ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលតែម្តង។[52] ត្រូវតែគោរពលើពេលវេលាដែលច្បាប់ហាមឃាត់ការចូលទៅក្នុងលំនៅឋានមុនពេលម៉ោង០៦ព្រឹក និងក្រោយម៉ោង១៨។ ក្នុងករណីដែលត្រូវឃុំខ្លួននៅក្រៅដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ និងមិនអាចបញ្ជូនខ្លួនជនត្រូវចោទមកចំពោះមុខចៅក្រមស៊ើបសួរបានទេ ត្រូវបានស្តាប់ចម្លើយដោយតំណាងអយ្យការនាទីកន្លែងត្រូវបានចាប់ខ្លួន។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌនៃរ.ប.ស.វ.ត ដីកាបង្គាប់ឱ្យនាំ,ទំព័រទី៥៧ ចុះថ្ងៃទី២៥ សីហា ២០០៦។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៩០,១៩២។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៩៧។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២០១ ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន។

## កថាខណ្ឌទី២៖ វិធានការត្រួតពិនិត្យរបស់តុលាការ

ជាយន្តការមួយនៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលអនុញ្ញាតឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចអំពីសិទ្ធិសេរីភាពរបស់ជនត្រូវចោទដែលកំពុងតែបង្ហាញខ្លួននៅចំពោះខ្លួនថា តើគួរតែមានវិធានការយ៉ាងណា? ដើម្បីធានាឱ្យជនត្រូវចោទនឹងបង្ហាញខ្លួនគ្រប់ពេលដែលនីតិវិធីត្រូវការ និងការបង្ការនូវការប្រព្រឹត្តបទល្មើសជាថ្មី ឬបង្កនូវឧបសគ្គដល់ការស្រាវជ្រាវការពិតក្នុងសំណុំរឿងក្តី។ តែទោះបីជាមានវិធានការណាមួយត្រូវតែគោរពនៅផលប្រយោជន៍នៃការស្រាវជ្រាវបទល្មើស ត្រូវធ្វើឡើងតាមរយៈដីកាសម្រេចដោយមានសំអាងហេតុនិងសំអាងច្បាប់។

### ៣.២.១ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

ជាគោលការណ៍ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរពាក់ព័ន្ធ និងសេរីភាពរបស់ជនត្រូវចោទមានពីរប្រភេទដែលចៅក្រមស៊ើបសួរ សម្រេចសេចក្តីដោយមានសំអាងហេតុចំពោះដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នដែលមិនចាំបាច់មានសំអាងហេតុអ្វីឡើយ ចំពោះករណីចេញដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន។[53]

- ***ករណីសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន***

ចៅក្រមស៊ើបសួរ ត្រូវតែសម្រេចឃុំខ្លួនជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិរបស់ខ្លួនឬតាមរយៈដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនជាបណ្តោះអាសន្នរបស់តំណាងអយ្យការ។ ចំពោះការសម្រេចឃុំខ្លួនជាបណ្តោះអាសន្នអាចធ្វើទៅបានលុះត្រាតែទោសដាក់ពន្ធនាគារស្មើ ឬលើសពី០១ឆ្នាំឡើងទៅ និងជនត្រូវចោទមានអាយុយ៉ាងតិច ១៤ ឆ្នាំ ឡើងទៅរួមទាំងមានមូលហេតុណាមួយក្នុងបញ្ញត្តិច្បាប់បានកំណត់ជាមុន។

- ***ករណីសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន***

ការសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវតែពិនិត្យនិងពិចារណានូវលក្ខខណ្ឌផ្សេងៗ ដើម្បីធានាឱ្យបាននូវការចូលបង្ហាញខ្លួននៅតុលាការគ្រប់ដំណាក់កាលនីតិវិធី និងបង្ការឱ្យបាននូវការបង្កនូវឧបសគ្គ ដល់ដំណើរការនៃនីតិវិធីស្រាវជ្រាវបទល្មើស ឬអាចត្រូវបានជនត្រូវចោទដែលខ្លួនបានអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នបំផ្លាញនូវស្នាកស្នាម ឬតម្រុយពិរុទ្ធជាងនេះទៅទៀតអាចប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះ ឬសិទ្ធិវន្តព្រមទាំងសាក្សីដែលបានដឹងហេតុការណ៍ផងដែរ។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៧។

### ៣.២.២ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

ជាបញ្ជាបង្គាប់មកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំជនដែលមានក្នុងកម្មវត្ថុនៃដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្ន រហូតដល់មានការសម្រេចផ្សេងពីនេះ។[54] ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលត្រូវតែទទួល និងឃុំខ្លួនជនដែលមានក្នុងកម្មវត្ថុនៃដីកាបង្គាប់ឱ្យខ្លួនជាបណ្តោះអាសន្នរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឱ្យមានសិទ្ធិសេរីភាពវិញ។[55]

### ៣.២.៣ ដីកាបង្គាប់ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានមួយសម្រាប់ដាក់ឱ្យជនត្រូវចោទ ដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវតែកំណត់កាតព្វកិច្ចចំពោះជនត្រូវចោទឱ្យបានជាក់លាក់ និងច្បាស់លាស់ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់មានរហូតដល់ទៅ **១២**ចំណុច ដោយចៅក្រមស៊ើបសួរ អាចសំអាងមានច្រើនឬមួយ ទៅតាមកាលៈទេសៈនៃបទល្មើស ឬមានការព្រួយបារម្ភខ្លាចជនត្រូវចោទរត់គេចខ្លួន ឬលែងចូលមកបង្ហាញខ្លួនតាមការកោះហៅពីអាជ្ញាធរតុលាការ។[56] កាតព្វកិច្ចដែលចៅក្រមស៊ើបសួរអាចសម្រេចជ្រើសរើសបានមានដូចជា៖

១.មិនត្រូវចាកចេញក្រៅពីព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២.មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួននៅចំពោះមុខមន្ត្រីនគរបាលជាតិឬកងរាជអាវុធហត្ថតាមការកំណត់ដោយចៅក្រមស៊ើបសួរ

៥.ត្រូវឆ្លើយតបនិងការកោះហៅដោយអ្នកជំនួសចៅក្រមស៊ើបសួរ

៦.ប្រគល់ជូនដល់ក្រឡាបញ្ជីនូវឯកសារអត្តសញ្ញាណប័ណ្ណ

៧.មិនត្រូវបើកបររថយន្ត

៨.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩.ដាក់ប្រាក់ធានា ដែលទឹកប្រាក់នេះ និងថេរវេលាបង់ប្រាក់ត្រូវកំណត់ដោយចៅក្រមស៊ើបសួរ

១០.មិនត្រូវកាន់កាប់ ឬយកតាមនូវអាវុធ និងអាវុធដែលត្រូវបានចោទប្រកាន់ត្រូវប្រគល់ជូនក្រឡាបញ្ជី

១១.ត្រូវប្រគល់ខ្លួនឱ្យគ្រូពេទ្យពិនិត្យ ដែលដាក់ឱ្យស្ថិតក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា២១៩,២២០។

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា២២២។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា២២៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ។

១២.មិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈខ្លះ។ តែការអនុវត្តចំណុចទី១២ នេះចៅក្រមស៊ើបសួរមិនអាចហាមឃាត់វិជ្ជាជីវៈខាងសហជីព និងអាណត្តិបោះឆ្នោត បានឡើយដោយសារតែវាជាការប៉ះពាល់សិទ្ធិសេរីភាពដែលធានាដោយរដ្ឋធម្មនុញ្ញ និងខូចខាតប្រយោជន៍របស់កម្មករនិយោជិត និងផលប្រយោជន៍ដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។

**កថាខណ្ឌទី៣៖ លក្ខខណ្ឌ និងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍សេរីភាពរបស់ជនត្រូវចោទត្រូវតែមាន។ ច្បាប់ត្រូវតែគោរពនូវសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗដែលមាន ប៉ុន្តែការគោរពនូវសិទ្ធិសេរីភាពចំពោះបុគ្គលដែលបានប្រព្រឹត្តនូវអំពើណាមួយ ដែលច្បាប់បានហាមឃាត់សិទ្ធិសេរីភាព មិនត្រូវយកមកអនុវត្តឡើយក្នុងលក្ខខណ្ឌ ដើម្បីការពារនូវការប្រព្រឹត្តបទល្មើសជាថ្មី និងការពារសុវត្ថិភាពសង្គម។ ប៉ុន្តែដើម្បីអាចដកហូតនូវសិទ្ធិសេរីភាពដើរហើរច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌ ដើម្បីដកហូតនូវសេរីភាពបណ្តោះអាសន្ន។ ដោយសារតែរដ្ឋធម្មនុញ្ញបានកំណត់ថា ជនជាប់ចោទកាលណាក៏ដោយត្រូវចាត់ទុកថាជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។[57] ទោះបីជាច្បាប់អនុញ្ញាតផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការដកហូតនូវសិទ្ធិសេរីភាពយ៉ាងណាក៏ដោយ ក៏ច្បាប់បានកំណត់រយៈពេលមួយជាក់លាក់ក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន កាលណាហួសរយៈពេលដែលច្បាប់បានកំណត់ត្រូវតែដោះលែងឱ្យជនត្រូវចោទមានសិទ្ធិសេរីភាពវិញ និងអាចវិធានការផ្សេងៗដែលបានបញ្ញត្តិក្នុងការអនុវត្តវិធានការត្រួតពិនិត្យ និងតាមដានជនត្រូវចោទដើម្បីឱ្យដំណើរការនីតិវិធី និងធានាថាជនត្រូវចោទចូលមកបង្ហាញគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការ។

**៣.៣.១ លក្ខខណ្ឌនៃបុគ្គលដែលត្រូវបានចោទប្រកាន់**

គោលការណ៍អនីតិជន ដែលមានអាយុក្រោម១៤ឆ្នាំដែលបានប្រព្រឹត្តបទល្មើសមិនអាចទទួលខុសត្រូវខាងបទល្មើសព្រហ្មទណ្ឌនោះទេ ប៉ុន្តែក៏ត្រូវបន្តវិធីរហូតមកដល់ដំណាក់កាលចៅក្រមស៊ើបសួរ ចំណុចនេះអាចកើតមានឡើងដោយសារតំណាងអយ្យការ បានបើកការស៊ើបសួរដែលមានអនីតិជនដែលមានអាយុតិចជាង១៤ឆ្នាំមកជាមួយ ហើយមិនអាចវិនិច្ឆ័យអំពីអាយុរបស់ជនជាប់សង្ស័យទើបចេញដីកាបញ្ជូនសំណុំឱ្យស៊ើបសួរមកកាន់ចៅក្រមស៊ើបសួរ ទើបចៅក្រមស៊ើបសួរអាចសម្រេចលើកលែងបទចោទប្រកាន់របស់អនីតិជនអាយុក្រោម១៤ឆ្នាំដោយផ្អែកទៅលើភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីនត្តិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។[58] ជនត្រូវចោទ ត្រូវតែចោទប្រកាន់ពីបទឧក្រិដ្ឋឬមជ្ឈិម ដែលមានទោសដាក់ពន្ធនាគារស្មើ ឬលើសពី០១ ឆ្នាំករណីក្រៅ

---

[57] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ កញ្ញា ១៩៩៣ មាត្រា៣៨ កថាខណ្ឌទី៧។

[58] ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី១៤ កក្កដា ២០១៦ នៃមាត្រា៤២។

ពីនេះ មិនអាចអនុវត្តទៅនឹងការឃុំខ្លួនបណ្តោះអាសន្នបានឡើយ ដោយសារបទបញ្ញត្តិនេះការពារនូវការដកហូតសិទ្ធិសេរីភាពរបស់បុគ្គល។[59]

### ៣.៣.២ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

មូលហេតុដែលច្បាប់អនុញ្ញាត ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានយោងមូលហេតុក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអាចមានមួយឬច្រើន។ ចៅក្រមស៊ើបសួរដាច់ខាតត្រូវតែមានសំអាងហេតុក្នុងមូលហេតុណាមួយដែលច្បាប់បានកំណត់។ មូលហេតុទាំងនោះមានដូចជា៖

១. ដើម្បីបញ្ឈប់បទល្មើស និងបង្ការបទល្មើសកុំឱ្យកើតមានជាថ្មី

២.ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត

៣.ដើម្បីរក្សាភស្តុតាង និងតម្រុយជាសម្ភារៈ

៤.ដើម្បីធានារក្សាទុក ជនត្រូវចោទជូនតុលាការតាមនីតិវិធី

៥.ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ

៦.ដើម្បីធានាការពារនូវសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានភាពច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[60] **ឧទាហរណ៍៖ ក** ជាជនត្រូវចោទដែលបានប្រព្រឹត្តបទល្មើស "***ឃាតកម្មគិតទុកជាមុន***" ទៅលើជនរងគ្រោះ **ខ** ដែលបានស្លាប់បាត់បង់ជីវិតនិងជនត្រូវចោទនេះធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសជាច្រើនដង។

### ៣.៣.៣ រយៈពេល និងការពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន

រយៈពេល គឺជាកាលកំណត់មួយដែលច្បាប់បានគណនាពិចារណាជាមុននូវអំឡុងពេលសម្រាប់ឱ្យចៅក្រមស៊ើបសួរ សម្រេចដាក់ជនត្រូវចោទឱ្យជាប់ពន្ធនាគារជាបណ្តោះអាសន្ន ដោយធ្វើការបែងចែកករណីជាពីរដាច់ដោយឡែកពីគ្នាគឺ ករណីនីតិជន និងករណីអនីតិជន។ ដោយនីតិជនត្រូវបានកំណត់រយៈពេលសម្រាប់បទល្មើសឧក្រិដ្ឋនិងសម្រាប់បទល្មើសមជ្ឈឹម។ ចំពោះអនីតិជនត្រូវបែងចែកជាអាយុមានអាយុ១៤ឆ្នាំ ទៅដល់១៦ឆ្នាំ និង១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ដោយអាចធ្វើការឃុំខ្លួនជាបណ្តោះអាសន្នទៅតាមប្រភេទនៃបទល្មើសនីមួយៗដែលមានបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម។ ចំណែកឯការពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន ដោយសារតែត្រូវការចំណាយពេលវេលាសម្រាប់ស្រាវជ្រាវបទល្មើសបន្ថែម ប៉ុន្តែការពន្យាពេលឃុំខ្លួននេះបានតែចំពោះនីតិជនតែប៉ុណ្ណោះដែលបានប្រព្រឹត្តបទល្មើស ចំពោះករណីអនិតិជនវិញមិនអាចពន្យាពេលបានឡើយ។ ចំពោះនិតិជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរមានអំណាចទូលំទូលាយក្នុងការពន្យាពេលឃុំខ្លួនជនត្រូវ

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៤ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៥ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន។

ចោទជាបន្តបាន។ ដោយច្បាប់បានកំណត់ឱ្យចៅក្រមស៊ើបសួរមានសិទ្ធិពន្យាពេលបាន០២ដង និងរយៈពេល ០៦ខែ ក្នុងមួយដងៗ។[61] ចំណែកបទល្មើសមជ្ឈិមវិញ ចៅក្រមស៊ើបសួរអាចពន្យាពេលបាន ០២ខែ ប៉ុន្តែបានតែម្តងប៉ុណ្ណោះ។[62]

*-ករណីឃុំខ្លួនជាបណ្តោះអាសន្នចំពោះនីតិជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិម*

ជាទូទៅនីតិជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នអតិប្បរមាមិនឱ្យលើសពី០៦ខែ ចំពោះជនត្រូវចោទ។[63] បទល្មើសមជ្ឈិមវិញ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន អតិប្បរមាមិនឱ្យលើសរយៈពេល០៤ខែ ចំពោះជនត្រូវចោទ។[64]

*-ករណីឃុំខ្លួនជាបណ្តោះអាសន្នចំពោះអនីតិជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិម៖*

ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់១៦ឆ្នាំ ចៅក្រមស៊ើបសួរ អាចធ្វើការឃុំខ្លួនជាបណ្តោះអាសន្នបានចំពោះការប្រព្រឹត្តបទល្មើសមជ្ឈិម និងមានរយៈពេលអតិប្បរមាមិនឱ្យលើសពី០២ខែ ចំពោះអនីតិជនដែលមានអាយុតិចជាង ១៦ឆ្នាំ និងរយៈពេល ០៤ខែ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។[65] ចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរ នឹងអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្នបានដែលមានថេរវេលាអតិប្បរមាមិនឱ្យលើសពី០៤ខែ ចំពោះអនីតិជនដែលមានអាយុតិចជាង១៦ឆ្នាំ និងចំពោះអនីតិជនដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ការឃុំខ្លួនជាបណ្តោះអាសន្នមិនឱ្យលើសពីរយៈពេល ០៦ខែឡើយ។[66] ជាពិសេសនោះការឃុំខ្លួនជាបណ្តោះអាសន្នចំពោះអនីតិជន ក្នុងបទល្មើសមជ្ឈិមមិនត្រូវលើសពីពាក់កណ្តាល នៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ **ឧទាហរណ៍៖** ក បានប្រព្រឹត្តបទល្មើស "លួច"ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី០៦ខែទៅ ០៣ឆ្នាំ ដែលខ្លួនទើបតែមានអាយុ១៧ឆ្នាំ។ អប្បរមានៃទោសកំណត់សម្រាប់អនីតិជននោះ០៣ខែ ដូច្នេះចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបានតែរយៈពេលអតិប្បរមាត្រឹមតែ០៣ខែមិនមែន ០៤ខែ តាមការកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៨ កថាខណ្ឌទី២។
[62] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៩ វាក្យខណ្ឌទី១។
[63] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៨ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នឧក្រិដ្ឋ។
[64] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខនស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២០៩ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបទមជ្ឈិម។
[65] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២១៤។
[66] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៥០៧/០២៤,១០ សីហា ២០០៧,មាត្រា២២៣។

# ជំពូកទី២
# អំណាចសំខាន់ៗលើការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី២

# អំណាចសំខាន់ៗលើការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

ក្រោយពីបានសិក្សា ពីជំពូកទី១ ទាក់ទងនឹងមូលដ្ឋានគ្រឹះនៃការស៊ើបសួររួចមក បានដឹងថាអំពីចៅក្រមស៊ើបសួរជាអ្នកណា គេបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះក្នុងគោលបំណងអ្វី ហើយចៅក្រមស៊ើបសួរគាត់មានសមត្ថកិច្ចអ្វីខ្លះ ក្នុងកិច្ចបើកការស៊ើបសួរនេះដែលត្រូវតែបំពេញ ក៏ដូចជាសិទ្ធិអំណាចដែលច្បាប់ប្រគល់ឱ្យ។ មួយវិញទៀត ប្រភពចម្បងដែលអាចឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលទាំងនេះជាមូលហេតុនាំឱ្យចៅក្រមស៊ើបសួរមានអំណាចក៏ដូចជាសិទ្ធិអំណាចមួយចំនួន ក្នុងការបើកការស៊ើបសួរដើម្បីធានាដល់ការស្វែងរកការពិត នៃអង្គហេតុជាបទល្មើសដែលទាំងនេះហើយជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះប្រកបដោយយុត្តិធម៌។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការស៊ើបសួរមានប្រសិទ្ធិភាពនោះ ចៅក្រមស៊ើបសួរគាត់បំពេញកិច្ចស្រាវជ្រាវដោយប្រើប្រាស់អំណាចដែលខ្លួនមាន ដើម្បីធ្វើការស៊ើបសួរដោយផ្អែកលើអំណាចមួយចំនួនដែលនឹងធ្វើការអត្ថាធិប្បាយខាងក្រោមនេះរួមមាន៖ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស និងអំណាចស្រាវជ្រាវតាមការស្នើសុំ។

## ផ្នែកទី១៖ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់

ដើម្បីធ្វើការបកស្រាយអំណាចក្នុងការស្រាវជ្រាវដោយខ្លួនឯងនេះ ដោយត្រូវគប្បីដឹងថាចៅក្រមស៊ើបសួរគឺគាត់មានសិទ្ធិអំណាចក្នុងការបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិត។[67] ដូច្នេះគាត់ដឹកនាំដោយសេរី និងឯករាជ្យនូវកិច្ចស៊ើបសួររបស់ខ្លួន និងមិនទទួលអធិបញ្ជាពីភាគីឬអាជ្ញាធរណាមួយឡើយ។ កិច្ចស្រាវជ្រាវដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ មិនមានភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលទេ ព្រោះក្នុងករណីនេះ វាជាកិច្ចបង្ហាញនូវភស្តុតាងដល់តុលាការ។ ព្រះរាជអាជ្ញា អាចជួយគ្រប់កិច្ចស៊ើបសួរ និងអាចសុំឱ្យមានកិច្ចស៊ើបសួរនេះទៅចៅក្រមស៊ើបសួរ។

### កថាខណ្ឌទី១៖ អង្គហេតុដែលមានសញ្ញាណធាតុផ្សំបទល្មើស

ដូចដែលបានសិក្សារួចមកហើយ ក្នុងអំពើអាចចាត់ទុកជាបទល្មើសមួយបាន គឺត្រូវគោរពនូវធាតុផ្សំបទល្មើស រួមមាន៖ ធាតុអន្តោម័ត ធាតុសត្យានុម័ត និងធាតុនីត្យានុកូល។ អាចធ្វើការស្រាវជ្រាវបាន គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទើបចៅក្រមស៊ើបសួរមានអំណាចបើកការស៊ើបសួរ យើងត្រូវគិតពីអំពើដែលបានប្រព្រឹត្តក៏ដូចជាចារិកគ្រោះថ្នាក់នៃអំពើនោះ ជាសញ្ញាណនៃបទល្មើស។ ការស្រាវជ្រាវនេះ គឺរកឱ្យឃើញនូវភាពពិតនៃអង្គហេតុ រួមមានស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ ពាក្យថាភស្តុតាងដាក់បន្ទុកនេះ

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៧។

និងភស្តុតាងដោះបន្ទុកនេះដោយយោងទៅលើកម្មវត្ថុនៃការចោទប្រកាន់ គេអាចឃើញនូវស្ថានការណ៍ទាំងឡាយរបស់ជនត្រូវចោទដែលបានប្រព្រឹត្តរួចហើយ ហើយនឹងអ្វីៗដែលបានបន្សល់ទុកពីអំពើនោះ ក្លាយជាកម្មវត្ថុនៃការចោទប្រកាន់។ ពីព្រោះថាការចោទប្រកាន់ទៅលើជនណាម្នាក់ ស្ថាប័នមានសមត្ថកិច្ចត្រូវតែមានភស្តុតាងសមល្មមដែលអាចយល់បានក្នុងដំណាក់កាលនៃនីតិវិធីនៃការចោទប្រកាន់។ ភស្តុតាងនៅក្នុងក្រុមនេះគេសំអាងសំខាន់នៅការផ្ដើមចោទប្រកាន់ពីដំបូង និងដោយយោងទៅលើកម្មវត្ថុនៃការចោទប្រកាន់នោះភស្តុតាងចែកចេញជាពីរប្រភេទ គឺដាក់បន្ទុក និងដោះបន្ទុក។ ចំពោះភស្តុតាងដាក់បន្ទុក គឺជាភស្តុតាងទាំងឡាយណាដែលធ្វើឱ្យមានពិរុទ្ធភាពលើជនត្រូវចោទ ឬភស្តុតាងដែលធ្វើឱ្យមានការទទួលខុសត្រូវនូវកំហុសរបស់ជនដែលបានប្រព្រឹត្តបទល្មើសនោះ។ ទំនាក់ទំនងដែលពាក់ព័ន្ធនឹងភស្តុតាងរបៀបនេះវាឈរនៅលើមូលដ្ឋាននៃការចោទប្រកាន់ ឬក៏លក្ខខណ្ឌទាំងឡាយណាដែលធ្វើឱ្យមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលដល់ការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ចំណែកឯ ភស្តុតាងដោះបន្ទុកវិញ គឺជាភស្តុតាងទាំងឡាយណាដែលច្រានចោលការចោទប្រកាន់ដោយកំណត់បាននូវភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬក៏ភស្តុតាងនោះធ្វើឱ្យថយចុះកាន់តែតូចនូវពិរុទ្ធភាព។ តែអាចនិយាយបានទៀតថា ជាភស្តុតាងដែលកំណត់បាននូវលក្ខខណ្ឌនានាប្រកបដោយមានស្ថានសម្រាលទោសក្នុងការទទួលខុសត្រូវរបស់ជនជនត្រូវចោទ បានផងដែរ។ ចំពោះការមានការបែងចែកដាក់បន្ទុកនិងដោះបន្ទុកនេះ វាមានលក្ខខណ្ឌដោយឡែកត្រង់ថា គ្រប់ភស្តុតាងវាពុំមានចរិតដូចគ្នាទេ ប៉ុន្តែវាមានព្រំដែនរបស់វាច្បាស់លាស់ថាភស្តុតាងជាច្រើន វានាំមកនូវចរិតដាក់បន្ទុក និងចរិតដោះបន្ទុកក្នុងពេលតែមួយ។[68]

ក្នុងករណីក្រោយពីការស៊ើបសួរចប់ ចៅក្រមស៊ើបសួរគាត់រកមិនឃើញថាមានបទល្មើសឬធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ឬគ្រប់គ្រាន់ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយដើម្បីបិទ គឺការចេញដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាលើកលែងចោទប្រកាន់។[69] ត្រង់ចំណុចនេះ ចំពោះដីកាសន្និដ្ឋានដែលព្រះរាជអាជ្ញាបញ្ជូនឱ្យស៊ើបសួរត្រូវបានបែងចែកជាពីរ គឺអង្គហេតុក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងអង្គហេតុគ្មានក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។

### ១.១.១ អង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ក្រោយពីបានស្វែងយល់អំពីមូលហេតុដែលនាំឱ្យចៅក្រមមានអំណាចក្នុងការស៊ើបសួររួចមក កិច្ចស្រាវជ្រាវ របស់ចៅក្រមស៊ើបសួរនេះផងដែរ ក៏មិនមានសភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលយុត្តិធម៌ទេ ព្រោះថាករណីទាំងពីរនេះវាជាកិច្ចបង្ហាញភស្តុតាងដល់តុលាការ។ ដោយការស្រាវជ្រាវនេះចៅក្រមស៊ើបសួរ អាច

[68] អ៊ិន បូផា, នីតិភស្តុតាង,២០១២,៣៥។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៤៧។

បើកការស៊ើបសួរបានត្រឹមកម្រិតដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ការបើកការស៊ើបសួរនេះត្រូវតែមានដីកាសន្និដ្ឋានពីព្រះរាជអាជ្ញា ទើបចៅក្រមស៊ើបសួរមានអំណាចបើកការស៊ើបសួរនេះបាន។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងនិងអញ្ញាតជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនអាចកំណត់បាន។
- ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខា។ ទម្រង់ការបែបនេះត្រូវតែមានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវចាត់ទុកមោឃៈ។[70]

ចំពោះការស្រាវជ្រាវនេះ ចៅក្រមស៊ើបសួរបំពេញតាមកិច្ចមួយចំនួនដូចខាងក្រោម៖

### ១.១.២ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ នូវបុគ្គលគ្រប់រូបដែលមានតម្រុយពិរុទ្ធភាពច្បាស់លាស់ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាមិនមានការចង្អុលបង្ហាញប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះក្នុងឋានៈជា ចារី ជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិត។[71] ចំពោះការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ គឺជាវិធីដែលទើបតែមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះប៉ុណ្ណោះ ដោយនេះជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ។ ផងដែរការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យធ្វើនៅពេលចូលបង្ហាញខ្លួនលើកដំបូង ដោយចៅក្រមស៊ើបសួរត្រូវអនុវត្ត៖

- ពិនិត្យអត្តសញ្ញាណរបស់ជនជាប់ចោទ
- ប្រាប់ពីជនត្រូវចោទពីរឿងរ៉ាវដែលចោទប្រកាន់
- ប្រាប់ពីឈ្មោះបទល្មើសដែលកំណត់ក្នុងច្បាប់
- ប្រាប់ជនត្រូវចោទថា អាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី
- ប្រាប់ពីសិទ្ធិរបស់ជនត្រូវចោទក្នុងការជ្រើសរើសមេធាវី ឬសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់លក្ខន្តិកៈមេធាវី។

---

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៨៤។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៦។

- ចំពោះជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ ដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[72]

### ១.១.៣ ការសួរចម្លើយ និងស្តាប់ចម្លើយរបស់ភាគីពាក់ព័ន្ធ

- ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ អាចធ្វើឡើងនៅចំពោះមុខមេធាវីជនត្រូវចោទ។ ប៉ុន្តែប្រសិនបើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវី។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបានដោយមិនចាំបាច់កោះហៅមេធាវីបានដូចជាមានគ្រោះថ្នាក់បណ្តាលឱ្យស្លាប់ ឬមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ នៅពេលសួរចម្លើយ ព្រះរាជអាជ្ញា និងមេធាវីក៏មានវត្តមានដែរ ហើយអាចលើកសំណួរទៅជនត្រូវចោទបានបន្ទាប់ពីមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឱ្យជនត្រូវចោទស្នើសុំឱ្យចៅក្រមស៊ើបសួរ សួរចម្លើយខ្លួន ឬសួរតទល់ កាលណាថេរវេលា ០៤ខែបានកន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមកោះហៅក្នុងចិរវេលា០១ខែ បន្ទាប់ពីការសុំទេ ជនត្រូវចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯងបាន។ ចំពោះកំណត់ហេតុសួរចម្លើយនេះត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក៏ដូចជាជនត្រូវចោទផងដែរ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃការស៊ើបសួរ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវស្តាប់ដោយមន្ត្រីនគរបាលយុត្តិធម៌ លុះត្រាតែគាត់បានសុំ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលជំនួយពីមេធាវីក្នុងពេលកំពុងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ។ ដូច្នេះមេធាវី ត្រូវទទួលបានការកោះហៅក្នុងថេរវេលា ០៥ថ្ងៃមុនការស្តាប់ចម្លើយ មានសិទ្ធិពិនិត្យសំណុំរឿងក្នុងចិរវេលានេះ និងអាចទទួលបានដោយចេញសោហ៊ុយខ្លួនឯងនូវឯកសារថតចម្លង និងលិខិតផ្សេងៗទៀតនៃនីតិវិធី ដោយមានការអនុញ្ញាតពីចៅក្រម។ ការស្តាប់ចម្លើយអាចធ្វើបានដោយពុំចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងពុំចាំបាច់កោះហៅមេធាវី ក្នុងករណីបន្ទាន់(គ្រោះថ្នាក់ដល់អាយុជីវិត ហានីភ័យនៃការបាត់បង់តម្រុយភស្តុតាង)។ ដូចពេលសួរចម្លើយជនត្រូវចោទដែរ ព្រះរាជអាជ្ញាអាចមានវត្តមាន។ ព្រះរាជអាជ្ញា និងមេធាវីរបស់ជនរងគ្រោះអាចសួរជនរងគ្រោះបានដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៤៣។

- ការស្តាប់ចម្លើយសាក្សី

សាក្សីអាចត្រូវបានគេឱ្យនិយមន័យបានថា ជាបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃការចោទប្រកាន់ និងអាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ ដល់ការបង្ហាញការពិតទៅចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា សាក្សីមានសារៈសំខាន់គាត់អាចបញ្ជាឱ្យកោះហៅសាក្សីនោះ។ ដូច្នេះសាក្សីមានកាតព្វកិច្ច ០៣យ៉ាង៖ ចូលបង្ហាញខ្លួនភ្លាម ធ្វើពាក្យសម្បថ(ត្រូវបានរួចផុតពីពាក្យសម្បថ បុគ្គលដែលស្និតជាមួយជនត្រូវចោទ ដូចជាបុព្វញាតិ បច្ឆាញាតិ ឬបងប្អូនជាដើម)។[73] បើសាក្សីបដិសេធមិនបង្ហាញខ្លួនចៅក្រមស៊ើបសួរសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន ដោយចេញបញ្ជាឱ្យចូលបង្ហាញខ្លួន ដែលមានចុះពីអត្តសញ្ញាណរបស់សាក្សី កាលបរិច្ឆេទចេញបញ្ជា ហត្ថលេខា និងត្រារបស់ចៅក្រម។ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចហៅអ្នកបកប្រែដើម្បីស្តាប់ចម្លើយសាក្សី។

## កថាខណ្ឌទី២៖ ការឆែកឆេរ និងចាប់យកវត្ថុតាង

ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាងនេះ ផ្ទុយពីគំនិតដែលទទួលបានជារួម ការស៊ើបសួរមិនអនុញ្ញាតឱ្យធ្វើការឆែកឆេរគ្រប់ទីកន្លែងដោយពុំមានលក្ខខណ្ឌ ដូចក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងនោះទេ។ ក្នុងក្របខណ្ឌនៃការស៊ើបសួរការឆែកឆេរត្រូវគោរព ពេលម៉ោងដែលច្បាប់កំណត់ដូចក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងដែរ គឺចន្លោះម៉ោង១៨ល្ងាច និងម៉ោង ៦ព្រឹក។ គោលការណ៍នេះត្រូវបានលើកលែងក្នុងករណីឆែកឆេរ ដែលបើកឱ្យសាធារណៈជន កន្លែងដែលមានបុគ្គលប្រព្រឹត្តព្យសនកម្ម និងកន្លែងបុគ្គលលក់ ឬប្រើប្រាស់គ្រឿងញៀន។ ដូចគ្នានេះដែរការឆែកឆេរក្នុងការិយាល័យមេធាវី ត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវីឬប្រតិភូរបស់គាត់។ ចំពោះអ្នកកាន់កាប់ទីកន្លែង គឺត្រូវមានវត្តមាន ឬបើគ្មានអ្នកកាន់កាប់ទេត្រូវមានសាក្សីពីរនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសាក្សីនោះមិនអាចជាកងរាជអាវុធហត្ថ ឬមន្ត្រីនគរបាលទេ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលត្រូវមានចុះអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ និងដោយយថាហេតុ អត្តសញ្ញាណរបស់ប្រធានគណៈមេធាវី។ ជាចុងក្រោយកំណត់ហេតុនេះត្រូវចុះហត្ថលេខាពីចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

ចំពោះការចាប់យកវត្ថុតាងវិញ ច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ នៅពេលក្រោយមកទៀត ដើម្បីឱ្យមានភាពប្រាកដថាវត្ថុដែលបានចាប់យកមកនោះពិតជាវត្ថុដែលបានចាប់យកក្នុងសំណុំរឿងនីតិវិធី វត្ថុ ឬឯកសារត្រូវស្ថិតក្រោមទម្រង់តែមួយនៃការបញ្ជាក់អត្តសញ្ញាណដូចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងដែរ។ ជាអាទិ៍វត្ថុត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ និងមានបិទស្លាកបន្ទាប់ពីបាន

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៥៦។

បង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី។ នៅគ្រប់ពេលនៃការស៊ើបសួរ ចៅក្រមមានអំណាចប្រគល់សងវត្ថុដែលបានចាប់យកនោះវិញ។ គាត់អាចធ្វើដោយឯកឯងបន្ទាប់ពីមានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬពីគ្រប់បុគ្គលទាំងអស់ដែលអះអាងថាមានសិទ្ធិលើវត្ថុដែលបានចាប់។ គាត់អាចធ្វើការបដិសេធប្រគល់វត្ថុដែលជាឧបសគ្គដល់ការសម្ដែងឱ្យឃើញការពិត នៅពេលដែលវត្ថុមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិ និងនៅពេលដែលត្រូវបានកាន់កាប់ដោយខុសច្បាប់។ គាត់ត្រូវចេញសេចក្ដីសម្រេចដែលទាក់ទងទៅនឹងការប្រគល់សងនេះ តាមរយៈដីកាដែលមានសំអាងហេតុដែលបើកផ្លូវបណ្ដឹងឧទ្ធរណ៍។

### ១.២.១ ការធ្វើកោសលវិច័យ

វត្ថុតាងទាំងឡាយណាដែលចៅក្រមស៊ើបសួរ មិនអាចវាយតម្លៃបានដោយខ្លួនឯង ឬមានភាពចាំបាច់ក្នុងការចាត់តាំងអ្នកជំនាញ ដើម្បីធ្វើការវាយតម្លៃជំនួសខ្លួនបាន។ អ្នកជំនាញត្រូវតែបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលមានលក្ខណៈជាបច្ចេកទេសសុទ្ធសាធក្នុងការធ្វើតេស្ត និងផ្ដល់នូវលទ្ធផលមកចៅក្រមស៊ើបសួរវិញក្នុងការវិនិច្ឆ័យចំណាត់ការបន្ត។ អ្នកជំនាញទាំងនោះអាចមានពីរប្រភេទគឺអ្នកជំនាញដែលមានក្នុងបញ្ជីថ្នាក់ជាតិ ដោយសេចក្ដីប្រកាសរបស់ក្រសួងយុត្តិធម៌និងអ្នកជំនាញដែលក្រៅពីបញ្ជីថ្នាក់ជាតិចៅក្រមស៊ើបសួរអាចជ្រើសតាំងបាន។ ចំពោះករណីដែលមានភាពចាំបាច់ក្នុងការធ្វើកោសលវិច្ច័យទៅលើស្លាកស្នាម ឬវត្ថុតាងណាមួយដែលចៅក្រមស៊ើបសួរមិនអាចវិនិច្ឆ័យដោយខ្លួនឯងបាននោះ។ ការចាត់តាំងអ្នកជំនាញក្រៅពីបញ្ជីថ្នាក់ជាតិចៅក្រមស៊ើបសួរ ត្រូវតែឱ្យអ្នកជំនាញនោះ ធ្វើការសម្បថទៅតាមសាសនា ឬជំនឿរបស់ខ្លួននៅចំពោះមុខវត្ថុស័កសិទ្ធ។ ករណីចាត់តាំងអ្នកជំនាញថ្នាក់ជាតិ មិនចាំបាច់ធ្វើសម្បថម្ដងទៀតឡើយ។ ដូចជាករណី សារធាតុញៀន ស្នាមម្រាមដៃ សរសៃសក់ ស្នាមបាតជើង ឈាម ឬស្បែក មធ្យោបាយនៃការប្រព្រឹត្តបទល្មើស.ល.។

*ការស្ដាប់ទូរស័ព្ទ*

ចំពោះការស្ដាប់ទូរស័ព្ទនេះ គឺជាការស្ដាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ការចាប់និងការថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរស័ព្ទ ឬសារតាមអិនធឺណែត។[74] មានតែចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្ដឹងដោយស្របច្បាប់ប៉ុណ្ណោះ ដែលមានអំណាចបញ្ជាឱ្យមានការចាប់ការថត និងការចម្លងអក្សរនៃការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍។ ម្យ៉ាងទៀត គាត់អាចចុះដល់ទីកន្លែងដែរធ្វើការចាប់ និងការថតនេះ។ ប៉ុន្តែវិធានការនៃការស៊ើបសួរនេះ ត្រូវតែចាំបាច់ដើម្បីបង្ហាញការពិត និងត្រូវមានគ្រប់ធាតុ

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧២។

នៃការកំណត់អត្តសញ្ញាណនៃការទាក់ទងដែលចាប់បទល្មើស ដែលជាមូលហេតុនាំឱ្យមានការចាប់ និងថេរវេលានៃការចាប់នេះ។ ក្នុងការអនុវត្ត សេចក្តីសម្រេចនេះគឺជាដីកាចាត់ឱ្យស៊ើបសួរជំនួសដែលជាក់លាក់ពិសេស ដែលប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ចំពោះសេចក្តីសម្រេចនេះត្រូវមានចុះការចង្អុលបង្ហាញជាក់លាក់នៃឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានស្តាប់ លេខទូរស័ព្ទ បើពុំនោះទេនឹងត្រូវមានមោឃភាព។

### ១.២.២ ដីកាសម្រេចចាត់តាំងអ្នកជំនាញ

នៅពេលដែលវត្ថុដែលជាកម្មវត្ថុនៃការធ្វើកោសលវិច័យដែលមាននៅក្នុងសំណុំរឿង ចៅក្រមស៊ើបសួរត្រូវតែចេញដីកាសម្រេចចាត់តាំងអ្នកជំនាញ ដែលមានក្នុងប្រកាសក្រសួងយុត្តិធម៌ ឬអ្នកជំនាញក្រៅពីបញ្ជីថ្នាក់ជាតិ ចំពោះតែលក្ខខណ្ឌបច្ចេកទេសរបស់អ្នកជំនាញពិសេសក្នុងការធ្វើកោសលវិច័យទៅលើវត្ថុនោះតែម្តង ដែលគ្មានអ្នកជំនាញក្នុងបញ្ជីថ្នាក់ជាតិ។ ការធ្វើកោសលជាមួយនឹងដីកាសម្រេចចាត់តាំងអ្នកជំនាញ។

### ១.២.៣ លទ្ធផលនៃការធ្វើកោសលវិច័យ

ចៅក្រមស៊ើបសួរ ដែលបានចាត់តាំងអ្នកជំនាញឱ្យបំពេញនូវកិច្ចបច្ចេកទេសផ្នែកកោសលវិច័យទៅលើវត្ថុតាង ឬស្លាកស្នាមអ្វីមួយដែលខ្លួនបានសង្ស័យថាមានការពាក់ព័ន្ធនឹងបទល្មើសនិងសំណុំរឿងដែលកំពុងមានចំណាត់ការនោះ។ ម្យ៉ាងទៀតដោយខ្លួនមិនអាចវិនិច្ឆ័យបានដោយប្រើភ្នែកទទេថា តើវត្ថុតាងនោះ ឬស្លាកស្នាមនោះមានភាពត្រូវគ្នាជាមួយនឹងអំពើជនត្រូវចោទបានប្រព្រឹត្តឬមិនមែន? ដើម្បីបញ្ជាក់អំពីពិរុទ្ធរបស់ជនត្រូវចោទ។ ដោយសារវត្ថុតាងមួយចំនួនមានតែវិទ្យាសាស្ត្រ និងឯកទេសផ្នែកនោះតែប៉ុណ្ណោះដែលអាចមានចំណេះដឹង និងបទពិសោធន៍អំពីកម្មវត្ថុដែលត្រូវធ្វើកោសលវិច័យ។

អ្នកជំនាញដែលត្រូវបានខ្លួនចាត់តាំងឱ្យបំពេញកិច្ចផ្នែកបច្ចេកទេស ក្រោយពីការបំពេញភារកិច្ចរួចហើយត្រូវតែបញ្ជូននូវៈ របាយការណ៍ស្តីពីការធ្វើកោសលវិច័យ សេចក្តីសន្និដ្ឋាននិងវត្ថុតាងដែលនៅសល់នោះ មកខ្លួនវិញតាមការកំណត់ពេលវេលាជាក់លាក់របស់ខ្លួនក្នុងដីកាសម្រេចចាត់តាំងអ្នកជំនាញ។ នៅពេលដែលដល់ការកំណត់អ្នកជំនាញត្រូវតែបញ្ជូនលទ្ធផលនោះមកចៅក្រមស៊ើបសួរវិញ ករណីមិនឃើញ ចៅក្រមស៊ើបសួរ អាចធ្វើការដាស់តឿន អ្នកជំនាញឱ្យបំពេញកិច្ចរបស់ខ្លួនឱ្យចប់ និងប្រគល់នូវលទ្ធផលមកខ្លួនឱ្យបានឆាប់ហ័ស។ ក្រោយពេលដែលបានទទួលនូវលទ្ធផល និងសេចក្តីសន្និដ្ឋានពីអ្នកជំនាញនោះ ចៅក្រមស៊ើបសួរ អាចវាយតម្លៃបានគ្រប់គ្រាន់នូវវត្ថុតាងនោះនិងបង្ហាញភាពស៊ីចង្វាក់នៃអំពើដែលជនត្រូវចោទបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបទល្មើសដូចដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់ និងការវិនិច្ឆ័យផ្ទាល់ខ្លួនឈានដល់ការសម្រេចសេចក្តីមួយត្រឹមត្រូវចំពោះជនត្រូវចោទ។

## ផ្នែកទី២៖ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស

បើពីនិត្យមើលក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានពន្លេចឡើងនូវអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការធ្វើការស្រាវជ្រាវទៅលើដែនសមត្ថកិច្ចផ្សេង ក្រៅពីដែនសមត្ថកិច្ចរបស់ខ្លួនបានក្នុងនោះទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលមានចែងនៅក្នុង **ផ្នែកទី៨ ដីកាចាត់ឱ្យស៊ើបសួរជំនួស នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

អ្វីទៅជា"**ដីកាចាត់ឱ្យស៊ើបសួរជំនួស**"?

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត ហើយក៏អាចចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរបានដែរ។[75] ក្នុងន័យនេះដែលជាលក្ខណៈទ្រឹស្តីអាចឱ្យអត្ថន័យបានថា ដីកាចាត់ឱ្យស៊ើបសួរជំនួស គឺជាការផ្ទេរនូវអំណាចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចទៅចៅក្រមផ្សេង ឬចៅក្រមស៊ើបសួរដទៃទៀតឱ្យបំពេញកិច្ចស្រាវជ្រាវបទល្មើសជំនួសខ្លួន គឺផ្តល់ទាំងសិទ្ធិនិងកាតព្វកិច្ចដែលខ្លួនប្រើប្រាស់ទាំងអស់ដូចគ្នា។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានធ្វើឡើងជាពីរបែបគឺ៖ ដីកាចាត់ឱ្យស៊ើបសួរជំនួសទៅចៅក្រមស៊ើបសួរផ្សេង និងដីកាចាត់ឱ្យស៊ើបសួរជំនួសចាត់តាំងឱ្យមន្ត្រីនគរបាលយុត្តិធម៌។

### កថាខណ្ឌទី១៖ ការចាត់តាំងចៅក្រមផ្សេងឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរដែលកំពុងបំពេញសំណុំរឿងក្តី ដែលមាននៅក្នុងដៃខ្លួន ហើយយល់ឃើញថាមានភាពចាំបាច់សម្រាប់ធ្វើកិច្ចអ្វីមួយដើម្បីបំភ្លឺនូវអង្គហេតុ ឬភាពសង្ស័យរបស់ខ្លួន ប៉ុន្តែខ្លួនមិនអាចចុះទៅដោយផ្ទាល់បានដោយសារតែកាលៈទេសៈឬស្ថានភាពក្នុងការធ្វើដំណើរពិបាក និងត្រូវចំណាយក្នុងការចុះទៅទីកន្លែងឆ្ងាយៗពីទីកន្លែងបទល្មើស។ ដោយហេតុផលទាំងនេះចៅក្រមស៊ើបសួរអាចពឹងពាក់ចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើកិច្ចការជំនួសខ្លួនបានតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមានការចាត់តាំងចៅក្រមផ្សេងឱ្យប្រតិបត្តិការជំនួសនេះត្រូវបានបែងចែកជាពីរផងដែរ៖ ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច និងការចាត់តាំងចៅក្រមនៃសាលាដំបូងផ្សេងទៀត។ ក្នុងការចាត់តាំងចៅក្រមដែលមានសមត្ថកិច្ចនៅសាលាដំបូងដូចគ្នា ឬចៅក្រមផ្សេងដែលពុំស្ថិតនៅក្នុងសាលាដំបូងតែមួយ តើមានលក្ខណៈដូចគ្នាឬខុសគ្នាយ៉ាងណា ហើយសិទ្ធិនិងកាតព្វកិច្ចត្រូវតម្រូវយ៉ាងដូចម្តេចដែរ? ទាំងអស់នេះយើងនឹងធ្វើការបកស្រាយ ក៏ដូចជាលើកយកមកបង្ហាញទៅលើការចាត់តាំងចៅក្រមឬមន្ត្រីនគរបាលយុត្តិធម៌នៃចំណុចទាំងពីរនេះឱ្យបានក្បោះក្បាយ។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៩០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៣។

## ២.១.១ ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច

នៅក្នុងសាលាដំបូងរាជធានី-ខេត្ត នីមួយៗមានចៅក្រមដែលបំពេញការងារជាច្រើនរូបដើម្បីដោះស្រាយនូវវិវាទក៏ដូចជាបង្រ្កាបនូវបទល្មើសដែលកើតឡើង។ ចៅក្រមស៊ើបសួរក្រោយពីបានសិក្សាទៅលើសំណុំរឿងរបស់ខ្លួនហើយនោះ ខ្លួនយល់ឃើញថានូវមានការសង្ស័យ ឬពុំច្បាស់លាស់ទៅលើភស្តុតាងដើម្បីដាក់បន្ទុក ឬដោះបន្ទុកណាមួយ នោះមានការចាត់តាំងចៅក្រមសាលាដំបូងដែលខ្លួនកំពុងស្ថិតនៅជាមួយគ្នា អាចធ្វើទៅបានដោយសារតែមានភាពចាំបាច់ក្នុងករណីដែលខ្លួនមិនអាចបំពេញកិច្ចការស្រាវជ្រាវនោះបាន ក្នុងនោះដែលឃើញថាមានការចេញនូវដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ ទៅចៅក្រមដែលនៅក្នុងសមត្ថកិច្ចសាលាដំបូងជាមួយនឹងខ្លួននោះហើយចៅក្រមស៊ើបសួរដែលជាអ្នកកាន់សំណុំរឿងត្រូវចេញដីកាដោយមានបញ្ជាក់អំពីប្រភេទនៃកិច្ចស៊ើបសួរនោះឱ្យច្បាស់លាស់នឹងដាក់លាក់តាមការណែនាំដែលចាត់ទៅឱ្យចៅក្រមដែលជំនួសខ្លួន ដើម្បីធ្វើកិច្ចនោះបន្តតាមអំណាចនៃដីកាចាត់ឱ្យស៊ើបសួរជំនួសនេះផងដែរ។ **ឧទាហរណ៍៖** ក្នុងករណីចៅក្រមស៊ើបសួរធ្វើការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ទៅលើការធ្វើកំណត់ហេតុសួរចម្លើយ និងការចាត់ឱ្យចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅចៅក្រមម្នាក់ទៀតជាអាទិ៍ នេះមានន័យថាចៅក្រមស៊ើបសួរដែលទទួលនូវដីកានេះត្រូវអនុវត្តតែអំណាចធ្វើកំណត់ហេតុសួរចម្លើយ និងបង្គាប់ឱ្យចូលខ្លួនតែប៉ុណ្ណោះ។

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ហើយចៅក្រមរូបនេះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ។[76] ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវតែណែនាំឱ្យបានច្បាស់លាស់។

ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវតែមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ នឹងមានបោះត្រាផងដែរ។

ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេល។[77] ក្នុងស្នារតីនេះចង់បង្ហាញឱ្យឃើញនូវការប្រើប្រាស់នូវអំណាចជំនួស គ្នាទៅវិញទៅមករវាងចៅក្រមស៊ើបសួរ និងចៅក្រមផ្សេងដែលនៅក្នុងសាលាដំបូងតែមួយ ប៉ុន្តែមិនមែនប្រើប្រាស់ទៅតាមអំពើចិត្តឡើយ គឺធ្វើស្របទៅតាមការកំណត់ដែលមាននៅក្នុងដីកាដែលចាត់ឱ្យស៊ើបសួរជំនួសនោះ ស្របទៅតាមច្បាប់នីតិវិធីព្រហ្មទណ្ឌដែលផ្តល់ឱ្យ។ ក្នុងនោះដែលបើពិនិត្យ

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៥។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៤។

លើក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ជាក់ឱ្យកាន់តែច្បាស់ទៀតថាការអនុវត្តខ្លឹមសារនៃដីកានេះ គឺចៅក្រមស៊ើបសួរដែលទទួលការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស គឺប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចទៅនឹង ចៅក្រមស៊ើបសួរដែលជាអ្នកទទួលនូវសំណុំរឿងនោះផ្ទាល់ដែរ។

### ២.១.២ ការចាត់តាំងចៅក្រមសាលាដំបូងផ្សេងទៀត

ការចាត់តាំងចៅក្រមនៅសាលាដំបូងផ្សេងនេះ គឺស្របពេលដែលស្ថិតនៅក្នុងកាលៈទេសៈ ដែលចៅក្រមស៊ើបសួរដែលជាអ្នកទទួលបន្ទុកសំណុំរឿងពិបាកក្នុងការធ្វើចំណាត់ការ ទៅលើការស្រាវជ្រាវស្វែងរកនូវភាពពិតរបស់អង្គហេតុដែលខ្លួនបានសិក្សា ដោយសារតែជនត្រូវចោទពុំមានវត្តមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬអាចនិយាយបានថាដោយសារបទល្មើសកើតឡើងនៅលើដែនសមត្ថកិច្ចនៃសាលាដំបូងផ្សេងបែបនេះ ហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានរំលេចឡើងយន្តការថ្មីនេះឡើងដើម្បីស្វែងរកឱ្យឃើញនូវភាពពិតប្រាកដនិងផ្តល់នូវភាពយុត្តិធម៌ទៅដល់ជនរងគ្រោះថែមទាំងជនត្រូវចោទផងដែរ។ ស្របទៅតាមខ្លឹមសារនូវដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺមានលក្ខខណ្ឌក្នុងការអនុវត្តអំណាចដូចគ្នាទៅនឹងការចាត់តាំងទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសដែលចេញឱ្យចៅក្រមនៅសាលាដំបូងដូចគ្នានោះដែលបានបកស្រាយខាងលើផងដែរ។

**ឧទាហរណ៍៖** ចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យចៅក្រមនៅសាលាដំបូងខេត្តកណ្តាល ឱ្យបំពេញកិច្ច កោសលវិច័យ ធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង និងធ្វើការស្តាប់ចម្លើយសាក្សីជាអាទិ៍។

## កថាខណ្ឌទី២៖ ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យស៊ើបសួរជំនួស

យើងបានដឹងហើយថា មន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ ក្នុងនោះដែលមន្ត្រីនគរបាលមានតួនាទីក៏ដូចជាភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណនិងចាប់ខ្លួនជនល្មើសផងដែរ។ បើយើងពិនិត្យឱ្យកាន់តែស៊ីជម្រៅ ឃើញថាវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ពិតជាមានសារៈសំខាន់ណាស់ នៅគ្រប់ដំណាក់កាលទាំងអស់ក្នុងរឿងព្រហ្មទណ្ឌ។ គ្រាន់តែថា ភារកិច្ច នឹងអំណាចត្រូវបានកំណត់ជាក់លាក់នៅក្នុងដំណាក់កាលនីមួយៗ គឺថានៅដំណាក់កាលអយ្យការ មន្ត្រីនគរបាលមានតួនាទីផ្សេង នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីផ្សេង និងមិនតែប៉ុណ្ណោះនៅក្នុងដំណាក់កាលជំនុំជម្រះមន្ត្រីនគរបាលយុត្តិធម៌មានតួនាទីផ្សេងផងដែរ។ តាមតម្រូវការជាក់ស្តែងដើម្បីភាពងាយស្រួលក្នុងការស្រាវជ្រាវបទល្មើសមួយផ្នែកនោះ ចៅក្រមស៊ើបសួរច្រើនតែចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យបំពេញកិច្ចស្រាវជ្រាវណាមួយតាមលទ្ធផលដែលមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើទៅបាន។ យ៉ាង

ណាមិញ ក្នុងន័យនេះយើងនឹងធ្វើការបកស្រាយតែទៅលើតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានលើភារកិច្ចរបស់គាត់ ដែលត្រូវចាត់ឱ្យដោយចៅក្រមស៊ើបសួរតាមដីកាចាត់ឱ្យស៊ើបសួរជំនួសតែប៉ុណ្ណោះ។

### ២.២.១ ការចាត់តាំងមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៨( កំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យ) ដល់មាត្រា១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ។

ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរយើងត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះ។[78] ក្នុងការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិ ជំនួសទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួស គឺហាក់ដូចជាមានភាពល្អិតល្អន់ជាង ពីព្រោះថាមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ធ្វើការបំពេញភារៈកិច្ចរបស់ខ្លួនពេលនេះ គឺស្ថិតក្នុងការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបសួរ ជាអ្នកកំណត់អំពីសិទ្ធិដែលខ្លួនត្រូវធ្វើទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនេះផងដែល ត្រង់ចំណុចនេះចង់បង្ហាញថាមន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់ចៅក្រមស៊ើបសួរ។ មិនតែប៉ុណ្ណោះយើងឃើញថាចៅក្រមស៊ើបសួរ គឺខ្លួនអាចចាត់តាំងតែចំពោះមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចពាក់ព័ន្ធឱ្យធ្វើការស្រាវជ្រាវ ក៏ដូចជាប្រតិបត្តិការជំនួសខ្លួនផងដែលទាក់ទងទៅនឹងការពន្លាតសមត្ថកិច្ចក្នុងការស្រាវជ្រាវនេះ ក៏អាចធ្វើបានដែលប្រសិនបើចៅក្រមស៊ើបសួរគិតថាមានភាពចាំបាច់ក្នុងការស្វែងរកតម្រុយនូវភស្តុតាងដើម្បីបញ្ជាក់នូវភាពពិត។ មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី៣ និងទី៣ មាត្រា៦៨ (ការពន្លាតសមត្ថកិច្ចដែនដី)នៃក្រមនេះ។[79]អ្វីដែលសំខាន់សម្រាប់ការការចេញនូវដីកាឱ្យស៊ើបសួរជំនួស ដែលចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ធ្វើដែលស្ថិតនៅក្រោមការកំណត់ដោយដីកានេះ នឹងក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ និងដែលអាចនិយាយបានថាជាបញ្ជាដាច់ខាតដោយដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌។

### ២.២.២ ប្រតិបត្តិការតាមការចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

នៅក្នុងការប្រតិបត្តិការ ក៏ដូចជាការអនុវត្តទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺមានការចង្អុលបង្ហាញយ៉ាងច្បាស់លាស់ និងជាក់លាក់ទៅលើបុគ្គល ទីកន្លែងដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅស្រាវជ្រាវដោយមានការចុះនូវនិទ្ទេសដោយចៅក្រមស៊ើបសួរដែលបានចេញដីកានោះ។ ក្នុងនោះដែលយើងឃើញថា ការ

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៦។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៧។

ប្រតិបត្តិការនេះមានដូចជា ការធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវនិងការពិនិត្យ, វិធានទាក់ទងនឹងការស្តាប់ចម្លើយ ការឆែកឆេរនិងការចាប់យក, ការឃាត់ខ្លួននៅក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស, ការស្តាប់ទូរស័ព្ទជាអាទិ៍។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។[80] ក្នុងនោះដែលយើងឃើញថា ទាក់ទងនឹងការស្តាប់ចម្លើយដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ គឺធ្វើទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ ក្នុងនោះដែលយើងពិនិត្យទៅលើក្រមនិតិវិធីព្រហ្មទណ្ឌយើង គឺផ្តល់នូវសិទ្ធិអំណាចតែទៅតាមការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ចំពោះការស្តាប់ចម្លើយសាក្សី ដែលចៅក្រមស៊ើបសួរបានឱ្យស្តាប់ចម្លើយជំនួសអាចធ្វើការកោះហៅសាក្សីឱ្យចូលមកចំពោះមុខខ្លួនបាន តែក្នុងករណីរឹងទទឹងមិនព្រមចូលខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំបញ្ជាឱ្យចូលខ្លួន ចំពោះមុខចៅក្រមស៊ើបសួរបាន។ ករណីដែលស្តាប់ចម្លើយរបស់សាក្សីណាមួយហើយបានលេចឡើងតម្រុយពិរុទ្ធភាពលើជននោះគឺត្រូវបញ្ឈប់និងរាយការណ៍ជាបន្ទាន់ដល់ចៅក្រមស៊ើបសួរ។ ចំពោះវិធានការនៃការស្រាវជ្រាវ ក៏ដូចជាការអនុវត្តរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺអនុវត្តទៅតាមបទប្បញ្ញត្តិរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា១៧៨។

# ជំពូកទី៣

# ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី៣

# ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស បើសិនជាចៅក្រមស៊ើបសួរយល់ឃើញថាគ្មានប្រយោជន៍អ្វីដល់កិច្ចនីតិវិធីដែលតម្រូវឱ្យចៅក្រមស៊ើបសួរស្វែងរកភស្តុតាង ដាក់បន្ទុក ឬដោះបន្ទុកទៀតទេនិងគ្មានលទ្ធផលអ្វីលើសពីកិច្ចដែលបានធ្វើកន្លងមក ហើយចៅក្រមស៊ើបសួរអាចបិទស៊ើបសួរត្រឹមតែកិច្ចដែលខ្លួនបានធ្វើកន្លងមកនោះ។ ការបញ្ចប់កិច្ចស៊ើបសួរដែលមានលក្ខណៈពិសេសជាងគេ គឺការទទួលមរណៈភាពរបស់ជនត្រូវចោទការស៊ើបសួរបានកន្លងហួស០១ឆ្នាំ ដែលភាគីពាក់ព័ន្ធបានស្នើសុំ និងការយល់ឃើញរបស់ខ្លួនផ្ទាល់ដល់ពេលវេលាដែលត្រូវបញ្ចប់។[81]

ចំពោះការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសអាចផ្តល់នូវគុណសម្បត្តិ ច្រើនជាងបន្តក្នុងការស្រាវជ្រាវដែលគ្មានសង្ឃឹមថាអាចបង្ហាញអ្វីៗលើសពីភស្តុតាងដែលមានក្នុងសំណុំរឿង។ ការផ្តល់នុវយុត្តិធម៌ដល់ជនដែលជាភាគីព្រហ្មទណ្ឌផងដែរ[82] ដោយសារគោលការណ៍មួយបានលើកឡើងថាភាពយឺតយ៉ាវ នៃការចាត់ការរឿងក្តីជាភាព "ភាពអយុត្តិធម៌" ដែលចៅក្រមស៊ើបសួរ គួរតែបិទការស្រាវជ្រាវរបស់ខ្លួនដើម្បីអាច បញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬលើកលែងចោទ និងសម្រេចអំពីការប្រគល់វត្ថុតាងដែលបានចាប់យក( ប្រសិនបើមាន) ដល់ភាគីដែលមានសិទ្ធិលើវត្ថុតាង ករណីវត្ថុតាងមានលក្ខខណៈគ្រោះថ្នាក់ដល់សង្គម ឬមានភាពចាំបាច់សម្រាប់ដាក់បន្ទុកជនត្រូវចោទមិនអាចប្រគល់វិញបានឡើយ។

## ផ្នែកទី១៖ នីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស

ដើម្បីអាចបញ្ចប់នូវកិច្ចស្រាវជ្រាវបទល្មើសដែលចៅក្រមស៊ើបសួរ បានបំពេញកន្លងមកក្នុងភាពជាតួអង្គនៅកណ្តាលនៃភាគី ដើម្បីបង្ហាញនូវការពិតដែលបានលាក់បាំងពីក្រោយហេតុការណ៍ផ្សេងៗដែលបានកើតឡើងហើយដល់ពេលការពិតត្រូវបានបង្ហាញចៅក្រមស៊ើបសួរ ត្រូវតែបង្ហាញការពិតដោយផ្អែកទៅលើភស្តុតាងដែលខ្លួនស្រាវជ្រាវនេះ។ ដើម្បីអាចបង្ហាញនូវការពិតបានចៅក្រមស៊ើបសួរត្រូវតែបញ្ចប់នូវកិច្ចរបស់ខ្លួនហើយនោះ និងប្រមូលគ្រប់ភស្តុតាងដែលបានស្រាវជ្រាវនោះធ្វើកន្លងមក ដើម្បីធ្វើជាមូលដ្ឋានក្នុងការពិចារណានិងសម្រេចសេចក្តី។ ចៅក្រមស៊ើបសួរមុននឹងសម្រេចបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួន ត្រូវតែជូនដំណឹងទៅគ្រប់ភាគីនៃបទល្មើសដែលមានក្នុងសំណុំរឿងគោលបំណងដើម្បីប្រាប់អំពីសិទ្ធិដែលអាចស្នើសុំឱ្យចៅក្រមស៊ើបសួរ បំពេញកិច្ច

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៨៦។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១៦១។

ស្រាវជ្រាវបន្ថែម ឬយល់ស្របជាមួយអ្វីដែលចៅក្រមស៊ើបសួរបានសម្រេចបញ្ចប់កិច្ចស្រាវជ្រាវដោយផ្អែកទៅលើភស្តុតាងដែលបានរកឃើញក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌកន្លងមក។

## កថាខណ្ឌទី១៖ ដីកាបញ្ជូនពត៌មាន និងលិខិតជូនដំណឹងបញ្ចប់កិច្ចស្រាវជ្រាវ

ដោយអនុលោមក្រមនីតិវិធីព្រហ្មទណ្ឌបាន តម្រូវឱ្យចៅក្រមស៊ើបសួរត្រូវតែធ្វើការជូនដំណឹងធ្វើជាលាយលក្ខណ៍អក្សរ ទៅភាគីក្នុងកិច្ចស្រាវជ្រាវរបស់ខ្លួន ជាពិសេសតំណាងអយ្យការ ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ។ ដោយមានដីកាបញ្ជូនពត៌មានទៅតំណាងអយ្យការដែលធ្វើការចោទប្រកាន់ លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ(ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ឬជនរងគ្រោះនិងមេធាវីការពារសិទ្ធិ និងតំណាងដោយអាណត្តិ)។

### ១.១.១ ដីកាបញ្ជូនពត៌មានទៅអយ្យការ

កាលណាដែលចៅក្រមស៊ើបសួរសម្រេចចិត្តក្នុងការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសដែល បើកការស្រាវជ្រាវដោយព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញា មកខ្លួនជាចៅក្រមស៊ើបសួរត្រូវតែជូនដណ្តឹងអំពីកិច្ចដែលខ្លួនបម្រុង នឹងបញ្ចប់តាមរយៈដីកាបញ្ជូនពត៌មានទៅព្រះរាជអាជ្ញា។ ដើម្បីទទួលយោបល់វិញថាតើការសម្រេចចិត្តរបស់ខ្លួននោះមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅសម្រាប់បញ្ចប់កិច្ចស្រាវជ្រាវនោះ ឬព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់នោះ អាចយល់ឃើញថាសំណុំរឿងមិនទាន់ពេលលេញហើយមានការបញ្ចេញយោបល់មិនឯកភាព និងអាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស្រាវជ្រាវបន្ថែមទៅលើចំណុចណាមួយឡើងវិញ។ ករណីដែលព្រះរាជអាជ្ញា និងការសម្រេចរបស់ចៅក្រមស៊ើបសួរនោះមានន័យថាចៅក្រមស៊ើបសួរ និងបន្តនីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ខ្លួនបានហើយ។

### ១.១.២.លិខិតជូនដំណឹងដល់ភាគីក្នុងរឿងក្តី

ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌអាចជាដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនត្រូវចោទជាដើម។ កាលណានីតិវិធីនៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌបានដល់ទីបញ្ចប់ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងទៅភាគីពាក់ព័ន្ធ ដើម្បីទទួលដំណឹងអំពីការបញ្ចប់ការស៊ើបសួរ របស់ខ្លួនក្នុងគោលបំណងឱ្យភាគីអាចស្នើសុំឬធ្វើកិច្ចអ្វីមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍មុនពេលចៅក្រមស៊ើបសួរ បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យនិងធ្វើដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរវិញ រួចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសត្រឹមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬបញ្ជូនទៅជំនុំជម្រះ។

### ១.១.៣ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

ការបញ្ជូនសំណុំរឿងឱ្យពិនិត្យ ធ្វើនៅពេលដែលដីកាបញ្ជូនពត៌មានអំពីការបិទការស៊ើបសួរបានកន្លងផុតពីរថ្ងៃមកចៅក្រមស៊ើបសួរ ត្រូវតែចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅ ព្រះរាជអាជ្ញាឱ្យពិនិត្យ និងតំណាងអយ្យការត្រូវតែបន្តធ្វើដីកាសន្និដ្ឋានស្ថាពរមួយត្រឡប់មកចៅក្រមស៊ើបសួរវិញ។ ដែលដីកានោះគឺជាការបញ្ចេញមតិយោបល់របស់ព្រះរាជអាជ្ញាទៅលើសំណុំរឿងក្តីដែលចៅក្រមស៊ើបសួរបានស្រាវជ្រាវ និងភស្តុតាង មានក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដែលអាចធ្វើដីកាសន្និដ្ឋានស្ថាពរនោះមកចៅក្រមស៊ើបសួរ ដើម្បីជាមូលដ្ឋានឱ្យចៅក្រមស៊ើបសួរ បានដឹងអំពីមូលហេតុនៃការស្នើសុំ ឬសំណូមពររបស់តំណាងអយ្យការដែលអាចជាការស្នើសុំធ្វើការចោទប្រកាន់ កែប្រែបទចោទ ឬលើកលែងការចោទប្រកាន់។

### ១.១.៤ ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ

ដីកាសន្និដ្ឋានស្ថាពរ ជាការបញ្ចេញមតិក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ និងអង្គច្បាប់ផ្ទាល់ខ្លួនរបស់តំណាងអយ្យការនីមួយៗ ដែលបានធ្វើការចោទប្រកាន់ និងការបើកការស៊ើបសួរមកកាន់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្រាវជ្រាវបទល្មើសឱ្យមានលក្ខណៈពេញលេញ។ ការយល់ឃើញថាយ៉ាងណាជាគំនិតរបស់តំណាងអយ្យការ គ្មានអនុភាពដាក់កាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរសម្រេចតាមឡើយ។ ជាករណីពិសេសបញ្ញត្តិច្បាប់បានតម្រូវឱ្យចៅក្រមស៊ើបសួរត្រូវតែទទួលដីកាសន្និដ្ឋានស្ថាពរជាមុនសិន ទើបអាចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសបាន។ បើគ្មានដីកាសន្និដ្ឋានជាស្ថាពរទេ ចៅក្រមស៊ើបសួរមិនអាចបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួនបានឡើយ តែតំណាងអយ្យការគ្មានអនុភាពបដិសេធ មិនធ្វើការសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរនោះទេ មានន័យថាតំណាងអយ្យការត្រូវតែធ្វើដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរ។ ដីកាសន្និដ្ឋានស្ថាពរជាផ្នែកមួយដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើជាមូលដ្ឋាន ក្នុងការពិចារណាតែប៉ុណ្ណោះ ចំពោះការវិនិច្ឆ័យទៅលើបទល្មើសដែលខ្លួនបានស្រាវជ្រាវ និងការសម្រេចជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ។ យើងអាចសន្និដ្ឋានបានថា តំណាងអយ្យការអាចសន្និដ្ឋានស្ថាពរជាបីទម្រង់៖ ទម្រង់ស្នើសុំលើកលែងបទចោទប្រកាន់, ទម្រង់កែប្រែបទចោទ, ទម្រង់រក្សាការចោទប្រកាន់ដោយមានការស្នើសុំបញ្ជូនជនត្រូវចោទ ឬវត្ថុតាងទៅជំនុំជម្រះ។

#### ក. ប្តឹងសុំឱ្យលើកលែងការចោទប្រកាន់

ដីកាសន្និដ្ឋានស្ថាពរលើកលែងការចោទប្រកាន់ ជាកាលៈទេសៈពិសេសដែលតំណាងអយ្យការបានបើកការស៊ើបសួរ តែក្រោយពេលដែលចៅក្រមស៊ើបសួរ រកមិនឃើញថាមានពិរុទ្ធភាពរបស់ជនត្រូវចោទ ឬគ្មានសារតាជាតិគ្រប់គ្រាន់និងជនត្រូវចោទបានទទួលមរណៈភាពដែលមូលហេតុបណ្តឹងអាជ្ញាត្រូវរលត់។ តំណាងអយ្យការមិនអាចធ្វើការប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះបានឡើយ។ តែមានករណីខ្លះដែល

តំណាងអយ្យការធ្វើដីកាសន្និដ្ឋានលើកលែងបទចោទ ទោះបីជាបទល្មើសនោះមានព្យសនកម្មតិចតួចក្រោយពីពេលដែលចៅក្រមស៊ើបសួរបានធ្វើការស្រាវជ្រាវ និងមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីអំពើរបស់ជនត្រូវចោទបាន។

**ខ. ប្តឹងសុំឱ្យកែប្រែបទចោទ**

ដីកាសន្និដ្ឋានស្ថាពរដែលស្នើសុំឱ្យចៅក្រមស៊ើបសួរកែប្រែបទចោទខុសពីអ្វីៗ ដែលខ្លួនបានចោទប្រកាន់ពីមុនដំបូងដោយសារតែខ្លួនបានពិនិត្យ និងសំណុំរឿងដែលចៅក្រមស៊ើបសួរបានធ្វើការស្រាវជ្រាវឃើញថា វាមិនមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនត្រូវចោទ ដែលបានធ្វើការចោទប្រកាន់ និងការបើកការស៊ើបសួរមកចៅក្រមស៊ើបសួរ។ តែវាបែរជាបទល្មើសផ្សេងពីអង្គហេតុដំបូងដែលតំណាងអយ្យការបានសន្មត់ថាជាអំពើអ្វីមួយដែលបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌតែក្រោយមក យល់ឃើញថាវាមិនមែនជាបទល្មើស ដូចការចោទប្រកាន់ពីដំបូងដោយផ្អែកទៅលើភស្តុតាងដោយអាចជាសម្តីជនត្រូវចោទ សាក្សី ជនរងគ្រោះ ភស្តុតាងកោសលវិច្ច័យផ្សេងៗទៀតជាដើម។ ***ដូចជាករណី*** ៖ **ក** ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ "ប្រទស្តកេរ្តិ៍" តែក្រោយពីការស៊ើបសួរឃើញថា"ប៉ុនប៉ងរំលោភសេពសន្ថវៈ"តាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌទៅវិញ។

**គ. ប្តឹងសុំឱ្យបញ្ជូនទៅជំនុំជម្រះ**

ការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះជាការស្នើសុំឱ្យចៅក្រមស៊ើបសួរ សម្រេចចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿង ដែលខ្លួនបានចោទប្រកាន់នោះទៅចៅក្រមជំនុំជម្រះ ដោយគ្មានការកែប្រែការចោទប្រកាន់អ្វីឡើយ។ ម្យ៉ាងទៀតដោយសារតែការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរដែលមានភស្តុតាងនៅក្នុងសំណុំរឿងដែលខ្លួនបានពិនិត្យ ឃើញថាមិនមានអ្វីប្រែប្រួលទេ គឺប្តឹងសុំឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះតែម្តង។

## កថាខណ្ឌទី២៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ចៅក្រមស៊ើបសួរ ក្រោយពីបានទទួលសំណុំរឿងបញ្ជូនត្រឡប់មកវិញពីតំណាងអយ្យការត្រូវតែពិនិត្យទៅលើដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការក្នុងគោលបំណងត្រួតពិនិត្យតាមការស្នើសុំ និងការយល់ឃើញរបស់តំណាងអយ្យការដែលបានសម្រេចប្តឹងសុំ ក្នុងដីកាសន្និដ្ឋានស្ថាពរក្នុងទម្រង់ណាមួយជាមុនសិនទើបចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចវិនិច្ឆ័យថាត្រូវតែចេញដីកាដំណោះស្រាយសម្រេចយ៉ាងណាចំពោះអំពើនោះ។ ទោះបីជាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសន្និដ្ឋានបែបណានោះ មិនមែនជាកាតព្វកិច្ចបង្ខំចៅក្រមស៊ើបសួរនោះទេ។ ម្យ៉ាងទៀតបើសិនជាចៅក្រមស៊ើបសួរសម្រេចផ្ទុយពីការយល់ឃើញរបស់តំណាងអយ្យការនោះ ព្រះរាជ

អាជ្ញាអាចបន្តប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលប្រឆាំងនឹងដីកាដំណោះស្រាយចំពោះជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីឬជនរងគ្រោះ អាចប្តឹងបាន ដែលមានរយៈពេលនៃការប្តឹងតាមការកំណត់របស់ច្បាប់។[83]

### ១.២.១ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

ដីកាដំណោះស្រាយជាការវិនិច្ឆ័យនូវភស្តុតាងនិងតម្រុយផ្សេងៗ ដែលមានការពាក់ព័ន្ធរួមទាំងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ដែលជាមូលដ្ឋានក្នុងការពិចារណាសេចក្តីសម្រេចជាចុងក្រោយនៃការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។ជាគោលការណ៍ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ*(ការយល់ឃើញ)* ដោយចៅក្រមស៊ើបសួរមុននឹងឈានទៅដល់ការវិនិច្ឆ័យក្នុងសេចក្តីសម្រេចរបស់ខ្លួន ដោយពិនិត្យទៅលើកំណត់ហេតុផ្សេងតាមពីដំណាក់កាលនគរបាលនិងដំណាក់កាលរបស់អយ្យការ រួមទាំងយោងតាមកំណត់ហេតុធ្វើតេស្តកោសលវិនិច្ឆ័យ និងវត្ថុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿងដែលខ្លួនបានធ្វើការស្រាវជ្រាវកន្លងមក។ ការសម្រេចសេចក្តីមួយប្រកបដោយភាពយុត្តិធម៌ និងក្រៅពីការយល់ឃើញនានារួចមក រួមទាំងពិចារណាលើអំពើដែលជនត្រូវចោទបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តដោយផ្អែកទៅលើភស្តុតាង ចៅក្រមស៊ើបសួរអាចវិនិច្ឆ័យសម្រេចដូចជា៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះឬដីកាសម្រេចលើកលែងបទចោទ។

### ១.២.២ ការសម្រេចលើកលែងការចោទប្រកាន់

ការលើកលែងការចោទប្រកាន់ចំពោះជនត្រូវចោទ ចៅក្រមស៊ើបសួរ អាចធ្វើក្នុងការបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួនដោយច្បាប់បានចែងយ៉ាងច្បាស់សម្រាប់ការចេញដីកាដំណោះស្រាយ។ មូលហេតុដែលមានក្នុងបញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការនាំឱ្យបណ្តឹងអាជ្ញារលត់។ កាលណាមានមូលហេតុនោះនាំឱ្យមានការរំលត់បណ្តឹងអាជ្ញាតំណាងអយ្យការអាចធ្វើដីកាសន្និដ្ឋានលើកលែងបទចោទប្រកាន់ ចៅក្រមស៊ើបសួរត្រូវតែលើកលែងបទចោទដោយចេញដីកាលើកលែងការចោទប្រកាន់។ ករណីក្រៅពីនេះចៅក្រមស៊ើបសួរត្រូវតែមានភស្តុតាងជាក់លាក់ ដោយមានសំអាងនៅក្នុងដីការបស់ខ្លួននិងសម្រេចលើកលែងបទចោទដោយអាចយកមូលហេតុទាំងនេះដូចជា៖ ជនត្រូវចោទទទួលមរណៈភាព ជនត្រូវចោទមិនត្រូវបានស្គាល់អត្តសញ្ញាណ និងអង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់ តែវាមិនមែនជាបទល្មើស ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ចំពោះជនត្រូវចោទ ដោយចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងបទចោទ ចំពោះជនត្រូវចោទ ទោះបីគ្មានការឯកភាពពីតំណាងអយ្យការយ៉ាងណាក៏ដោយ។

ចំណែកឯការកែប្រែឬរក្សាការចោទប្រកាន់របស់តំណាងអយ្យការ គឺការសម្រេចតាមដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ នៅក្នុងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរ អាចមានការ

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៦៦។

យល់ឃើញថាអំពើដែលកើតឯងជាបទល្មើសផ្សេងគ្នាដោយផ្អែកទៅលើភស្តុតាង ឬការបកស្រាយអង្គច្បាប់ និងរួមទាំងអង្គហេតុផ្សេងពីតំណាងអយ្យការ។ ក្នុងករណីចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនសំណុំរឿងក្តីទៅជំនុំជម្រះដោយយល់ឃើញថា ដូចនឹងការយល់ឃើញរបស់តំណាងអយ្យការ ឬក៏អាចមានការយល់ឃើញដោយខ្វែងគំនិតគ្នាទៅលើបទល្មើសដែលកំណត់ ច្បាប់ព្រហ្មទណ្ឌក្នុងអង្គហេតុជាបទល្មើសដូចគ្នា។

ទោះបីជាមានការយល់ឃើញយ៉ាងណាក៏ដោយ អំពើដែលជាបទល្មើសដែលខុសពីការចោទប្រកាន់និងប្តឹងសុំតាមដីកាសន្និដ្ឋានស្ថាពរ ក៏គ្មានកាតព្វកិច្ចចងជើងចៅក្រមស៊ើបសួរនោះឡើយ។

### ១.២.៣ ការសម្រេចអំពីសិទ្ធិជនត្រូវចោទក្នុងឃុំ និងវត្ថុតាង

ជាគោលការណ៍ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបញ្ចប់នៅពេលដែល ដីកាដំណោះស្រាយបានចេញក្រោយពីការវិនិច្ឆ័យទៅលើវត្ថុតាងនិងរបាយការណ៍ ឬដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការដែលបានសម្រេចនិងបញ្ចេញយោបល់តាមបែបណានោះ គឺត្រូវសម្រេចដោយភក្តីភាពរបស់ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅជំនុំជម្រះ។[84] តែចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន (***ប្រសិនបើមាន***) និងសម្រេចអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ រហូតដល់ជនត្រូវចោទ ត្រូវបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ។ក្រោយពីរយៈពេល០៤ខែ កន្លងផុតត្រូវតែបានដោះលែងឱ្យជនត្រូវចោទមានសេរីភាពវិញលើកលែងតែបានការសម្រេចផ្សេងពីនេះ។ ការសម្រេចអំពីការឃុំខ្លួនឬប្រគល់វត្ថុតាងត្រូវធ្វើឡើងនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនទាំងអស់តែម្តង។

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៤០៧/០២៤,១០ សីហា ២០០៧,មាត្រា២៤៩។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អត្ថន័យនៃការស្រាវជ្រាវមួយនេះផ្តោតទៅលើកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ ក៏ដូចជាសិទ្ធអំណាចដែលទទួលបាននៅពេលដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅពេលដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះជាដើម។ អ្វីដែលសំខាន់បំផុតនៅក្នុងដំណើរការនីតិវិធីនេះ គឺជាការស្រាវជ្រាវស្វែងរកការពិតនៃអង្គហេតុដែលជារឿងក្តីព្រហ្មទណ្ឌដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាធានាឲ្យបាននូវជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋនៅក្នុងសង្គមទាំងមូលក្នុងការស្វែងរកយុត្តិធម៌ មានតម្លាភាព និងធានាឲ្យបាននូវសមភាពក្នុងការទទួលនូវការផ្តល់យុត្តិធម៌ ពីសំណាក់ស្ថាប័នតុលាការទៅប្រជាពលរដ្ឋទូទៅទាំងអស់ដោយមិនប្រកាន់នូវឋានៈតួនាទី កម្រិតជីវភាព និងកម្រិតចំណេះដឹង។

ចំណុចទាំងនេះ បានធ្វើឲ្យចៅក្រមស៊ើបសួរ មានតួនាទីសំខាន់ត្រង់ថាប្រព័ន្ធចៅក្រមស៊ើបសួរជាប្រព័ន្ធមួយដែលស្ថិតនៅចន្លោះកណ្តាលនៃដំណាក់កាលផ្តើមចោទប្រកាន់របស់ព្រះរាជអាជ្ញា ក្នុងការស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមជំនុំជម្រះ។ បង្ហាញឲ្យឃើញថាដំណាក់កាលស៊ើបសួរនេះជាស្នូលនៃកិច្ចនីតិវិធីនៃតុលាការព្រហ្មទណ្ឌ ដោយចៅក្រមស៊ើបសួរជាតួអង្គម្នាក់ ដែលឯករាជ្យស្ថិតនៅកណ្តាល ដែលច្បាប់ប្រគល់ឲ្យដោយមិនលម្អៀងទៅរកភាគីណាម្ខាង នៃរឿងក្តីឡើយ។ ចំពោះកាតព្វកិច្ចរបស់គាត់ គឺស្រាវជ្រាវទៅលើភស្តុតាងទាំងឡាយ រួមមានភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរ ក៏ត្រូវធ្វើកិច្ចស្រាវជ្រាវដោយផ្អែកជាចម្បងលើមូលដ្ឋានច្បាប់ និងការវិនិច្ឆ័យលើភាពសមហេតុផលប្រកបដោយយុត្តិធម៌សមស្របតាម គុណធម៌ សីលធម៌ និង វិជ្ជាជីវៈ មិនមែនសុទ្ធតែតម្រូវធ្វើការជូនដំណឹង ដល់ព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួរថ្មីនោះទេ គឺនៅក្នុងករណីមួយនៅពេលដែលកំពុងដំណើរការនៃកិច្ចនីតិវិធីស្រាប់តែ ចៅក្រមស៊ើបសួរគាត់រកឃើញនូវភស្តុតាងថ្មីដែលត្រឹមតែជាស្ថានទម្ងន់ទោសនៃបទល្មើសដែលព្រះរាជអាជ្ញាចោទតាមរយៈដីកា។ បន្ទាប់ពីចៅក្រមស៊ើបសួរ បានពិនិត្យឃើញនូវតម្រុយពិរុទ្ធភាពរបស់ជនល្មើស ភស្តុតាងដែលប្រមូលបាន និងលទ្ធភាពមួយដែលខ្លួនយល់ថាអាចបង្ហាញនូវការពិតបានហើយនោះ ចៅក្រមស៊ើបសួរចេញដីកាមួយ ហៅថាដីកាដំណោះស្រាយ ដើម្បីជាកិច្ចបញ្ចប់នីតិវិធី។

# អនុសាសន៍

ដើម្បីជាការផ្តល់គំនិតក្នុងគោលបំណងមួយ ដែលធ្វើយ៉ាងណាឱ្យប្រព័ន្ធនៃការស្រាវជ្រាវក៏ដូចជាសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការស្វែងរកការពិតប្រកបដោយសុក្រិត្យភាព តម្លាភាព សមភាព និងធានាឱ្យមានភាពជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋក៏ដូចជា ធានានូវភាពស្អាតស្អំរបស់ស្ថាប័នតុលាការដែលមានតួនាទីផ្តល់នូវសេវាយុត្តិធម៌ផងដែរ។ គឺត្រូវរៀបចំអោយមានមន្ទីរស៊ើបសួរមួយច្បាស់លាស់ ដែលបំពេញតែកិច្ចស៊ើបសួរ និងទទួលបណ្តឹងពីតំណាងអយ្យការ ឬបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែប៉ុណ្ណោះដែលជាសមត្ថកិច្ចដាច់ដោយឡែក។ កាតព្វកិច្ចក្នុងការស៊ើបសួរមិនត្រូវមានការថ្លោះធ្លោយនោះឡើយដែលវាសំខាន់ណាស់ ចាំបាច់ឱ្យចៅក្រមស៊ើបសួរមានសមត្ថភាពខ្ពស់ខាងផ្នែកទ្រឹស្តីច្បាប់ និងបច្ចេកទេសខាងផ្នែកចិត្តសាស្ត្រក៏ដូចជាយុទ្ធសាស្ត្រក្នុងការប្រត្តិបត្តិការនៃកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរ ដូច្នេះចៅក្រមស៊ើបសួរត្រូវតែមានវគ្គបណ្តុះបណ្តាល ជាពិសេសទៅលើបច្ចេកទេសស្រាវជ្រាវ, ស៊ើបសួរ និងបទពិសោធន៍ក្នុងវិស័យព្រហ្មទណ្ឌ។ បង្កើតឱ្យមានមន្ទីរពិសោធន៍មួយស្ថិតក្រោមមន្ទីរស៊ើបសួរ និងមានមន្ត្រីជំនាញដើម្បីជាជំនួយក្នុងកិច្ចការបច្ចេកទេសធ្វើកោសលវិច័យ ទៅលើភស្តុតាងដែលពាក់ព័ន្ធនឹងបទល្មើស។ មានក្រឡាបញ្ជីសមាមាត្រទៅនឹងចំនួនចៅក្រម ដែលបានមកបំពេញភារកិច្ចក្នុងឋានៈជាចៅក្រមស៊ើបសួរ។

ក្នុងឋានៈជាចៅក្រមស៊ើបសួរ ត្រូវមានការផ្តល់កិច្ចសហការចូលរួម ពីគ្រប់ស្ថាប័នដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងផ្តល់នូវកងកម្លាំង និងមន្ត្រីជំនាញតាមតម្រូវការរបស់ចៅក្រមទទួលបន្ទុកកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរមិនអាចប្រើប្រាស់អំណាចរបស់ខ្លួនដោយមិនមានការចូលរួមសហការពីស្ថាប័ននិងបុគ្គលពាក់ព័ន្ធទេ។ ដោយឡែកចៅក្រមស៊ើបសួរត្រូវតែជៀសវាងឱ្យបាននូវអគតិទាំង៤ ដើម្បីធ្វើឱ្យការវិនិច្ឆ័យនូវសេចក្តីសម្រេចណាមួយប្រកបដោយភាពយុត្តិធម៌ និងគុណតម្លៃនៃគោលការណ៍យុត្តិធម៌ និងភាពសុចរិត ដើម្បីធានាបានថាតុលាការមានប្រព័ន្ធស៊ើបសួរដ៏រឹងមាំនឹងច្បាស់លាស់។ នៅពេលដែលប្រព័ន្ធស៊ើបសួរមានភាពរឹងមាំ និងស្ថិតនៅក្នុងស្ថានភាពដែលជាជំហច្បាស់លាស់ហើយនោះទើបការស៊ើបសួរប្រកបដោយភាពកក់ក្តៅ សម្រាប់ភាគីដែលមកពឹងតុលាការដើម្បីស្វែងរកយុត្តិធម៌ជូនខ្លួន។ មិនតែប៉ុណ្ណោះភាពរឹងមាំ និងច្បាស់លាស់ទាំងនេះនឹងធ្វើឱ្យសេចក្តីសម្រេចរបស់តុលាការប្រកបដោយភាពត្រឹមត្រូវដែលផ្តល់នូវសាលក្រមចេញទៅប្រកបដោយប្រសិទ្ធិភាពរឹងមាំតាមផ្លូវច្បាប់។

ជាចុងក្រោយក្នុងការលើកឡើងក្នុងអនុសាសន៍ខាងលើគឺមានគោលបំណងតែម្យ៉ាងគត់ គឺដើម្បីធ្វើឱ្យប្រព័ន្ធស៊ើបសួររបស់ប្រទេសកម្ពុជាយើងមានស្តង់ដា ដើម្បីជាទីទុកចិត្តរបស់ប្រជាពលរដ្ឋមកលើស្ថាប័នតុលាការដែលជាស្ថាប័នស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាននិងគ្រប់ស្រទាប់វណ្ណៈ។

# ឯកសារយោង

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស /រកម/០៨០៧/០២៤,១០ សីហា ២០០៧។
- ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
- ឯកសារជំនួយស្មារតី ផ្សព្វផ្សាយ ក្រមនីតិវិធីព្រហ្មទណ្ឌ កើត រិទ្ធ។
- ចក សម្បត្តិ *"ការដាក់ឱ្យស្ថិតក្រោមការពិនិត្យខ្លឹមសារនៃប្រព័ន្ធចៅក្រមស៊ើបសួរ"*,ការផ្សព្វផ្សាយរបស់សមាគមន៍សាលាត្រាជូ ខែវិច្ឆិកា ឆ្នាំ២០០៧។
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត,*មេរៀននីតិវិធីព្រហ្មទណ្ឌ*,២០១៧។
- មាត្រា៣៨ អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចុះថ្ងៃទី២១ កញ្ញា ១៩៩៣។
- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចុះថ្ងៃទី១៤ កក្កដា ២០១៦។
- អ៊ិន បូផា.២០១៦. នីតិភស្តុតាង,ភ្នំពេញ។

# ឧបសម្ព័ន្ធ

**សាលាដំបូងខេត្តកណ្តាល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖......... អក
ចុះថ្ងៃទី...........................
ស៊ើបសួរលេខ ៖.............. សស
ចុះថ្ងៃទី.............................

# កំណត់ហេតុស្តីពី
# ការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣. ១៤៤. ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែកុម្ភៈ ថ្ងៃទីម្ភៃមួយ វេលាម៉ោងបួន និងប្រាំនាទីរសៀល

យើង...........................ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល

អមដោយ............................... ជាក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

បានឃើញបុគ្គលក្នុងនាមជាជនត្រូវចោទបានបង្ហាញខ្លួននៅចំពោះមុខយើង មានអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ......................ភេទ............ អាយុ.............។ឆ្នាំ ជនជាតិខ្មែរ មុខរបរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន...........................................................ឪពុកឈ្មោះ.................ម្តាយឈ្មោះ........................................ ជានីតិជន ទោសពីមុន....................។

លោក-លោកស្រី.........................................ជាមេធាវី នៃជនត្រូវចោទដែលត្រូវបានកោះហៅនៅ ថ្ងៃទី...........ខែ..............ឆ្នាំ..............ហើយដើម្បីឱ្យលោក-លោកស្រីមេធាវីអាចត្រៀមរៀបចំការពារកូនក្តីខ្លួនបាន ។

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬ អាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យរូបគាត់ ។

យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយ ខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន ។

ជននេះ បានប្រកាសប្រាប់ថា៖

ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យរូបខ្ញុំ

ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬ អាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬ អាចឱ្យយើងសួរចម្លើយក៏បាន ។

ជននេះ បានប្រកាសប្រាប់ថា៖ .......................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

លោក-លោកស្រី មេធាវី៖ ...................................បានផ្តល់សេចក្តី កត់សម្គាល់ការពារថា

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឱ្យ ស្ថិតនៅក្រោមការពិនិត្យ៖

ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឱ្យដឹង ។

ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបទល្មើស៖ ហិង្សាដោយចេតនា

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឱ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំ មោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្តឹង ឧទ្ធរណ៍ តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេល នៃដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខណ្ឌ ដែល មានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិ ក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិន បើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមាន សំណើសុំ យើងនឹងចាត់តាំងមេធាវីមួយរូបជូន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបាន ជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឱ្យចាត់តាំងមេធាវីឱ្យ) ។

ជនត្រូវចោទ បានប្រកាសប្រាប់ថា៖

ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យរូបខ្ញុំ

ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឱ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិ នៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចឃុំខ្លួនគាត់បណ្តោះអាសន្ន។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឱ្យនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់ឱ្យគាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព ។

យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន ( ឱ្យនៅក្រៅឃុំ ) ។

យើងបានប្រាប់ដល់ជនត្រូវចោទថា៖

-គាត់ត្រូវប្រកាសប្រាប់អំពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬ ជា អាស័យដ្ឋាន របស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឱ្យគាត់ ប្រសិនបើគាត់អាចផ្តល់ឱ្យភ្លាមនូវការព្រមព្រៀង ជាលាយលក្ខណ៍អក្សររបស់តតិយជននោះ ។

-អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ..............................

..........................................................................................................................................

..........................................................................................................................................

ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម៖

អាសយដ្ឋាននេះ ជា៖ អាសយដ្ឋានផ្ទាល់ខ្លួន

អាសយដ្ឋានរបស់ ៖ ..........................................

យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា៖

-រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់ យើងគ្រប់ការផ្លាស់ប្តូរអាស័យ ដ្ឋាន ដែលបានប្រកាសប្រាប់ខាងលើដោយការប្រកាសជាថ្មី ឬ ដោយលិខិតអនុសិដ្ឋ

-គ្រប់ការជូនដំណឹង ឬ ការឱ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋាន ដែលបានប្រកាស ប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ ។

យើងបានឱ្យជនត្រូវចោទឱ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះហើយបើមិនបដិសេធគ្រង់ចំណុចណាទេឱ្យចុះហត្ថលេខា ឬ ផ្តិតមេដៃលើកំណត់ហេតុនេះ ។

បញ្ឈប់កំណត់ហេតុនៅម៉ោងបួន និងដប់នាទីរសៀល នាថ្ងៃខែឆ្នាំដដែល។

**ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ......... អក
ចុះថ្ងៃទី១២.០៤.២០២០
ស៊ើបសួរលេខ.......... សស
ចុះថ្ងៃទី.....................

# កំណត់ហេតុស្ដីពី
# ការសួរចម្លើយជនត្រូវចោទ

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែឧសភា ថ្ងៃទីប្រាំបី វេលាម៉ោងដប់ និងប្រាំបួននាទីព្រឹក

យើង......................................ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក..................... ជាក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

បានឃើញបុគ្គលក្នុងនាមជាជនត្រូវចោទបានបង្ហាញខ្លួននៅចំពោះមុខយើង មានអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ...........................ភេទប្រុស អាយុ.......ឆ្នាំ ជនជាតិខ្មែរ មុខរបរ...........។មានទីកន្លែងកំណើត....................... និងទីលំនៅបច្ចុប្បន្ន........................... ឪពុកឈ្មោះ...................ម្ដាយឈ្មោះ..........................(រស់) ជានីតិជន ទោសពីមុន..........។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឱ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលតំណាងអយ្យការបានប្ដឹង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖............ ដកសស ចុះថ្ងៃទី....... ខែ.......... ឆ្នាំ២០២០ ដែលជាហេតុនាំឱ្យជននេះត្រូវដាក់ស្ថិតនៅក្រោមការឃុំខ្លួនតាមដីកាសម្រេចលេខ.................... ដកសឃខ ចុះថ្ងៃទី........... ខែ........... ឆ្នាំ២០២០។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា ៖

សួរ-ឆ្លើយ ៖ ខ្ញុំបានដឹងពីបទចោទប្រកាន់ខ្ញុំហើយ។

-ខ្ញុំអាចឆ្លើយដោយខ្លួនឯងបានដោយពុំចាំបាច់មានមេធាវីអមខ្ញុំទេ។

-ខ្ញុំសូមរក្សាចម្លើយដែលខ្ញុំបានឆ្លើយនៅមុខប៉ូលីស កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ទុកនៅដដែល ដោយមិនមានកែប្រែអ្វីឡើយ ។ ខ្ញុំសូមរក្សាចម្លើយដែលបានឆ្លើយនៅមុខតំណាងអយ្យការ កាលពីថ្ងៃ១២ ខែមេសា ឆ្នាំ២០២០ ទុកនៅដដែល តែសុំបដិសេធត្រង់ចំណុចថា "ខ្ញុំទទួលស្គាល់ថ្នាំញៀនជារបស់ខ្ញុំ គឺទិញពីចុងព្រែក ស្រុកមុខកំពូល ០១ កញ្ចប់តូច តម្លៃ ៣ ម៉ឺនរៀល គោលបំណងយកមកប្រើប្រាស់ជាមួយឈ្មោះ" ដោយសារពេលនោះគាត់មិនបានអានឱ្យខ្ញុំស្ដាប់។

សួរ-ឆ្លើយៈ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ម៉ោងប្រហែលប្រាំបីព្រឹក ខ្ញុំបានជិះម៉ូតូឌុបទៅផ្ទះរបស់ឈ្មោះ...........ដើម្បីយកម៉ូតូរបស់ខ្ញុំ ដែលឈ្មោះ............ខ្ចីឌុបឈ្មោះ..................ទៅផ្ទះពីព្រឹកម៉ោងប្រហែលប្រាំមួយជាងពេលទៅដល់ផ្ទះរបស់ឈ្មោះ..............ក៏បានជួបឈ្មោះ...........តែមិនឃើញឈ្មោះ..................ទេ គឺវាជិះម៉ូតូចេញទៅក្រៅបាត់។ ហើយខ្ញុំក៏បានអង្គុយលេងជាមួយឈ្មោះ..................... ដល់ចំណុចភូមិក្រងស្វាយ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្ដាល ស្រាប់តែមានស

ម្ចាស់កិច្ចឃាត់ឆែកឆេរកឃើញថ្នាំញៀនចំនួន ០២ (ពីរ) កញ្ចប់តូច នៅនឹងខ្លួនរបស់ឈ្មោះ .............ចំនួន ០១ (មួយ) កញ្ចប់ និងនៅខ្លួនរបស់ឈ្មោះ...........ចំនួន ០១ (មួយ) កញ្ចប់ ។

សួរ-ឆ្លើយៈ ខ្ញុំសំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

បញ្ឈប់កំណត់ហេតុនេះនៅម៉ោងដប់ និងសែសិបប្រាំបីនាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល។

យើងបានឱ្យជនត្រូវចោទ អានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ត្រាចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬឱ្យផ្តិតមេដៃលើកំណត់ហេតុនេះ។

**ជនត្រូវចោទ មេធាវី អ្នកបកប្រែ ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ:........... អក
ចុះថ្ងៃទី............. ខែ....... ឆ្នាំ២០២០
ស៊ើបសួរលេខៈ..............
ចុះថ្ងៃទី........ ខែ......... ឆ្នាំ២០២០

# កំណត់ហេតុ
# ស្ដីពីការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែកុម្ភៈ ថ្ងៃទីម្ភៃមួយ វេលាម៉ោងបួន និងដប់ពីរនាទីរសៀល

យើង............................................ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក............................ជាក្រឡាបញ្ជី

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.............ដក.ដស/២០២០ ចុះថ្ងៃទី........ ខែ........... ឆ្នាំ២០២០

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម:

ឈ្មោះ......................ភេទប្រុស អាយុ.........ឆ្នាំ ជនជាតិខ្មែរ មុខរបរ............... ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន..........................................................ឪពុកឈ្មោះ............................ម្ដាយឈ្មោះ.......................... ជានីតិជន ទោសពីមុន................................។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

□ ដោយមានលោក/លោកស្រី.................ជាមេធាវី ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬ ដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយ នឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូង។

យើងបានប្រាប់ដល់ជនត្រូវចោទថា:

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ជនត្រូវចោទ បានប្រកាសប្រាប់ថា:

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន:

□ ត្រូវបានធ្វើ

□ ត្រូវបានលើកទៅថ្ងៃទី............ខែ............ឆ្នាំ.............តាមសំណូមពររបស់

.........................................................................................................................................

តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម:

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

ជនត្រូវចោទបានបង្ហាញសេចក្ដីសង្កេតរបស់ខ្លួន ដូចខាងក្រោម

.............................................................................................................................

.............................................................................................................................

.............................................................................................................................

...........................................................................................................................

លោក-លោកស្រីមេធាវី.........................បានបង្ហាញសេចក្ដីសន្និដ្ឋានការពារដូចខាងក្រោម:

.........................................................................................................................................
....

.........................................................................................................................................
.............

.........................................................................................................................................
.............

□ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនជនត្រូវចោទ

បណ្ដោះអាសន្នដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ។

□ យើងបានឱ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬ ផ្តិតមេដៃលើកំណត់ហេតុនេះ។

□ បានអានឱ្យស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្តិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

□ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

បញ្ឈប់កំណត់ហេតុនេះនៅម៉ោងបួន និងដប់ប្រាំនាទី រសៀល នាថ្ងៃខែឆ្នាំដដែល។

| **ជនត្រូវចោទ** | **អ្នកបកប្រែ** | **មេធាវី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |
| --- | --- | --- | --- | --- |

**សាលាដំបូងខេត្តកណ្តាល**

ចៅក្រមស៊ើបសួរ "គ"

សំណុំរឿងព្រហ្មទណ្ឌលេខ:.........

ចុះថ្ងៃទី....................................

**លេខ:** ............. ដក.ស.យខ/២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន

យើង..................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល អមដោយ លោក/លោកស្រី ................................ជាក្រឡាបញ្ជី ។

- បានឃើញមាត្រា២០៣, ២០៤, ២០៥ និងមាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:........... ដកសស/២០ ចុះថ្ងៃទី...... ខែ ............. ឆ្នាំ២០២០ដែលបានបើកឲ្យស៊ើបសួរទាក់ទងនឹង:

ឈ្មោះ ................................ឈ្មោះហៅក្រៅ....................ភេទ.......... អាយុ........ឆ្នាំ ជាតិ ...........................កម្រិតវប្បធម៌...................... មុខរបរ..................... ទីកន្លែងកំណើត ..............................................................................................................................ទីលំនៅបច្ចុប្បន្ន ...................................................................................................................................ឪពុកឈ្មោះ ................................(រស់/ស្លាប់) ម្តាយឈ្មោះ ................................................. (រស់/ស្លាប់) នៅលីវ/(ប្តី/ប្រពន្ធ)................................មានកូន.............នាក់។ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.......................... ។ ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ: ....................................................... ប្រព្រឹត្តនៅភូមិ .................................................................................................................................. កាលថ្ងៃទី ...............................................តាមបញ្ញត្តិមាត្រា............................................................................... ............................................. ។

- បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង
- បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ
- បានឃើញកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់:

១. ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ .......................................... ត្រូវបានដាក់ នៅក្រោមការពិនិត្យពីបទ: ............................................................................................ ប្រព្រឹត្តនៅ .........................................................................................................................កាលពីថ្ងៃទី ..........................................តាមបញ្ញត្តិមាត្រា..................... ។

២.តំណាងអយ្យការបានស្នើសុំដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ............. ................................... ដើម្បីជានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្រឡូកច្របល់ដែល បណ្តាលមកពីបទល្មើសនេះ ។

៣. ជនត្រូវចោទឈ្មោះ ...................................ឆ្លើយថាខ្លួនពិតជាបានប្រព្រឹត្តមែន ។

II. សំអាងហេតុនៃសេចក្តីសម្រេច:

៤. ជនត្រូវចោទឈ្មោះ ................................... ត្រូវបានចោទប្រកាន់ពីបទ...........។

៥. ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ផ្អែកតាមមាត្រា២០៥ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺ:

- ដើម្បីបញ្ចប់បទល្មើសនិងបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសំភារៈដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការ តាមនីតិវិធី
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ដែលបណ្តាល

មកពីបទ ល្មើសនេះដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និង អាចធានាឲ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយ មានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចនូវគោលដៅខាងលើ ។

**ហេតុដូច្នេះសម្រេច**

ឃុំខ្លួនជនត្រូវចោទឈ្មោះ ..........................................ជាបណ្តោះអាសន្នរយៈពេល អតិបរមា.............
(.....................)ខែ ។

ថ្ងៃ................................ ខែ............ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល, ថ្ងៃទី...........ខែ............. ឆ្នាំ២០២០

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

មន្ទីរស៊ើបសួរ«គ»

**លេខ: ................ តក.ព្រទ/**

## ដីកាសម្រេច
## ដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង............................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

- បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ............. អក ចុះថ្ងៃទី...... ខែ....... ឆ្នាំ២០២០ ។
- បានឃើញសំណុំរឿងស៊ើបសួរលេខៈ.............. សស ចុះថ្ងៃទី......... ខែ........ ឆ្នាំ២០២០។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ...........ដកសស ចុះថ្ងៃទី......... ខែ........ ឆ្នាំ ២០២០ ។
- បានឃើញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខៈ............ សរ.មឃ/២០ ចុះថ្ងៃទី.......... ខែ........... ឆ្នាំ ២០២០ ។

## សំអាងហេតុ

ដើម្បីឲ្យជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះក្នុងដំណើរការនៃនីតិវិធី គប្បីសម្រេចដាក់ជនត្រូវចោទឲ្យជាប់កាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ , ២២៦ និង មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/ រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧។

## ហេតុដូច្នេះសម្រេច

**ក. ដាក់ជនត្រូវចោទ**

ឈ្មោះ.........................ភេទប្រុស អាយុ............. ឆ្នាំ ជាតិខ្មែរ មុខរបរ........... ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន...................................... ឪពុកឈ្មោះ.............. ម្តាយឈ្មោះ...................ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.....................។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ...........................ប្រព្រឹត្តនៅ................. ............. កាលពីថ្ងៃទី........................។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា .............................. នៃ....................។

**ឲ្យគោរពនូវកាតព្វកច្ចដូចខាងក្រោម:**

១. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

២. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

**៥.**ក្នុងករណីដែលជនត្រូវចោទរូបនេះគេចវេះមិនគោរពតាមកាតព្វកិច្ចដូចបានកំណត់ខាងលើ យើងនឹងសម្រេចឃុំ ខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន។

ថ្ងៃ............................... ខែ............. ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បានទទួលដំណឹងរួចហើយ កណ្តាល ថ្ងៃទី..........ខែ................ឆ្នាំ២០២០

កណ្តាល ថ្ងៃទី.........ខែ............ឆ្នាំ២០២០ **ចៅក្រមស៊ើបសួរ**

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ:..........អក
ចុះថ្ងៃទី.... ខែ......... ឆ្នាំ ២០២០

# ដីកាកោះ

យើង......................ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

អញ្ជើញឈ្មោះ.....................ភេទប្រុស អាយុ.......ឆ្នាំ ជាតិខ្មែរ។

ទីលំនៅបច្ចុប្បន្ន ភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ឲ្យចូលទៅកាន់សាលាដំបូងខេត្តកណ្ដាល (**បន្ទប់ ត**)

**នៅថ្ងៃទី........... ខែ........... ឆ្នាំ២០២០ វេលាម៉ោង..........ព្រឹក /ល្ងាច**

ដើម្បី: មកសាកសួរ

ពីដំណើររឿង: **បរិហាបង្កាច់កេរ្តិ៍**

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ ទិន និងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃ........................... ខែ........... ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល ថ្ងៃទី......... ខែសី........ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

មន្ទីរស៊ើបសួរ

លេខ ............. បគ.ចខ/២០

# ដីកាបង្គាប់ឲ្យចូលខ្លួន
